ដាំដើមជីវិត
LIFE GROWTH

ភាគ ១

# តម្រាពិជ័យសង្គ្រាម សាមកុក

## បទវិភាគដ៏ស៊ីជម្រៅនាំមកនូវបញ្ញា

ប្រាជ្ញ វិជ័យ
អ្នកបង្កើតយុទ្ធសាស្ត្រជីវិតនិងអ្នកនិយាយជំរុញចិត្តមនុស្សដ៏មានឥទ្ធិពល...

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# កម្រាពិជ័យសង្គ្រាម
# សាមកុក

«បទវិភាគដ៏ស៊ីជម្រៅនាំមកនូវបញ្ញា»

ចំណេះដឹងគ្រប់វិនាទី

**ប្រាជ្ញ វិជ័យ** អ្នកបង្កើតយុទ្ធសាស្ត្រជីវិតនិងអ្នកនិយាយជំរុញចិត្តមនុស្សដ៏មានឥទ្ធិពល...

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ដាំដើមជីវិត


| | |
|---|---|
| នាយកប្រតិបត្តិ | ប្រាជ្ញ វិជ័យ |
| កែសម្រួល | ប្រាជ្ញ វិជ័យ |
| ទីប្រឹក្សា | សាស្ត្រាចារ្យ ទុយ វាសនា |
| បណ្ណាធិការ | ស៊ាន សោភ័ណ |
| សហការីប្រែ | តឹក រដ្ឋា |
| រចនាក្រប | សារុន សិទ្ធី |
| ពិនិត្យអក្ខរាវិរុទ្ធ | គណៈកម្មការដាំដើមជីវិត |
| ប្រធានចែកចាយ | កួន គ្រេន |
| លេខ ISBN | 978 999 63 42 011 |



## រក្សាសិទ្ធិគ្រប់យ៉ាង



បោះពុម្ពលើកទី៣ ភ្នំពេញ ឆ្នាំ២០១២

សម្រាប់អតិថិជនជាវដុំយើងខ្ញុំនឹងមានសេវាកម្មដល់ទីកន្លែង។

សូមទាក់ទងមកលេខៈ ០៧៧ ៨៥ ០៣ ០៥

Email ✉ Lifegrowthbooks@yahoo.com



www.facebook.com/7khmer
Fb page : Entertainment And Knowledge

## អារម្ភកថា

រឿងសាមកុកជារឿងដ៏ល្បីឈ្មោះបោះសម្លេងមិនត្រឹមតែស្រុកខ្មែរយើងទេ តែវាក៏ជារឿងដ៏ល្បីល្បាញក្នុងពិភពលោកផងដែរ។ នៅលោកខាងលិចគេហៅរឿងសាមកុកនេះថា *(The three kingdom)* ប្រែជាខេមរៈភាសាយើងថា «នគរ៣» ។ នៅក្នុងសាច់រឿងសាមកុកនេះពោរពេញទៅដោយល្បិចកិច្ចកល និងកាប់ចាក់ប្រយុទ្ធគ្នាយ៉ាងមហាអស្ចារ្យរហូតមានពាក្យនិយាយតៗគ្នាថា «អ្នកមើលរឿងសាមកុកនេះចប់ប្រាំពីរដងមិនអាចយកជាមិត្តភក្តិបានទៀតផង»។

*តើរឿងនេះវាពិតជាអីចឹងមែនឬយ៉ាងណា?* ចំពោះខ្លួនខ្ញុំបាទបានអាន និងមើលរឿងសាមកុកនេះតាំងពីឆ្នាំ២០០៣មក។ បើគិតជាចប់វិញនោះមិនតិចជាង២០ដងទេ។ ក្នុងប្រវត្តិសាស្ត្ររបស់ខ្ញុំនេះខ្ញុំមិនដែលបានទៅបោកប្រាស់នរណាម្នាក់សោះឡើយ។ នេះសបញ្ជាក់ឲ្យឃើញថាការអានឬមើលរឿងសាមកុកនេះ វាមិនដល់ថ្នាក់ទុកចិត្តមិនបានសោះ។ ឯមនុស្សខ្លះមិនដែលនឹងបានស្គាល់ថារឿងសាមកុកនោះវាមុខយ៉ាងម៉េចផងតែពូកែដើរបោកប្រាស់គេណាស់។ ចុះរឿងនោះវាយ៉ាងម៉េចទៅវិញ?...

យើងធ្លាប់ឮតែរឿងសាមកុកតែមិនដែលសូវបានឮទេ ពាក្យថា «តម្រាពិជ័យសង្គ្រាមសាមកុក»នោះ។ ពាក្យថា«តម្រា ពិជ័យសង្គ្រាម

www.facebook.com/7khmer
Fb page : Entertainment And Knowledge

សាមកុក» មានន័យថាជាក្បួនប្រយុទ្ធឬក្បួនយុទ្ធសាស្ត្រខ្លីៗដើម្បីធ្វើការប្រយុទ្ធយកជ័យជម្នះទៅលើសត្រូវរបស់ខ្លួន។ បើអស់លោកណាបានអាននូវក្បួនប្រយុទ្ធ និងក្បួនយុទ្ធសាស្ត្រខ្លីៗក្នុង «តម្រាពិជ័យសង្គ្រាមសាមកុក» នេះហើយនឹងបានកើតនូវបញ្ញាដ៏មហាអស្ចារ្យ ហើយអាចនឹងកែប្រែជីវិតពីចាញ់មកឈ្នះវិញដូចបកចេកដូច្នោះដែរ ដោយគ្រាន់តែលោកអ្នកនាំយកនូវក្បួននីមួយៗពី «តម្រាពិជ័យសង្គ្រាមសាមកុក» នេះទៅធ្វើការវិភាគឲ្យបានស៊ីជម្រៅម្តងមួយៗ ដោយមិនបង្ខំ ព្រោះថា «តម្រាពិជ័យសង្គ្រាម»ល្អៗកំពុងមានក្នុងដៃរបស់លោកអ្នកហើយ។

ខ្ញុំសូមបញ្ជាក់ផងដែរថា ការបកប្រែនេះ គឺបកចេញតាមសំនាងភាសាចិនទៀជីវ មិនបកប្រែតាមសំនាងភាសាចិនកុកងឺទេ ដូច្នេះមិត្តអ្នកអានខ្លះដែលធ្លាប់តែចាំឈ្មោះតួអង្គនីមួយៗ តាមសំនាងភាសាចិនកុកងឺ ឧទាហរណ៍ដូចជាឆាវឆាវ តែបកតាមសំនាងចិនទៀជីវថាចូចូទៅវិញនោះ ខ្ញុំបាទក៏សូមធ្វើការអភ័យទោសពីមិត្តអ្នកអានផងដែរ។

មួយទៀតដោយខ្ញុំបាទបានផ្ទៀងផ្ទាត់ជាមួយតម្រាចាស់ៗដូចជាតម្រាលោកឧកញ៉ានូ កន ក៏បកតាមនាងចិនទៀជីវដែរ ព្រោះហេតុហេតុដូច្នេះទើបខ្ញុំបាទបកតាមសំនាងចិនទៀជីវតែម្តងទៅ។

(សូមជូនពរលោកអ្នកឲ្យមានសំណាងល្អលើផ្លូវដែលលោកអ្នកដើរ...)

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# មាតិការឿង


១/កលយុទ្ធនៃការឡោមព័ទ្ធ..............................................................២

២/ប្រែប្រួលតាមឱកាស................................................................១១

៣/ចំណុចខ្សោយនៃការចូលរួមពីសម្ពន្ធមិត្ត.......................................១៣

៤/យុទ្ធសាស្ត្រខ្ចីប្រើបង្គន់រួចប្លន់យកផ្ទះ...........................................២៨

៥/ឧបាយកលស្រីស្រស់...............................................................៣៧

៦/សង្គ្រាមញោះឲ្យខឹង..................................................................៤១

៧/ឧបាយកលបញ្ឆោតខ្លាពីរក្បាលឲ្យដណ្ដើមចំណីអាហារគ្នា......៤៨

៨/ឧបាយកលដេញខ្លាឲ្យទៅខាំជាមួយឆ្កែព្រៃ..................................៥៥

៩/ទស្សនៈផ្អែកយោធារបស់ស៊ុនសេក...........................................៦១

១០/យុទ្ធសាស្ត្រស្រែកខាងឆ្វេងតែទៅវាយខាងស្តាំឬវាយពីលិច
បញ្ឆោតពីកើត.............................................................................៧០

១១/សិល្បៈក្នុងការដេញប្រយុទ្ធ.......................................................៧៨

១២/ព័ត៌មានក្លែងក្លាយនិងការវិភាគព័ត៌មានរបស់អ្នកដឹកនាំ...........៨៦

១៣/ផែនការរបស់តាន់កុង...............................................................៩៦

១៤/ប្រាជ្ញារបស់ទៀវហ៊ុយ...............................................................១០៥

១៥/ឧបាយកលបោកបញ្ឆោតសត្រូវឲ្យធ្វើងកន្ទើងឬឡើងចាង..១១៣

១៦/អ្នកដែលនៅក្នុងហេតុការណ៍តែងវង្វេងអ្នកដែលនៅក្រៅ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ហេតុការណ៍តែងមើលឃើញច្បាស់..............................................១២០
១៧/សង្គ្រាមប្លន់យកស្បៀងនៅស្រុកអួថៅ...............................១២៨
១៨/ផ្សព្វផ្សាយពាក្យចចាមអារ៉ាមដើម្បីបំបែកកម្លាំងសត្រូវ.......១៣៨
១៩/ទឹកចិត្តអ្នកនយោបាយ..............................................................១៤៥
២០/ឧបាយកលពួនស្ទាក់វាយលុកទាំង១០ទិសរបស់ជៀយុក....១៥៣

www.facebook.com/7khmer
Fb page : Entertainment  And Knowledge



ឡៅពី

刘备

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ១

# យុទ្ធវិធី នៃការ ឡោមព័ទ្ធ

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

«កុំគាបសង្កត់បច្ចាមិត្តឲ្យទាល់ច្រក»
ហើយ«ការឡោមព័ទ្ធត្រូវបើកផ្លូវ...»

ពាក្យសម្ដី២ប្រយោគខាងលើនេះជាគោលការណ៍យ៉ាងសំខាន់ ដែលគេយកទៅប្រើប្រាស់ក្នុងការធ្វើសង្គ្រាមរបស់មនុស្សក្នុងសម័យ បុរាណកាល។ កលយុទ្ធនេះបើយើងនិយាយឲ្យងាយស្ដាប់ប្រៀបបីដូច ជាការដាំទឹកក្នុងឆ្នាំងដោយបិទគម្របឲ្យជិត ពេលទឹកពុះទឹកនឹងរីកមាឌ ធំឡើងៗ បើវាគ្មានច្រកចេញទេចំហាយទឹកនឹងបុកឆ្នាំងទាល់តែបែក។ ដូច្នេះ ការដាំទឹកទើបតម្រូវឲ្យមានប្រហោង ដើម្បីបញ្ចេញចំហាយទឹក ការឡោមព័ទ្ធបច្ចាមិត្តក៏ដូច្នោះដែរ។ ប្រសិនបើដាក់កម្លាំងទ័ពឡោមព័ទ្ធ សត្រូវច្រើនពេក ពួកសត្រូវនឹងធ្វើការតស៊ូប្ដូរស្លាប់ប្ដូររស់ជាមួយមិន ខាន។ ដូច្នេះនៅពេលដែលឡោមព័ទ្ធសត្រូវមិនគួរព័ទ្ធទាំងបួនផ្នែកជិត នោះទេ ត្រូវតែបណ្ដោយឲ្យសត្រូវរត់គេចចេញតាមច្រកដែលយើង បើកទុកឲ្យហើយបោកបញ្ឆោតឲ្យពួកវា ធ្លាក់ចូលទៅក្នុងឧបាយកល របស់យើង ទើបធ្វើការវាយប្រហារទៅលើពួកសត្រូវតែម្ដង។ នៅក្នុង រឿងសាមកុកមានកលយុទ្ធឡោមព័ទ្ធបច្ចាមិត្តមួយវគ្គ ដែលវាទាក់ទង នឹងរឿងនេះដូចតទៅ៖

ពេលដែលឡៅពី តាមជូហ៊ុចេញទៅបង្ក្រាបពួកចោរអាវលឿង ដែលបោះទីតាំងនៅក្រុងអួនសៀ ទៀងកុកក៏បញ្ជាឲ្យហាន់តុង មកធ្វើ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

សង្គ្រាម។ ចំណែកឯជូហ៊ី ក៏បញ្ជាឲ្យឡេវពី កួនអ៊ូ និងទៀវហ៊ុយ ឲ្យទៅឡោមព័ទ្ធនៅភាគនិរតី។

ហាន់តុងប្រមូលទ័ពសេះខ្លាំងពីរក្រុមធំៗ សម្រុកចូលវាយលុកនៅភាគអាគ្នេយ៍ ឡេវពីក៏លើកទ័ពដេញតាមពីក្រោយថែមទៀតបានធ្វើឲ្យកងទ័ពពួកសត្រូវទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ ក៏នាំគ្នារត់គេចខ្លួនចូលទៅក្នុងក្រុងអួនសៀវិញ។

នៅពេលនោះជូហ៊ី បំបែកកម្លាំងទ័ពឡោមព័ទ្ធជាប់ទិសទាំងបួន ពេលត្រូវឡោមព័ទ្ធជាប់នៅក្នុងក្រុងៗក៏កើតទុរភិក្ស។ ហាន់តុង ឃើញដូច្នេះក៏សម្រេចចិត្តបញ្ជូនទូតឲ្យទៅចរចាសារភាពសុំចុះចូលប៉ុន្តែជូហ៊ីបដិសេធចោលទើបឡេវពីនិយាយថា«សម័យមុនស្តេចហាន់កូចូ បានឡើងសោយរាជ្យក៏ដោយសារព្រះអង្គព្រមទទួលយកពួកសត្រូវដែលសុំចុះចូលជាបក្សពួក ហើយចុះហេតុអ្វីបានជាលោកបដិសេធនូវការចុះចូលរបស់ហាន់តុង ទៅវិញ»។

ជូហ៊ី និយាយតថាព្រោះសម័យកាលខុសគ្នា។ នៅសម័យនោះប្រទេសជាតិមានភាពច្របូកច្របល់ដោយសារតែបាត់បង់រាជវង្សឈិន ប្រជាជនគ្មានមេដឹកនាំពិតប្រាកដ។ ជាហេតុបណ្តាលឲ្យពួកមេដឹកនាំខ្លាំងៗ ត្រូវប្រើមធ្យោបាយអូសទាញប្រជាជន មកធ្វើជាបក្សពួករបស់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ្លួន ព្រោះហេតុដូច្នេះទើបព្រមទទួលការសុំចុះចូលពីពួកសត្រូវដើម្បីបន្ថែមកម្លាំងរបស់ខ្លួនឲ្យកាន់តែរឹងមាំ ប៉ុន្តែពេលនេះប្រទេសជាតិរបស់យើងមានស្ថេរភាពហើយពួកសត្រូវក្បត់ជាតិមានគ្នាត្រឹមតែមួយក្រុមតូចហេតុអ្វីចាំបាច់ទៅខ្លាចពួកវា? ប្រសិនបើយើង ព្រមទទួលការសុំចុះចូលរបស់ពួកវា ប្រទេសជាតិមិនកាន់តែច្របូកច្របល់ទេឬ? ហើយពួកសត្រូវនឹងកាន់តែបានចិត្ត ដើរបង្ករឿងប្លន់កាប់សម្លាប់តាមតែអំពើចិត្ត ព្រោះពួកគេគិតថា បើបរាជ័យពេលណាក៏នឹងចេញមកសុំចុះចូលនៅពេលនោះ វាប្រៀបដូចជាការជ្រោមជ្រែងឲ្យពួកសត្រូវកាន់តែបានចិត្ត នេះមិនមែនជាមធ្យោបាយដ៏ល្អនោះទេ។

ឡៅពីនិយាយថា «មិនព្រមទទួលការសុំចុះចូលពីពួកសត្រូវក៏បានតែពួកសត្រូវបើសុំចុះចូលមិនបាន ពួកគេនឹងប្ដេជ្ញាធ្វើការប្រយុទ្ធយកស្លាប់យករស់យ៉ាងពិតប្រាកដហើយភាពសាមគ្គីរបស់ពួកសត្រូវទាំងនោះគឺជាកម្លាំងដ៏មហាសាល ប្រសិនបើមនុស្សមួយម៉ឺននាក់រួមចិត្តគំនិតគ្នាជាធ្លុងមួយ តើលោកគិតថាអាចនឹងទប់ទល់ជាមួយនឹងពួកគេបានឬទេ? តើមានប្រយោជន៍អ្វីនៅពេលដែលមានទាហានដេកស្លាប់ក្នុងថ្លុកឈាមរាប់ម៉ឺននាក់ក្នុងសង្គ្រាមនោះ?សុខចិត្តដកទ័ពចេញពីទិសអាគ្នេយ៍ ហើយត្រៀមវាយលុកនៅទិសពាយ័ព្យត្រឹមតែមួយទិសទើប

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រសើរ។ នៅពេលដែលពួកសត្រូវមានផ្លូវរត់គេចខ្លួននោះ ពួកគេក៏គ្មានទឹកចិត្តនឹងធ្វើសង្គ្រាមដងដែរ។ ពួកគេនឹងបោះបង់ចោលទីក្រុង ហើយរត់គេចខ្លួនយ៉ាងពិតប្រាកដ លុះដល់ពេលនោះពួកយើងនាំទ័ពទៅពួនស្ទាក់នៅច្រកផ្លូវចេញរបស់ពួកវា។ ការធ្វើដូច្នេះ យើងនឹងចាប់ពួកគេបានយ៉ាងងាយស្រួលបំផុត»។

ជូហ៊ីពិចារណាហើយ ក៏យល់ស្របជាមួយនឹងគំនិតរបស់ឡៅតី ទើបបញ្ជាឲ្យដកកងទ័ពចេញពីទិសអាគ្នេយ៍ ហើយក៏ត្រៀមកម្លាំងទ័ពវាយលុកនៅទិសពាយ័ព្យ មិនយូរប៉ុន្មានហាន់តុង ក៏ដឹកនាំទ័ពចេញពីទីក្រុងអួនសៀ ពិតដូចជាការគិតទុក។

កងទ័ពរបស់ជូហ៊ីមាន ឡៅតី កួនអ៊ូនិងទៀវហ៊ុយដែលពួនស្ទាក់ចាំនៅតាមច្រកផ្លូវដែលបានបើកទុកឲ្យពួកសត្រូវរត់គេចខ្លួននោះ ក៏ចេញមកដេញសម្លាប់សត្រូវអស់ទាំងនោះ។ នៅពេលដែលហាន់តុងស្លាប់កងទ័ពដែលនៅសេសសល់នាំគ្នារត់ខ្ចាត់ខ្ចាយអស់គ្មានសល់។

ខ្លឹមសារនៅក្នុងវគ្គនេះ បានឆ្លុះបញ្ចាំងឲ្យឃើញពីទស្សនៈផ្នែកនយោបាយរបស់ជូហ៊ី ហើយស្របពេលគ្នានេះដងដែរ ក៏ចង់បង្ហាញពីចំណេះដឹងនិងភាពវាងវៃខាងផ្នែកយោធារបស់ឡៅតីដងដែរ។ ខណៈពេលដែលឡៅតី ស្ថិតនៅក្នុងឋានៈជាអ្នកមានជ័យជម្នះចំណែកសត្រូវ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ស្ថិតនៅក្នុងឋានៈជាអ្នកបរាជ័យនោះ ឡៅពីនៅតែសម្លឹងមើលឃើញនូវដំណោះស្រាយភ្លាមៗថា នៅក្នុងការបរាជ័យរបស់ពួកសត្រូវក៏មានលក្ខខណ្ឌល្អៗ បង្កប់ចំណែកផងដែរ។ ឯការមានប្រៀបលើសត្រូវរបស់ពួកយើង ក៏មានលក្ខខណ្ឌដែលមិនល្អបង្កប់។ ដូច្នេះហើយពួកសត្រូវអាចផ្លាស់ប្តូរស្ថានការណ៍ពីបរាជ័យឲ្យមកជាជោគជ័យវិញបាន វាដូចគ្នាទៅនឹងភាគីរបស់យើងដែលអាចប្តូរពីជោគជ័យទៅជាបរាជ័យដែរ។

ការឡោមព័ទ្ធសត្រូវជិតគ្រប់ទិស ថែមទាំងមិនព្រមទទួលយកការសុំចុះចូលពីពួកសត្រូវ វានឹងក្លាយទៅជាកម្លាំងគាបសង្កត់ដែលធ្វើឲ្យបច្ចាមិត្តត្រូវប្រយុទ្ធប្តូរស្លាប់រស់។ ការធ្វើនូវសង្គ្រាមបែបនេះទោះបីជាជូហ៊ុ ទទួលបានជ័យជម្នះក៏ដោយតែត្រូវខាតបង់កម្លាំងទ័ពជាច្រើនផងដែរ។ កាលដែលឡៅពី ស្នើឲ្យជូហ៊ុ បើកច្រកចេញដល់ពួកសត្រូវគឺបង្ហាញឲ្យឃើញថាឡៅពី យល់នូវកលយុទ្ធនៃការឡោមព័ទ្ធសត្រូវយ៉ាងច្បាស់ ហើយក៏ចេះយកទ្រឹស្តីពីតម្រាពិជ័យសង្គ្រាមនានា មកកែច្នៃប្រើប្រាស់ជាមួយនឹងស្ថានការណ៍ពិត។

ទស្សនរបស់មេដឹកនាំខាងផ្នែកយោធាបានពោលថា«ជ័យជម្នះដែលស្ថិតក្នុងលក្ខណៈត្រាំត្រែងនោះ មិនមែនជាគោលដៅដ៏ប្រសើរខ្ពង់ខ្ពស់របស់ពួកគេនោះទេ តែគោលដៅដែលប្រសើរខ្ពង់ខ្ពស់បំផុត

www.facebook.com/7khmer
Fb page : Entertainment And Knowledge

លើសលប់នោះ វាគឺជាជ័យជម្នះដែលភាគីរបស់យើងខាតបង់កម្លាំងទ័ពតិចបំផុតឬចាយវាយថ្លៃតបស្នងតិចបំផុតឯណោះវិញទេ»។

នៅក្នុងសម័យបុរាណ កម្លាំងនៃការផលិតនៅមិនទាន់មានភាពរីកចម្រើនទើបមិនមានប្រភេទអាវុធបាញ់បានឆ្ងាយគ្រប់ប្រភេទផ្សេងៗហើយយុទ្ធសាស្ត្រក្នុងការឡោមព័ទ្ធក៏នៅមានកម្រិតទាបបើមិនខ្លាំងជាងសត្រូវឲ្យពិតប្រាកដទេនោះក៏ពិបាកនឹងយកឈ្នះទៅលើសត្រូវបាន។ ហេតុដូច្នេះហើយទើបអ្នកជំនាញផ្នែកយោធាពោលថា «វិធីដ៏ប្រសើរបំផុតនោះគឺការធ្វើសង្គ្រាមដោយប្រើឧបាយកល វិធីបន្ទាប់គឺសង្គ្រាមផ្នែកការទូតឯវិធីទី៣គឺការចូលប្រយុទ្ធគ្នាដោយផ្ទាល់ វិធីដែលអន់បំផុតនោះគឺការឡោមព័ទ្ធទីតាំងរបស់ពួកសត្រូវ។

វិធីនេះអាចប្រើប្រាស់បានលុះត្រាណាតែមានភាពទាល់ច្រកតែប៉ុណ្ណោះ។ ដូច្នេះការឡោមព័ទ្ធត្រូវតែបើកផ្លូវទុកឲ្យពួកសត្រូវ យើងត្រូវជៀសវាងការប៉ះទង្គិចនៅត្រង់ចំណុចរឹងមាំរបស់ពួកសត្រូវហើយត្រូវតែរង់ចាំវាយលុកនៅត្រង់ចំណុចខ្សោយរបស់ពួកសត្រូវវិញ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពាក្យខ្មែរ
របស់យើងបាន
ពោលថា
«បើដេញ
វាយឆ្កែ
កុំវាយ
ឲ្យរហូត
វាទាល់ច្រក
ជាដាច់ខាត»

www.facebook.com/7khmer
Fb page : Entertainment And Knowledge



តាំងតុ

董卓



អួនសៀវ

袁紹

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ២

## ប្រែប្រួលតាមឱកាស

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

«នៅក្នុងវគ្គទី៤របស់រឿងសាមកុកនៅត្រង់វគ្គដែលចូឆ្វូគិតនឹងលបធ្វើឃាតតាំងតុ...»

ក្រោយពីព្រះបាទឡេនតេ ចូលទីវង្គតទៅ តាំងតុ ឆ្លៀតឱកាសរឹបអូសយកអំណាចតែម្នាក់ឯងគត់។ តាំងតុ បានដកហាំងជូពៀន ចេញពីរាជបល្ល័ង្ក ហើយបានតែងតាំងហាំងជូហៀប ឲ្យឡើងគ្រងរាជ្យបានបណ្ដាលឲ្យមានការក្រោធខឹង ពីបណ្ដានាម៉ឺនសព្វមុខមន្ត្រីនៅក្នុងវាំងយ៉ាងខ្លាំងក្លា។

ពេលនោះចូឆ្វូ មានតំណែងជាមេបញ្ជាការកងទ័ពសេះ គាត់ជាមនុស្សក្លាហាន និងស្រឡាញ់នូវភាពយុត្តិធម៌ ទើបមានគំនិតចង់កម្ចាត់តាំងតុចោល ហើយបានទៅខ្ចីកាំបិតដ៏វិសេសមួយពីអងអ៊ុន ក្នុងគោលបំណងលបធ្វើឃាតតាំងតុ។ ខ្លឹមសារនៅក្នុងវគ្គនោះ ខ្ញុំបាទនឹងនាំមកពិពណ៌នាលម្អិតដូចតទៅ៖

នៅពេលដែលចូឆ្វូ បានកាំបិតវិសេសមកហើយក៏បានដើរទៅកាន់សំណាក់របស់លោកមហាឧបរាជ។ លុះចូឆ្វូ ឃើញតាំងតុ កំពុងតែអង្គុយនៅលើអាសនៈដោយមានលីប៉ូ នៅក្បែរកៀកដូច្នេះ ទើបមិនហ៊ានចាត់ការ។ បន្ទាប់មកតាំងតុ ប្រើលីប៉ូ ឲ្យទៅយកសេះមួយក្បាលមកឲ្យចូឆ្វូ ចូឆ្វូក៏គិតថាឱកាសរបស់ខ្លួនបានមកដល់ហើយ ព្រមទាំងបានលួចនិយាយខ្សឹបៗជាមួយខ្លួនឯងថា «អាមនុស្សអាក្រក់ អាឯងសម

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គួរតែស្លាប់»។

នៅខណៈពេលដែលគិតថានឹងដកកាំបិតរកចាក់សម្លាប់តាំងតុនោះ ចូចូ ក៏កើតនូវអាការៈភ័យខ្លាចភ្លាមមួយរំពេច។ គាត់គិតថាតាំងតុមានមាឌធំប្រហែលជានឹងមានកម្លាំងខ្លាំងទើបមិនហ៊ានចាត់ការ។ គាប់ជួនពេលនោះតាំងតុ ក៏ទម្រេតខ្លួនបំរុងដេកល្ហេម។ វាអាចដោយសារតែគាត់ជាមនុស្សធាត់អង្គុយយូរមិនបានឬដោយសារតែតាំងតុ គិតថាចូចូមិនមែនជាមនុស្សស្ថិតនៅក្នុងខ្សែក្អែកជងនោះ ទើបផ្តួលខ្លួនដេកបែរខ្នងដាក់ឲ្យចូចូ។

ពេលនោះគំនិតរបស់ចូចូ ក៏លេចឡើងមកទៀតថា «ប្រញាប់ឆ្លៀតឱកាសនៅពេលដែលមនុស្សអាក្រក់នេះកំពុងដេកលក់ សម្លាប់វាចោលទៅ!» ចូចូចាប់កាំបិតជាប់នៅក្នុងដៃ ខណៈពេលដែលគិតនឹងចាក់សម្លាប់តាំងតុ តាំងតុក៏ងើបមុខឡើង សម្លឹងមើលទៅកាន់កញ្ចក់ក៏បានឃើញស្រមោលរបស់ចូចូ កំពុងដកកាំបិតនៅពីក្រោយក៏ប្រញាប់ងាកមកសួរថា«តើឯងគិតចង់ធ្វើអ្វី?»ចំពេលនោះលីប៉ូ ក៏បានដឹកសេះមករង់ចាំនៅខាងក្រៅទៀត។ ចូចូបានឃើញស្ថានការណ៍មិនអំណោយផលទើបកើតគំនិតឈ្លាសវៃមួយរំពេច ប្រញាប់លុតជង្គង់ចុះឱនថ្វាយកាំបិតដល់តាំងតុ ព្រមទាំងនិយាយថា «ខ្ញុំទើបបានកាំបិតដ៏វិសេសមួយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទើបនាំយកមកថ្វាយដល់លោកមហាឧបរាជ»។ បន្ទាប់ពីថ្វាយកាំបិតរួចហើយ ក៏ប្រញាប់ស្ទុះចេញពីសំណាក់របស់តាំងតុ ហើយក៏រត់គេចខ្លួនបាត់ស្រមោល។

នៅក្នុងរឿងសាមកុកមានរឿងរ៉ាវ ដែលទាក់ទងជាមួយនឹងការប្រើប្រាស់ភាពឈ្លាសវៃយករួចខ្លួនជាច្រើន ប៉ុន្តែគ្មានរឿងណាល្អដូចចូឆូថ្វាយកាំបិតដល់តាំងតុ ទេ។

ទង្វើរបស់ចូឆូ ទោះបីជាមានអាកប្បកិរិយាប្រែប្រួលរអិលបីដូចជាអន្ទង់ ឬជាឥរិយាបថដែលក្រឡិចក្រឡុចខិលខូចមិនសមគួរនឹងយកមកប្រើក្នុងការចិញ្ចឹមជីវិតក៏ដោយតែចូឆូ ប្រើអាកប្បកិរិយានេះនៅក្នុងផែនការលបធ្វើឃាតតាំងតុ ដើម្បីសម្រេចគោលដៅផ្នែកនយោបាយរួចទៅហើយទើបមិនគួរឲ្យមានការស្អប់ខ្ពើមប៉ុន្មានទេ។ មួយវិញទៀតវាក៏បានក្លាយជាភាពឈ្លាសវៃដែលមនុស្សជំនាន់ក្រោយៗ បានធ្វើការកោតសរសើរផងដែរ។

សម្រាប់អ្នកជំនាញខាងផ្នែកយោធា ការប្រើល្បិចខិលខូចបែបនេះចាត់ទុកជាយុទ្ធសាស្ត្រក្នុងការការពារខ្លួនដ៏ឈ្លាសវៃ ហើយវាក៏ជាគន្លឹះក្នុងការបង្កើតលក្ខខណ្ឌ ដើម្បីភាពជោគជ័យ។ ប្រសិនបើយើងអានរឿងសាមកុករហូតដល់ចប់នឹងដឹងថា ចូឆូគឺជាមនុស្សពោរពេញ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដោយបញ្ញានិងមានភាពឈ្លាសវៃបំផុត។ អ្នកដែលគិតចង់ធ្វើការងារធំ ឬចង់សម្រេចភាពជោគជ័យដ៏មហាសាលក្នុងជីវិតត្រូវតែហ៊ានប្រថុយគ្រោះថ្នាក់ ហ៊ានធ្វើឬហ៊ានទទួលខុសត្រូវចំពោះការប្រថុយគ្រោះថ្នាក់។ រឿងរ៉ាវគ្រោះថ្នាក់នឹងកើតមានឡើងរាប់រយជំពូកនៅចំពោះមុខយើង។ ដូច្នេះត្រូវតែធ្វើការសម្រេចចិត្តឬឆ្លើយតបភ្លាមៗដើម្បីផ្លាស់ប្តូរទៅតាមស្ថានការណ៍នីមួយៗ។

ការប្រើភាពឈ្លាសវៃបែបនេះ វាមិនមែនជារឿងងាយស្រួលនោះទេ។ ប្រសិនបើយើងចេះផ្លាស់ប្តូរឲ្យវាទៅតាមស្ថានការណ៍និងចេះប្រើប្រាស់ភាពឈ្លាសវៃដើម្បីដោះស្រាយបញ្ហា យើងនឹងអាចរួចផុតពីគ្រោះថ្នាក់ផ្សេងៗបានយ៉ាងមានសុវត្ថិភាព។

ពាក្យថាប្រែប្រួលតាមឱកាសដំបូងត្រូវចាប់វាឲ្យបាន។ ពាក្យថា «ចាប់យកឱកាស» សំដៅដល់អ្នកដែលចេះស្វែងរកប្រយោជន៍ពីឱកាសដែលកើតឡើងនិងចេះសម្របខ្លួនទៅតាមកាលៈទេសៈ ដូចយ៉ាងចូឆូ ដកកាំបិតបំរុងនឹងចាក់សម្លាប់តាំងតុ តែពេលដែលភ្លាត់ស្នៀតក៏ប្រញាប់លុតជង្គង់ធ្វើជាយកកាំបិតមកថ្វាយតាំងតុ ជាដើមឬដូចជាវគ្គដែលចូឆូ អញ្ជើញឡៅពីមកផឹកស្រាដើម្បីស្ទាបស្ទង់មើលថាតើឡៅពីគិតចង់ដណ្តើមអំណាចរបស់ខ្លួនឬអត់។ ពេលនោះឡៅពី បានយកនូវ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពន្លឺផ្លេកបន្ទោរបិទបាំងភាពភ័យខ្លាចរបស់ខ្លួន នេះក៏ជាការប្រែប្រួលតាមឱកាសដូចគ្នា។ វិធីប្រើប្រាស់យុទ្ធវិធីប្រែប្រួលទៅតាមឱកាសនោះគឺជាវិធីដ៏ល្អបំផុត។ យុទ្ធសាស្ត្រមួយនេះ អាចទទួលបានលទ្ធផលល្អលុះត្រាតែអ្នកប្រើប្រាស់ ចេះធ្វើឲ្យស្របតាមធម្មជាតិ មិនបន្លំធ្វើរហូតទាល់តែគេចាប់ចំណុចបាន ត្រូវតែចេះប្រែប្រួលឲ្យបានឆាប់រហ័សទៅតាមពេលវេលា ឱកាស ឬស្ថានការណ៍ និងឥរិយាបថរបស់សត្រូវ។

ការប្រែប្រួលតាមឱកាសនិងប្រើមានភាពឈ្លាសវៃដោះស្រាយបញ្ហាឲ្យទាន់ហេតុការណ៍បាន សុទ្ធតែជាគំនិតដែលកើតឡើងមកភ្លាមៗដោយពុំមានការគិតទុកជាមុននោះទេ។ នៅពេលណាដែលមានបញ្ហាកើតឡើងគឺ ខួរក្បាលអាចដំណើរការបានយ៉ាងឆាប់រហ័សប្រៀបបីដូចជាឧបករណ៍គិតលេខ ដែលអាចបង្ហាញចម្លើយបានដោយស្វ័យប្រវត្តិដូច្នោះឯង។ បច្ចុប្បន្នកាលនេះ ពួកអ្នកវិទ្យាសាស្ត្របានលាតត្រដាងនូវអាថិកំបាំងប្រភេទនេះរួចមកហើយ ប៉ុន្តែក្នុងទីនេះគឺ ប្រសិនបើចង់មានភាពឈ្លាសវាងវៃនោះគឺត្រូវអាស្រ័យលើការហ្វឹកហាត់បណ្តុះនិស្ស័យរបស់យើង។ និយាយជារួមគឺ ភាពឈ្លាសវៃមិនមែនធ្លាក់ចុះមកពីលើមេឃឬទេវតាប្រទាននោះទេ។ អ្នកដែលអាចប្រើប្រាស់ភាពឈ្លាសវៃដោះស្រាយបញ្ហាក្នុងពេលដែលមានអាសន្នបាននោះ ត្រូវតែពឹងផ្អែក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទៅលើការហ្វឹកហាត់និងគិតជាញឹកញាប់ផងដែរ។ ដូចយ៉ាងចូឆូ ដែលជាអ្នកនយោបាយ និងជាអ្នកជំនាញផ្នែកយោធាដ៏ពូកែមួយរូបនេះគាត់មានភាពស្ទាត់ជំនាញតាំងតែពីក្មេងមកម្ល៉េះ គាត់មិនមែនទើបតែឆ្លាតក្នុងពេលមានបញ្ហានោះទេ។

នៅក្នុងវគ្គទីមួយរបស់រឿងសាមកុក បានចាប់ផ្ដើមពិពណ៌នារឿងចូឆូ តាំងតែពីបើកឆាកមកថា «កាលនៅពីក្មេងឪពុកមារបស់ចូឆូឃើញចូឆូ ចូលចិត្តតែដើរលេងពាលា អាវ៉ាសែក៏កើតចិត្តស្អប់ ទើបនាំយករឿងរ៉ាវទៅប្រាប់ចូកូ ដែលត្រូវជាឪពុករបស់ចូឆូ ចូកូហៅចូឆូមកស្ដីបន្ទោសធ្វើឲ្យចូឆូ ក្រោធខឹងយ៉ាងខ្លាំង ទើបរិះរកឧបាយកលធ្វើបាបឪពុកមាវិញ»។

នៅថ្ងៃមួយ ចូឆូបានឃើញឪពុកមាដើរមក ក៏ធ្វើពុតជាខ្យល់ចាប់ដេកបម្រះននៀលនៅនឹងដី។ ឪពុកមាឃើញហើយភិតភ័យយ៉ាងខ្លាំងទើបប្រញាប់ទៅប្រាប់ដល់ចូកូ ពេលដែលចូកូ មកដល់ ចូឆូធ្វើដូចជាមិនមានអ្វីកើតឡើង។ ចូកូនិយាយថា«ឪពុកមារបស់ឯងប្រាប់ថាឯងខ្យល់ចាប់ឥឡូវបានជាស្រួលបួលហើយឬនៅ?» ចូឆូឆ្លើយថា«កូនមិនដែលមានជម្ងឺនេះទេឪពុកមាស្អប់មុខកូនទើបស្វែងរករឿងប្ដឹងពុក»។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចូកូ ក៏ជឿពាក្យសម្ដីរបស់ចូចូ ចាប់តាំងពីពេលនោះមកពេលដែលឪពុកមារបស់ចូចូ នាំរឿងយកទៅប្ដឹងទៀតក៏ចូកូ មិនជឿទើបធ្វើឲ្យចូចូ កាន់តែបានចិត្ត ប្រព្រឹត្តអាក្រក់ពាលាអាវ៉ាសែច្រើនឡើងថែមទៀត។

នៅមាននិទានមួយវគ្គទៀតបាននិយាយថា«កាលចូចូ មានវ័យជំទង់តែងតែបបួលអួនសៀវ ដើរលេងជាមួយគ្នា។ ថ្ងៃមួយពួកគេទាំងពីរនាក់បានទៅលួចមើលគូស្វាមីភរិយា ដែលទើបតែរៀបការហើយថ្មីៗ។ ពួកគេនាំគ្នាលបចូលទៅក្នុងចំការរបស់ម្ចាស់ផ្ទះ។ ពេលនោះចូចូក៏ស្រែកឡើងថា «មានចោរចូលផ្ទះ ចោរនៅទីនេះ !» មនុស្សនៅក្នុងផ្ទះនាំគ្នាចេញមកដេញចាប់ចោរ។ ចូចូ ក៏ឆ្លៀតឱកាសនោះលួចយកកូនក្រមុំគេទៅបាត់តែជាអកុសលបានវង្វេងផ្លូវចូលក្នុងព្រៃបន្លាស្រាប់តែអួនសៀវ រកច្រកចេញមកវិញមិនបានសោះទើបចូចូ ស្រែកខ្លាំងៗឡើងថា«ចោរនៅទីនេះ !» អួនសៀវ ភ័យខ្លាំងពេកទើបរើបម្រះចេញពីព្រៃបន្លាទាល់តែបាន។

បទវិភាគខាងលើនេះ វាសបញ្ជាក់ឲ្យបានឃើញថា ឧបាយកលបោកប្រាស់ផ្សេងៗ មិនមែនបានមកតែពីគម្រាពិជ័យសង្គ្រាមតែម្យ៉ាងនោះទេគឺត្រូវមានការគិតដ៏ឈ្លាសវៃផងដែរ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

«គំនិត

ច្នៃប្រឌិត

បូកនឹង

គំនិតហ៊ាន

បូកនឹង

ធ្វើសកម្មភាព

ស្មើនឹង

ឧបាយកល

នាំជីវិតជោគជ័យ»

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

អួនសៀវ

袁紹



ចូឆូ

曹操

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ៣

## ចំណុចខ្សោយ
## នៃការចូលរួម
## ពីសម្ពន្ធមិត្ត

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

នៅក្នុងវគ្គទី៥របស់រឿងនិទានសាមកុកនិយាយថា

បន្ទាប់ពីចូឆូ បានទទួលភាពបរាជ័យក្នុងការលបធ្វើឃាតតាំងតុ ហើយក៏បានរត់គេចខ្លួនទៅកាន់ក្រុងឡូងអៀង បានពុះពារឧបសគ្គគ្រប់បែបយ៉ាងទើបចូលមកដល់ក្រុងតាន់លិវ ធ្វើការប្រមូលផ្តុំកម្លាំងទ័ពនៅទីនោះព្រមទាំងផ្ញើសារទៅបបែរ បបួលចៅហ្វាយខេត្តផ្សេងៗ ឲ្យលើកទ័ពមកជួយបង្ក្រាបតាំងតុ នៅពេលដែលសារលិខិតបានទៅដល់ដៃចៅហ្វាយខេត្តផ្សេងៗ។ គេក៏នាំគ្នាទទួលការបបួលរបស់ចូឆូ ហើយនាំគ្នាលើកទ័ពមកមួយរំពេច។ ចៅហ្វាយខេត្តដែលលើកទ័ពមកលើកនេះមានដូចជា៖

- អួន ស៊ុត ចៅហ្វាយខេត្តឡាំយ៉ុង
- ហាក់ ហុក ចៅហ្វាយខេត្តគិចជិវ
- ខុង ម៉ ចៅហ្វាយខេត្តសៀវជិវ
- ឡៅ តាយ ចៅហ្វាយខេត្តអ៊ិវជិវ
- អង ខង ចៅហ្វាយខេត្តហូឡាយ
- ទៀវ ម៉ៅ ចៅហ្វាយខេត្តតាន់លិវ
- ទៀវ ប៉ូ ចៅហ្វាយខេត្តតងគុន
- អួន អ៊ុយ ចៅហ្វាយខេត្តស៊ុនយ៉ុង
- ប៉ៅ ស៊ីន ចៅហ្វាយខេត្តចេប៉ាក់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

- ខុង ឡេង ចៅហ្វាយខេត្តប៉ាក់ហៃ
- ទៀវ ធៀវ ចៅហ្វាយខេត្តកងលេង
- គួ កៀម ចៅហ្វាយខេត្តឈីជីវ
- ម៉ា ថេង ចៅហ្វាយខេត្តសេលៀង
- ស៊ុន កៀន ចៅហ្វាយខេត្ត តៀងសា
- ទៀនអៀន ចៅហ្វាយខេត្ត សៀងតុង
- កង ស៊ុនចាន ចៅហ្វាយខេត្តប៉ាក់ប៉េង
- អួន សៀវ ចៅហ្វាយខេត្តពុតហៃ។

បូករួមបញ្ចូលគ្នាជាមួយកងទ័ពរបស់ចូចូជងមាន១៨ក្រុម សរុបកម្លាំងទ័ពទាំងអស់មានដល់១០ម៉ឺននាក់ ពួកគេបានលើកឲ្យអួនសៀវ ចៅហ្វាយខេត្តពុតហៃ ធ្វើជាមេដឹកនាំ ដើម្បីបុករុកចូលក្រុងឡុកអៀង យ៉ាងអង់អាចក្លាហានជាទីបំផុត។ ប៉ុន្តែកងទ័ពសម្ពន្ធមិត្តទាំង១៨ខេត្ត ដែលរឹងមាំក្លាហានជាងកងទ័ពរបស់តាំងតុ រាប់រយដងបែរជាមិនអាចធ្វើអ្វីតាំងតុ បាន។ នៅទីបំផុតបានត្រឹមតែបណ្តោយឲ្យតាំងតុ គេចខ្លួនចេញពីក្រុងឡុកអៀង យ៉ាងសប្បាយៗ។

ចាប់តាំងតែពីពេលនោះមក សង្គ្រាមដណ្តើមអំណាចគ្នារវាងពួកចៅហ្វាយខេត្តផ្សេងៗក៏បានផ្ទុះឡើង។ តើមូលហេតុអ្វីទើបកងទ័ព

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទាំង១៨ខេត្តក្រុងសម្លាប់តាំងតុ មិនបានសម្រេច?

ក្នុងរឿងនិទានសាមកុកបានពណ៌នាទុកថា មូលហេតុសំខាន់ៗ ដែលធ្វើឲ្យកងទ័ពសម្ពន្ធមិត្ត«ឈ្លោះប្រកែកគ្នា»មិនយល់ស្របគ្នានោះ គឺបណ្តាលមកពី៖

ប្រការទី១ ប៉ៅស៊ីន ចៅហ្វាយខេត្តចេប៉ាក់ ចង់បានកេរ្តិ៍ឈ្មោះ ទើបលួចបញ្ជូនប៉ៅតុង ដែលត្រូវជាប្អូនប្រុស របស់ខ្លួននាំទ័ពសំដៅទៅ តាមផ្លូវកាត់ កាត់មុខស៊ុនកៀន ដែលមានឋានៈជាមេទ័ពស្រួចទទួល បន្ទុកនៅក្នុងការ វាយលុកនៅផ្នែកគិស៊ុយក្វាន តែនៅទីបំផុត ប៉ៅតុងក៏ ស្លាប់យ៉ាងវេទនា។ ក្នុងហេតុការណ៍លើកនេះ បានចាប់ផ្តើមធ្វើឲ្យទ័ព សម្ពន្ធមិត្តទាំង១៨ខេត្តក្រុងខូចទ្រង់ទ្រាយក្បួនទ័ព។

ប្រការទី២កងទ័ពរបស់ស៊ុនកៀន ដែលជាទ័ពស្រួចទទួលបន្ទុក វាយលុកខាងផ្នែកគិស៊ុយក្វាន បានទទួលជ័យជម្នះតែអួនសៀវ ដែល ជាកងទ័ពជំនួយបែរទៅជាមានការច្រណែនជាមួយនឹងស៊ុនកៀន ទើប បានជាមិនព្រមបញ្ជូនស្បៀងទៅឲ្យ ការខ្វែងគំនិតគ្នាទាំងនេះធ្វើឲ្យទ័ព សម្ពន្ធមិត្តមានភាពច្របូកច្របល់។

ប្រការទី៣ បន្ទាប់ពីលីប៉ូ ធ្វើសង្គ្រាមចាញ់នៅឯប៉ែកហ៊ោឡូក្វាន ហើយ តាំងតុបានឃើញស្ថានការណ៍មិនស្រួល ទើបចាប់ស្តេចធ្វើជា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឈ្លើយសឹក (ចំណាប់ខ្មាំង) ហើយផ្លាស់ប្តូររាជធានីត្រលប់ទៅកាន់ក្រុង ឡុងអៀងវិញ។

ចូច្ចូ គិតនឹងចង់ឆ្លៀតយកឱកាសនេះ ដេញកាប់សម្លាប់តាំងគុ តែអួនសៀវ បែរជានិយាយឡើងថា «កងទ័ពសម្ពន្ធមិត្តហត់នឿយខ្លាំង ណាស់មិនអាចធ្វើបានទេបើដេញពីក្រោយក្រែងទទួលបរាជ័យ»។ នេះ គឺជាខអាងមិនព្រមលើកទ័ពរបស់អួនសៀវ។

ចូច្ចូសម្រេចចិត្តលើកទ័ពទៅតែម្នាក់ឯង ទើបត្រូវកងទ័ពរបស់ តាំងគុ ដែលពួនស្ទាក់ចាំវាយប្រហារធ្វើឲ្យចូច្ចូ ចាញ់យ៉ាងដំណំ។ ចូច្ចូ ក្រោធខឹងនឹងអួនសៀវ ខ្លាំងណាស់ ទើបគិតថា អួនសៀវ ជាមេដឹកនាំ អសមត្ថភាព ក៏នាំទ័ពសំដៅទៅក្រុងអេងជិវ កងស៊ុនចានឃើញចូច្ចូ ដកខ្លួនចេញក៏លើកទ័ពត្រលប់ទៅវិញដូចគ្នា។ ហេតុការណ៍នេះធ្វើឲ្យ កងទ័ពសម្ពន្ធមិត្តបែកបាក់គ្នា។

ប្រការទី៤ ស៊ុនកៀន បានលើកទ័ពសម្រុកចូលវាយលុកក្រុង ឡុកអៀង បានត្រាប្រចាំដែនដី ទើបស្រមៃចង់ធ្វើជាស្តេចតែម្នាក់ឯង លះបង់កងទ័ពសម្ពន្ធមិត្ត និងគិតចង់លើកទ័ពត្រលប់ទៅក្រុងកាំងតាំង វិញជាបន្ទាន់។ អួនសៀវក្រោធខឹងខ្លាំងណាស់ទើបបញ្ជូនសារសម្ងាត់ បញ្ជាឲ្យឡៅពៀវ ចាំពួនស្ទាក់វាយប្រហារស៊ុនកៀន ដូច្នេះហើយទើប

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ស៊ុនកៀននិងឡៅពៀវមានការឈ្លោះប្រកែកគ្នាខ្លាំងក្លាបំផុត។

ប្រការទី៥ កងទ័ពរបស់ឡៅតាយ និងទៀវប៉ូ ខ្វះខាតស្បៀងអាហារទើបបានកើតសង្គ្រាមដណ្តើមស្បៀងអាហារគ្នា។

ប្រការទី៦អួនសៀវ ឃើញថៅហ្វាយខេត្តផ្សេងៗទាស់ទែងខ្វែងគំនិតគ្នាដូច្នេះ ប្រហែលជាមានភាពពិបាកក្នុងការដឹកនាំ ទើបបានដកកម្លាំងទ័ពរបស់ខ្លួនចេញពីក្រុងឡុកអៀង ឆ្ពោះទៅកាន់ក្រុងក្ងនតង។

ចាប់តាំងពីពេលនោះមកកងទ័ពសម្ពន្ធមិត្តទាំង១៨ខេត្តក្រុង ក៏បែកបាក់គ្នាជាបក្សជាពួក រហូតរលាយរលត់ដោយហេតុការណ៍យ៉ាងនេះឯង។ បន្ទាប់មកទៀត សង្គ្រាមដណ្តើមដែនដីដែលជារឿងដ៏ក្តៅគគុករបស់ពួកមេទ័ពទាំងឡាយក៏បានចាប់ផ្តើម។ ការពិតការបែកបាក់គ្នារបស់កងទ័ពសម្ពន្ធមិត្តនេះ គឺជារឿងដែលមិនអាចជៀសវាងបានមែនព្រោះថាកងទ័ព១៨ក្រុងមានចិត្ត១៨ដួង។ ម្នាក់ៗបោះពួយសំដៅតែទៅលើផលប្រយោជន៍ផ្ទាល់ខ្លួន និងគោលដៅរៀងៗខ្លួន។ ម្នាក់គិតថានឹងឆ្លៀតឱកាសចាប់យកត្រីនៅក្នុងទឹកល្អក់ និងឆ្លៀតឱកាសស្វែងរកប្រយោជន៍ដាក់ខ្លួន។ ម្នាក់ៗគិតតែបំផ្លាញភាគីម្ខាងទៀតឲ្យខ្ទេចខ្ទី។ ហេតុដូច្នេះហើយទើបកងទ័ពសម្ពន្ធមិត្តមិនមានភាពស្ថិតស្ថេរ។

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ឥទ្ធិពលរបស់តាំងតុ គឺជាភាពគ្រោះថ្នាក់ដ៏ធំធេង ចំពោះផលប្រយោជន៍រួមរបស់ពួកចៅហ្វាយខេត្តផ្សេងៗ។ ហេតុនេះហើយទើបពួកគេព្រមទទួលការអំពាវនាវរបស់ចូចូ បង្កើតជាសម្ពន្ធមិត្តឡើងដើម្បីមកកម្ចាត់តាំងតុ ប៉ុន្តែពេលដែលឃើញតាំងតុ អស់ឫទ្ធិ ហើយមិនមានគ្រោះថ្នាក់ដល់ខ្លួន ទើបម្នាក់ៗចាប់ផ្ដើមដណ្ដើមអំណាចបុណ្យស័ក្តិគ្នាយ៉ាងផប់ផល់។

នៅក្នុងប្រវត្តិសាស្ត្រ មានសង្គ្រាមដែលកើតពីមូលហេតុដូច្នេះច្រើនសន្ធឹកសន្ធាប់ជាមូលហេតុធ្វើឲ្យកម្លាំងទ័ពដែលមានគ្នាច្រើនជាងមិនអាចយកឈ្នះកម្លាំងទ័ពដែលមានគ្នាតិចជាងបាន។

អ្នកប្រាជ្ញម្នាក់បានពោលទុកមកថា «នៅក្នុងលោកនេះមិនមានសត្រូវដែលស្ថិតស្ថេរ ហើយវាក៏គ្មានមិត្តដែលស្ថិតស្ថេរដែរ មានតែផលប្រយោជន៍មួយប៉ុណ្ណោះដែលស្ថិតស្ថេរ»។

១១១ «គ្មានមិត្តគ្មានសត្រូវគឺមានតែផលប្រយោជន៍ប៉ុណ្ណោះ»

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ៤

## យុទ្ធសាស្ត្រ ខ្ចីប្រើបន្ទន់ រួច ប្លន់យកផ្ទះ

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

យុទ្ធសាស្ត្រនេះជនជាតិចិននិយាយថា«ខ្ចីផ្លូវវាយយករដ្ឋកួ»

យុទ្ធវិធីនេះ ប្រៀបដូចជាពួកចោរសម័យបច្ចុប្បន្ន ដែលមកសុំខ្ចីប្រើប្រាស់បង្គន់បោកបញ្ឆោតម្ចាស់ផ្ទះថា«ចុកពោះទ្រាំលែងបាន»។ ម្ចាស់ផ្ទះចិត្តល្អក៏ឲ្យចូលបង្គន់។ លុះដល់ពេលចេញមកវិញ ពួកចោរក៏ឆ្លៀតឱកាសនោះប្លន់ដណ្តើមយកទ្រព្យសម្បត្តិទៅអស់គ្មានសល់។

រឿង«ខ្ចីផ្លូវវាយយករដ្ឋកួ»នេះបានកើតឡើងតាំងតែក្នុងសម័យឈុន ឈីវ សម័យនោះរដ្ឋវី និងរដ្ឋកួ គឺជារដ្ឋជិតខាងនឹងគ្នាអាចហៅបានថា«ជារដ្ឋបងរដ្ឋប្អូន»ដែលត្រូវពឹងពាក់គ្នាទៅវិញទៅមកឬប្រៀបដូចជាអណ្តាតនិងធ្មេញដូច្នោះឯង។ ក្រោយមករដ្ឋជិនដែលជារដ្ឋធំគិតចង់លេបត្របាក់យករដ្ឋទាំងពីរ។

នៅក្នុងឆ្នាំ ៦៥៨ មុនគ្រឹះសករាជស្តេចជិនសៀនកុង បានប្រើយុទ្ធសាស្ត្រ«សុំខ្ចីប្រើបង្គន់រួចប្លន់ផ្ទះ»ដោយនាំយកមាសពេជ្រនិងសេះមានពូជល្អៗធ្វើជានុយបោកបញ្ឆោតស្តេចរបស់រដ្ឋវីព្រមទាំងបញ្ជូនទូតទៅចរចាជាមួយដែនដីរដ្ឋវីថា«សុំខ្ចីផ្លូវឆ្លងកាត់ទៅវាយយករដ្ឋកួ បន្តិចនៅរដូវប្រាំងនេះ»។ នៅក្នុងឆ្នាំនោះកងទ័ពជិន ក៏រឹបអូសយកបានក្រុងសៀយ៉ាងរបស់រដ្ឋកួ។

៣ឆ្នាំក្រោយមក ស្តេចជិនសៀនកុង មកសុំខ្ចីផ្លូវរដ្ឋវីដើម្បីវាយយករដ្ឋកួទៀត បណ្តានាម៉ឺនសព្វមុខមន្ត្រីនៅក្នុងរដ្ឋវី នាំគ្នាជំទាស់ប៉ុន្តែ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ស្តេចរដ្ឋវី មិនស្តាប់យល់ព្រមឲ្យរដ្ឋជិន លើកទ័ពឆ្លងកាត់ទៅវាយយករដ្ឋក្អូ ម្តងទៀត។ ក្រោយពីកងទ័ពជិន វាយយករដ្ឋក្អូ បានហើយ ពេលត្រលប់វិញក៏ឆ្លៀតឱកាសនោះវាយយករដ្ឋវីមួយទៀតផងដែរ។

*១១១ ជិនស្មៀនកុង បាញ់ព្រួញមួយតែបានសត្វពីរទទួលបានជោគជ័យយ៉ាងងាយស្រួលបំផុត ។*

ចាប់តាំងពីពេលនោះមកសុភាសិតដែលនិយាយថា«ខ្ចីផ្លូវវាយយករដ្ឋក្អូ» ក៏បានក្លាយទៅជារូបមន្តមួយផ្នែកយោធា។ មនុស្សជំនាន់ក្រោយក៏នាំគ្នាយករូបមន្តនេះទៅប្រើម្តងហើយម្តងទៀត«មានទាំងអ្នកទទួលបានជោគជ័យនិងអ្នកទទួលបរាជ័យ»។

ក្នុងរឿងសាមកុកមានយុទ្ធសាស្ត្រនេះដូចគ្នាគឺ ពេលអ្នូនស៊ៀវលើកទ័ពចេញពីក្រុងឡុកអៀង ទៅបោះជំរំទ័ពនៅក្រុងហូឡាយ នោះកងទ័ពរបស់អ្នូនស៊ៀវ ខ្វះខាតស្បៀងអាហារ។ ពេលនោះ អ្នូនស៊ៀវនឹកគិតចង់បានក្រុងគិជិវ ដែលជាក្រុងសម្បូរសប្បាយរបស់ហាន់ហុកទាល់តែស្រក់ទឹកមាត់ ទើបហង់គីគុន ជាមន្ត្រីស្មោះត្រង់របស់អ្នូនស៊ៀវណែនាំថា «យើងគួរតែលួចផ្ញើសារទៅប្រាប់កងស៊ុនចាន ថាឲ្យលើកទ័ពមកវាយយកក្រុងគិជិវ ជួយគ្នាវាយសន្ទប់ទាំងសងខាង ពេលក្រុងមកដល់ដៃ យើងនឹងចែកគ្នាម្នាក់ពាក់កណ្តាល កងស៊ុនចាននឹងយល់ព្រមយ៉ាងពិតប្រាកដ។ ឯហាន់ហុក ចៅហ្វាយខេត្តក្រុងគិជិវ ជាមនុស្ស

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គ្មានសតិបញ្ញា នឹងរត់មកសុំការជួយសង្គ្រោះពីលោកម្ចាស់ជាក់ជាមិនខាន។ លុះដល់ពេលនោះ លោកនឹងទទួលបានក្រុងគិជិវ ដូចបំណងប្រាថ្នាយ៉ាងប្រត្យក្ស»។

អួនសៀវ បានឮដូច្នេះហើយ ក៏បានប្រញាប់ប្រញាល់ផ្ញើសារទៅប្រាប់ដល់កងស៊ុនចាន និងណាត់ឲ្យកងស៊ុនចាន លើកទ័ពមកជួយវាយក្រុងគិជិវ ស្របពេលគ្នានោះដែរ ក៏បញ្ជូន«ទូត»ឲ្យទៅរាយការណ៍ប្រាប់ដល់ហាន់ហុកថា កងស៊ុនចានកំពុងលើកកងទ័ពមកវាយយកក្រុងគិជិវហើយ។

ហាន់ហុកបានទទួលព័ត៌មានភ្លាម ក៏ភ័យស្លន់ស្លោមិនជឿពាក្យណែនាំរបស់នាម៉ឺនសព្វមុខមន្ត្រីសោះ ទើបប្រញាប់បញ្ជូនទូតឲ្យទៅសុំការជួយសង្គ្រោះពីអួនសៀវ។

បន្ទាប់ពីអួនសៀវ បានលើកទ័ពមកដល់ក្រុងគិជិវ ហើយនោះក៏តែងតាំងហាន់ហុក ឲ្យជាមេទ័ពឯក ប្រគល់ភារកិច្ចទៅឲ្យទៀនហងខៅស៊ិវ និង ហងគី មើលការខុសត្រូវក្រុងគិជិវ បែបនេះគឺមានន័យថាបានលេបអំណាចរបស់ហាន់ហុក ទាំងស្រុងហើយ។

ហាន់ហុកខូចចិត្តណាស់ ទើបបោះបង់ចោលក្រុមគ្រួសារសាច់-ញាតិ ហើយជិះសេះរត់គេចខ្លួនទៅរស់នៅជាមួយនឹងទៀវម៉ៅ ក្នុងក្រុង

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទិវលីវ បន្ទាប់ពីនោះមកអ្នកសៀវ និងកងស៊ុនចាន ដែលជាសម្ពន្ធមិត្ត ក៏ប្រឈមមុខដាក់គ្នា ម្នាក់ៗសុទ្ធតែចង់គ្រប់គ្រងក្រុងគិជិវ ទើបកើតជាសង្គ្រាមផ្ទុះឡើងឥតឈប់ឈរ។

អ្នកសៀវ រឹបអូសយកបានក្រុងគិជិវ ដោយប្រើយុទ្ធសាស្ត្រ«ខ្ចីផ្លូវវាយយករដ្ឋក្វ»ហើយបានទទួលជ័យជម្នះយ៉ាងងាយស្រួលបំផុត។

ជិវយីក៏ធ្លាប់ប្រើប្រាស់យុទ្ធសាស្ត្រនេះដូចគ្នាដែរ ក៏ប៉ុន្តែទទួលនូវភាពបរាជ័យទាំងស្រុង។ រឿងនេះគឺមាននៅក្នុងរឿងនិទានសាមកុក វគ្គទី៥៦ ក្រោយពីធ្វើសង្គ្រាមជាមួយនឹងសេកជេក ចប់ហើយ ឡៅពី បានធ្វើតាមផែនការរបស់ខុងបេង ឆ្លៀតយកឱកាសពេលដែលជីវយីកំពុងតែធ្វើសង្គ្រាមជាមួយចូចូ សម្រុកចូលរឹបអូសយកក្រុង«កេងជិវ» ដោយប្រាប់ថា«សុំខ្ចី»ក្រុងកេងជិវប្រើប្រាស់ជាបណ្ដោះអាសន្ន។

ក្រោយមក តាំងង៉ី បញ្ជូនទូតមកទារក្រុងកេងជិវ វិញជាច្រើនលើកច្រើនសាតែមិនបានវិញទាល់តែសោះ។ ជំបូងខុងបេង ធ្លាប់សន្យាថាបន្ទាប់ពីវាយយកក្រុងសេឈួន បានមកដល់ដៃហើយ នឹងប្រគល់ក្រុងកេងជិវ ទៅឲ្យវិញ។ ក្រោយមកទៀតក៏អាងថាឡៅជៀង ដែលជាអ្នកគ្រប់គ្រងក្រុងសេឈួន នោះជាខ្សែស្រឡាយរបស់ឡៅពី ប្រសិនបើលើកទ័ពទៅដណ្ដើមយកក្រុងសេឈួន នោះ ខ្លាចក្រែងមនុស្សម្នាគេ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដាក់បណ្ដាសា។

ភាគីខាងឡៅតី ស្វែងរកខមកអាងដោះសាម្ដងហើយម្ដងទៀត បានធ្វើឲ្យជិវយី ក្រោធខឹងសឹងដាច់ក្បាលដាច់កន្ទុយទើបនឹករកឧបាយឡើងថា «ប្រសិនបើឡៅតី មិនព្រមលើកកងទ័ពទៅវាយដណ្ដើមយកក្រុងសេឈួន ទេនោះ ខ្ញុំជិវយី នឹងលើកទ័ពដណ្ដើមយកមកឲ្យដោយខ្លួនឯង»។

ជិវយី សង្ឃឹមថា គេនឹងបានប្រើប្រាស់នូវផែនការលើកទ័ពទៅដណ្ដើមយកក្រុងសេឈួន ដោយឆ្លងកាត់ក្រុងកេងជិវ ពេលត្រលប់មកវិញវាយយកកេងជិវ តែម្ដងតែមិននឹកស្មានសោះថាខុងបេង ដែលជាកំពូលអ្នកប្រាជ្ញដឹងទាន់ហេតុការណ៍ទាល់តែសោះ ហើយបានដាក់ផែនការបកទៅរកជិវយី វិញ ធ្វើឲ្យជិវយី ទាល់ប្រាជ្ញាធ្លាក់ចូលទៅក្នុងឧបាយកលរបស់ខុងបេង តែម្ដង។ ខណៈពេលដែលជិវយី លើកទ័ពមកដល់ក្រុងកេងជិវ កងទ័ពដែលពួនស្ទាក់ចាំ ក៏បានស្ទុះព្រួតចេញមកឡោមព័ទ្ធកងទាហានរបស់ជិវយី ជាប់ សម្លេងស្រែកឲ្យចាប់ជិវយី ទាំងរស់ក៏លាន់ឮកងរំពងពេញព្រៃ ពេលដែលជិវយី ដឹងថា «ចាញ់ឧបាយក៏ស្រែកឡើងខ្លាំងដោយកំហឹង»។ ស្នាមរបួសដែលត្រូវគ្រាប់ព្រួញក៏រើឡើងបណ្ដាលឲ្យជិវយី ធ្លាក់ពីលើខ្នងសេះលាន់សូរឡើងខ្ទាក។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បទវិភាគខាងលើបានបង្ហាញថា ទាំងអ្នូនសៀវ ទាំងជិវយី ប្រើយុទ្ធសាស្ត្រដូចគ្នាប៉ុន្តែឲ្យផលខុសប្លែកពីគ្នា។ ដូច្នេះ គោលសំខាន់ៗក្នុងការប្រើយុទ្ធសាស្ត្រគឺត្រូវចេះផ្លាស់ប្តូរត្រូវបង្កើតយុទ្ធសាស្ត្រថ្មីៗ បើគិតចង់ធ្វើត្រាប់តាម «រូបមន្តស្រាប់» របស់អ្នកដទៃនោះ គឺត្រូវចេះប្រែប្រួលទៅតាមកាលៈទេសៈ និងអាចផ្លាស់ប្តូរបានទាន់ពេលវេលា ទើបអាចជួបប្រទះនូវភាពជោគជ័យ។ ដូចយ៉ាងអ្នូនសៀវ ធ្វើតាមផែនការរបស់ហាងគី ដំបូងបន្លំធ្វើជាបបែរបប្ចូលកងស៊ុនចាន ឲ្យលើកកងទ័ពមកជួយវាយក្រុងគិជិវ តែផ្ទុយទៅវិញបែរជានាំព័ត៌មានទៅប្រាប់ដល់ហាន់ហុកធ្វើឲ្យហាន់ហុកចាញ់ឧបាយ ដើម្បីមកសុំការជួយសង្គ្រោះពីខ្លួន។ នៅពេលបុកចូលក៏រឹបអូសយកក្រុងគិជិវ បានហើយទើបកម្ចាត់ហាន់ហុកឲ្យផុតស្រឡះតែម្តង។

មូលហេតុធំ ដែលធ្វើឲ្យអ្នូនសៀវ ជួបប្រទះនូវភាពជោគជ័យក្នុងការប្រើយុទ្ធសាស្ត្រនេះដោយសារតែអ្នូនសៀវ បានសិក្សាទិន្នន័យផ្សេងៗយ៉ាងល្អិតល្អន់ហើយអាចសរុបបានថា ហាន់ហុកគឺជាមនុស្សដែលគ្មានបញ្ញាទើបចាញ់កលឧបាយខ្លួនយ៉ាងងាយ។

ម្យ៉ាងវិញទៀតអ្នូនសៀវ ធ្វើមិនអាចឲ្យអ្នកដទៃចាប់ចំណុចបានហើយអាចិកំបាំង ទើបតែលាតត្រដាង នៅពេលដែលផែនការរបស់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

អ្នួនសៀវ បានសម្រេចគោលដៅតែជីវយី ទទួលបរាជ័យពីយុទ្ធសាស្រ្ត នេះដោយសារតែចិត្តអន្ទះសា និងចង់ដណ្ដើមយកក្រុងកេងជីវ ត្រលប់មកវិញឲ្យខាងតែបានយ៉ាងឆាប់រហ័ស បូករួមជាមួយនឹងក្រុងកេងជីវ មានការប្រុងប្រយ័ត្នខ្ពស់ផង ទើបជីវយី មិនអាចសម្រេចគោលបំណង របស់ខ្លួនបាន។ ដូច្នេះការប្រើប្រាស់ឧបាយកលត្រូវគិតដល់សតិបញ្ញា របស់គូបដិបក្ស ពេលវេលា ឱកាស ទីកន្លែង និងបុគ្គលជាគោល។ បើ មិនដូច្នេះទេនឹងជួបប្រទះនូវភាពបរាជ័យដូចជីវយី យ៉ាងពិតប្រាកដ។

«ធ្វើមួយគិតមួយ
ធ្វើពីរគិតពីរ
ធ្វើបីគិតបី...
ចូរកុំតក់ក្រហល់»

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទៀវ សៀន

貂蟬





ជីវ យ៉ី

周瑜

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ៥

## ឧបាយកល ស្រីស្រស់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

យុទ្ធសាស្ត្រនៃការបង្ក្រាបសត្រូវឲ្យបរាជ័យទាំងឡាយទាំងពួង ឧបាយកលស្រីស្រស់ស្ថិតនៅក្នុងលំដាប់ថ្នាក់លេខមួយរហូត ។

ពាក្យស្លោកមួយបានពោលទុកថា « វីរជនក្លាហានកម្រនឹងរួចផុតពីកណ្តាប់ដៃស្រីស្អាត»។ តើមានអ្នកណាខ្លះដែលហ៊ានអះអាងថា «ខ្លួនជាមនុស្សមានចិត្តរឹងប៉ឹងមិនទន់ខ្សោយក្នុងរឿងស្រីៗជាពិសេសគឺស្រីស្រស់នោះ»។ ក្នុងប្រវត្តិសាស្ត្រចិនអ្នកជំនាញផ្នែកយោធាតែងតែប្រើស្រីស្អាតមកបង្ក្រាបសត្រូវដែលមានភាពរឹងមាំជាងខ្លួនជានិច្ច។

ដូចយ៉ាងនៅក្នុងសម័យឈុនឈិវ ដែលរដ្ឋយ៉ៃ ទៅបង្ក្រាបរដ្ឋអ៊ូដោយការបញ្ជូនស្រីស្អាតឈ្មោះថា «សៃស៊ី» ទៅពន្ទក់ «ហ៊្វូសៃ»ដែលជាស្តេចនៅរដ្ឋអ៊ូ ហើយនៅក្នុងនិទានសាមកុកវិញ នាងទៀវសៀន គឺជាអ្នកកម្ចាត់តាំងតុ ឧបាយកលស្រីស្រស់នៅក្នុងសាមកុកមាននៅក្នុងវគ្គទី៨បានពោលថា ក្រោយពីកងទ័ពសម្ព័ន្ធមិត្តទាំង១៨ខេត្តក្រុងបានទទួលបរាជ័យក្នុងការសម្លាប់តាំងតុ ហើយនោះ។ អងអ៊ុន បានប្រើនាងទៀវសៀន ឲ្យធ្វើជាខាន់ស្លាដើម្បីញុះញង់តាំងតុ និងលីប៉ូ ឲ្យឈ្លោះប្រកែកគ្នាបន្ទាប់មកក៏ខ្ញីដៃលីប៉ូ សម្លាប់តាំងតុ ជាបន្ត ប៉ុន្តែបើវិភាគឲ្យស៊ីជម្រៅឧបាយស្រីស្រស់ដែលអងអ៊ុន យកមកប្រើនេះ វាគួរតែហៅថា«ឧបាយកលប្រទាក់កងគ្នា» គឺជាយុទ្ធសាស្ត្រដ៏ល្អមួយក្នុងចំណោមយុទ្ធសាស្ត្រទាំងឡាយដើម្បីនឹងបង្ក្រាបសត្រូវដូចគ្នា។ ម្យ៉ាងវិញទៀត

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក្នុងគម្រាពិជ័យសង្គ្រាមបានពោលទុកថា «មិនគួរប្រយុទ្ធជាមួយកងទ័ពដែលមានកម្លាំងខ្លាំងក្លានោះទេ គួរធ្វើឲ្យវាអស់កម្លាំងជាមុនសិនទើបរកឱកាសសម្លាប់វាជាក្រោយ» មានន័យថាមិនគួរអន្ទះអន្ទែងចូលប្រយុទ្ធជាមួយសត្រូវដែលមានកម្លាំងខ្លាំងជាងទាំងល្វីល្វើនោះទេ ប៉ុន្តែគប្បីប្រើឧបាយកលធ្វើឲ្យសត្រូវប្រយុទ្ធគ្នា និងកាប់សម្លាប់គ្នាឯងដើម្បីបន្ថយកម្លាំងវាទាល់តែទន់ខ្សោយដល់កម្រិតសូន្យ បន្ទាប់មកចាំចូលទៅវាយប្រយុទ្ធទើបដណ្តើមយកបានជ័យជម្នះយ៉ាងងាយស្រួល។

«នៅក្នុងពិភពលោកនេះ
បើគ្មានស្រីស្រស់ទេ
លុយ អំណាច បុណ្យស័ក្តិ
ក៏គ្មានន័យដែរ
វីរបុរសក៏ប្រហែលមិនកើតឡើងដែរ»

www.facebook.com/7khmer
Fb page : Entertainment And Knowledge



អង់ អ៊ុន

王允

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ៦

# សង្គ្រាម
# គ្មោះ
# ឲ្យខឹង

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

នៅក្នុងវគ្គទី៩នៃរឿងនិទានសាមកុកពោលទុកថា...

ពេលដែលតាំងតុ ត្រូវលីប៉ូ សម្លាប់បានហើយលីឈុយ គុយគី ទៀវចេ និងហួនទៀវ ដែលជាកងទ័ពឯករបស់តាំងតុ នោះបាននាំគ្នារត់គេចខ្លួនទៅនៅខេត្តសៀងសៃ បន្ទាប់មកទើបបញ្ជូនទូតនាំសារមកកាន់ទីក្រុងទៀងហាន់ដើម្បីនឹងសុំអភ័យទោស។

អងអ៊ុន មានលីប៉ូ ជាកម្លាំងសំខាន់ ទើបបដិសេធចោលនូវការសុំអភ័យទោសនោះ លីឈុយ និងគុយគី ត្រូវគាបសង្កត់ទាល់តែគ្មានផ្លូវចេញក៏សម្រេចចិត្តប្រមូលកម្លាំងទ័ពរាប់ម៉ឺននាក់នៅក្រុងសៀងសៃ ហើយបែងចែកកងទ័ពចេញជា៤ក្រុមដើម្បីសម្រុកចូលវាយលុកក្រុងទៀងហាន់ ក្នុងគោលបំណងស៊ូស្លាប់ដើម្បីសងសឹកឲ្យតាំងតុ អងអ៊ុនបញ្ជាឲ្យលីប៉ូ លើកទ័ពទៅធ្វើសង្គ្រាមជាមួយលីឈុយ គុយគី ទៀវចេ និងហួនទៀវ ដោយសារតែពួកគេទាំងនេះ មិនមែនជាដៃគូជាមួយនឹងលីប៉ូ ត្រឹមតែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ ក៏ត្រូវដកថយត្រលប់ទៅវិញរាប់សិបគីឡូ។

ក្នុងផ្នែកកម្លាំងទ័ពលីឈុយ និងគុយគី ចាញ់ប្រៀបលីប៉ូ ក៏ពិតមែន ប៉ុន្តែលីឈុយ ជាមនុស្សឆ្លាតគិតរកឧបាយកលក្នុងការផ្លាស់ប្តូរស្ថានការណ៍ពីបរាជ័យឲ្យទៅជាជោគជ័យវិញគឺឧបាយកល«វាយលុកជាប់ៗគ្នាឬវាយលុកបណ្តាក់គ្នា»។ ឡូក្លួនចុងពិពណ៌នាហេតុការណ៍វគ្គ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នេះទុកយ៉ាងរស់រវើកថា ពេលដែលលីប៉ូ បានលើកទ័ពមកដល់ជើងភ្នំ ក៏ជួបជាមួយនឹងកងទ័ពរបស់លីឈុយ កងទ័ពរបស់លីឈុយ ប្រយុទ្ធយ៉ាងអង់អាចក្លាហានតែបន្ទាប់មកក៏ដកថយឡើងទៅលើភ្នំ។

លីប៉ូ គិតចង់ឡើងតាម រំពេចនោះឯងដុំថ្មក៏ធ្លាក់ចុះមកពីលើភ្នំហាក់បីដូចគ្រាប់ភ្លៀងធ្វើឲ្យកងទ័ពរបស់លីប៉ូ សម្រុកចូលទៅមុខមិនបាន។ ភ្លាមៗនោះ ក៏មានរបាយការណ៍ជាបន្ទាន់មកថា កងទ័ពរបស់គុយគី បុកចូលមកពីក្រោយហើយ។ ពេលនោះលីប៉ូ ប្រញាប់ដកថយ តែបានឮសម្លេងស្គរកងរំពងស្រែកថា កងទ័ពរបស់គុយគី ដកថយទៅវិញ ហើយលីប៉ូគិតចង់លើកទ័ពត្រលប់ទៅវិញ សម្លេងស្គរក៏បានបន្លឺឡើងស្រែកថា កងទ័ពរបស់លីឈុយ បុកចូលមកទៀតហើយ។

លីប៉ូ នៅមិនទាន់នឹងបានត្រៀមខ្លួនផង ស្រាប់តែកងទ័ពរបស់គុយគី ក៏មកវាយសង្គ្រុបពីផ្នែកខាងក្រោយ ខណៈពេលដែលកងទ័ពរបស់លីប៉ូ រត់មកដល់ស្រាប់តែកងទ័ពរបស់គុយគី បានទូងស្គរដកទ័ពត្រលប់ទៅវិញទៀត។ លីឈុយ និងគុយគី ញោះឲ្យលីប៉ូ ឲ្យក្រោធខឹងទាល់តែញ័រពេញទាំងខ្លួន។

លីឈុយ និងគុយគីធ្វើបែបនេះជាបន្តបន្ទាប់ច្រើនថ្ងៃធ្វើឲ្យលីប៉ូវិលក្បាលចង់ធ្វើសង្គ្រាម ក៏ធ្វើមិនបាន ចង់ឈប់ក៏ឈប់មិនបាន ខណៈ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពេលដែលកំពុងតែវិលក្បុងនោះ អ្នកនាំសារក៏ចូលមករាយការណ៍ថា កងទ័ពរបស់ទៀវចេ និងហ្វូនទៀវ សម្រុកចូលវាយក្រុងទៀងហាន់ ហើយឥឡូវកំពុងតែស្ថិតនៅក្នុងសភាពដ៏គ្រោះថ្នាក់។ លីប៉ូក៏ប្រញាប់លើកទ័ពត្រលប់ទៅវិញ ប៉ុន្តែលីឈុយ និងគុយគី បានលើកទ័ពដេញវាយតាមពីក្រោយ។ ទាហាន៤ក្រុមពង្វក់លីប៉ូ ឲ្យច្របូកច្របល់និងធ្វើឲ្យកំពូលអ្នកក្លាហានមួយរូបនេះកំរើកខ្លួនលែងបាន។

ទីបំផុតលីប៉ូ ក៏ត្រូវចាញ់ ហើយបោះបង់ចោលផ្ទះសម្បែង និងបានដឹកនាំទ័ពសេះជាងមួយរយនាក់ រត់គេចចេញពីទីក្រុងចូលទៅរស់នៅជាមួយនីងអួនស៊ុត។ រឿងនិទានសាមកុកក្នុងវគ្គនេះ ស្រដៀងគ្នានឹងរឿងមួយក្នុងសៀវភៅ «សៀវថៃជឺអ៊ុ» នៅក្នុងសៀវភៅនោះមានរឿងនិទានខ្លីមួយរឿងពោលថា មានក្មេងគង្វាលចៀមពីរនាក់បានចូលទៅក្នុងព្រៃជ្រៅជួបជាមួយកូនខ្លាព្រៃពីរក្បាល ក្មេងទាំងពីរនាក់នោះក៏គិតរកឧបាយសម្លាប់មេខ្លាព្រៃនោះចោល។ ពួកគេក៏បាននាំគ្នាចាប់យកកូនខ្លាម្នាក់មួយក្បាល ហើយក៏នាំគ្នាឡើងទៅលើដើមឈើធំម្នាក់មួយដើម។ ដើមឈើទាំងពីរនោះ នៅឆ្ងាយពីគ្នាប្រហែលជាពីរទៅបីម៉ែត្រប៉ុណ្ណោះ។ មិនយូរប៉ុន្មានមេខ្លាព្រៃក៏វិលត្រលប់មកវិញ វាខំប្រឹងស្រែករកកូនរបស់វាតែមិនឃើញ ទើបក្មេងគង្វាលចៀមទាំងពីរនាក់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នាំគ្នាមួលស្លឹកត្រចៀករបស់កូនខ្លែព្រៃមួយក្បាល កូនខ្លែព្រៃក៏ស្រែក ពេលដែលមេខ្លែព្រៃបានឮសម្លេងកូនរបស់វាស្រែកភ្លាម ក៏មានការក្រោធខឹងយ៉ាងខ្លាំងហើយបានព្យាយាមខាំដើមឈើនោះ។ ពេលនោះក្មេងគង្វាលចៀមនៅឯដើមឈើម្ខាងទៀត ក៏ក្តិចដើងកូនខ្លែព្រៃមួយក្បាលទៀតឲ្យស្រែកឡើង។ ពេលនោះមេខ្លែព្រៃបានឮសម្លេងកូនខ្លែស្រែកនៅដើមឈើម្ខាងទៀតក៏បោះបង់ចោលដើមឈើមួយដើមនោះចោលហើយក៏រត់ទៅខាំដើមឈើមួយដើមផ្សេងទៀត។ វារត់ទៅរត់មករវាងដើមឈើទាំងពីរដើមនោះជាច្រើនលើកច្រើនសា នៅទីបំផុតក៏នឿយហត់ទាល់តែដាច់ខ្យល់ស្លាប់។

ផែនការរបស់ក្មេងគង្វាលចៀម ក្នុងរឿងនិទាននេះ ក៏ដូចគ្នានឹងផែនការរបស់លីឈុយ និងគុយគី ដែរ។ សកម្មភាពរបស់មនុស្សទាំងនេះបានផ្តល់គោលគំនិតយ៉ាងជ្រៅដល់យើង។ នៅក្នុងសមរភូមិធំធេងនោះអ្នកដែលអាចយល់នូវស្ថានការណ៍បាន គឺគេអាចអង្គុយចាំទទួលជ័យជម្នះយ៉ាងងាយស្រួលបំផុតប្រៀបដូចជាអង្គុយរង់ចាំឲ្យជ្រូក វារត់មកបុកគាំបិតប៉ុងគោដោយខ្លួនឯងដោយយើងមិនចាំបាច់ទៅចំណាយកម្លាំងអ្វីឡើយ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

វិធីបញ្ឆោតឲ្យជ្រូករត់មកបុកកាំបិតប៉ុងតោនេះគឺជាការញោះឲ្យសត្រូវក្រោធខឹងខ្លាំង ហើយរត់ស្ទុះទៅវិញទៅមកទាល់តែអស់កម្លាំង។ នៅក្នុងខណៈពេលដែលរត់ស្ទុះដោយកំហឹងនោះ សត្រូវនឹងបាត់បង់សតិសម្បជញ្ញៈ(ស្មារតី) បង់កម្លាំងក្នុងការធ្វើចលនា និងបាត់បង់ឱកាសទទួលជ័យជម្នះ។ នេះជាភាពអស្ចារ្យនៃសង្គ្រាមអុចអាលញុះញង់ឬជាភាពអស្ចារ្យនៃយុទ្ធសាស្ត្រ«ចាក់ឲ្យប្រឡោតបញ្ឆោតឲ្យខឹង»។

«ខាំឲ្យដល់ឆ្អឹង
ទើបគេញញើង
ចំណីមិនរបូតចេញពីមាត់»

www.facebook.com/7khmer
Fb page : Entertainment  And Knowledge



លី ប៉ូ

呂布

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ៧

# ឧបាយកល
# បោកបញ្ឆោត
# ខ្លាពីរក្បាល
# ឲ្យដណ្តើម
# ចំណីអាហារគ្នា

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

នៅក្នុងវគ្គទី១០របស់និទានសាមកុកពោលទុកថា...

ក្រោយចូឆូ បានធ្វើសង្គ្រាមចាញ់ដៃលីប៉ូ ហើយក៏ឆ្លៀតឱកាសខណៈពេលដែលមេទ័ពកំពុងតែច្បាំងគ្នាបាននាំយកព្រះបាទហៀនតេត្រលប់ទៅកាន់ក្រុងហ៊ិត រ៉ៃកុ។ ចាប់តាំងពីពេលនោះមកចូឆូ អាងព្រះរាជឱង្ការធ្វើអំពើអាត្រាតជោរឃៅ និងសន្ធុអណ្ណាចផ្ទាល់តែមានឥទ្ធិពលដ៏ខ្លាំងក្លាជាងមេទ័ពទាំងអស់ ផ្កាសប្តុរបានមកជាភាគីដែលមានប្រៀបផ្នែកខាងយោធា។

ពេលនោះឡេពី បានដឹកនាំកម្លាំងទ័ពទៅបោះទីតាំងនៅឯក្រុងឈីជិវ។ ពេលដែលលិប៉ូ ចាញ់សង្គ្រាមជាមួយចូឆូ នោះលីប៉ូរត់គេចខ្លួនមករស់នៅជាមួយនឹងឡេពី ឡេពីក៏ប្រគល់ក្រុងសៀវជាយ ដែលជាក្រុងតូចទៅឲ្យលីប៉ូត្រួតត្រា។

ចូឆូ ដឹងពត៌មានភ្លាមខ្លាចក្រែងឡេពី និងលីប៉ូ រួមគ្នាប្រឆាំងជាមួយខ្លួនទើបប្រមូលមេទ័ពទាំងអស់មកពិភាក្សារៀបចំផែនការ។ ដំបូងមេទ័ពខៅឆូ ជានាថា «នឹងដឹកនាំកងទ័ពក្លាហានប្រាំម៉ឺននាក់ ទៅវាយលុកក្រុងឈីជិវ នឹងកាត់ក្បាលឡេពី និងលីប៉ូមកឲ្យចូឆូ ប៉ុន្តែស៊ុនហុកទីប្រឹក្សារបស់ចូឆូ បានបដិសេធដាច់អហង្ការដោយផ្តល់ហេតុផលថាលោកមេទ័ពស្ទាត់ជំនាញ តែរឿងប្រើប្រាស់កម្លាំងមិនចេះប្រើប្រាស់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នូវផែនការសោះ ឥឡូវនេះក្រុងហ៊ូតូ ទើបតែស្ថាបនាឡើង យើងមិនគួរបង្កសង្គ្រាមនោះទេ»។

ខ្ញុំមានផែនការវិសេសមួយហៅថា« ឧបាយកលបោកបញ្ឆោតខ្លាពីរក្បាលឲ្យដណ្ដើមចំណីគ្នា» ពេលនេះបើទោះបីជាឡៅពី គ្រប់គ្រងក្រុងឈីជីវ ក៏ដោយ ប៉ុន្តែនៅមិនទាន់បានទទួលព្រះរាជឱង្ការតែងតាំងជាផ្លូវការនៅឡើយ។ ប្រសិនបើលោកម្ចាស់ទូលសុំព្រះរាជឱង្ការតែងតាំងឲ្យឡៅពី ធ្វើជាចៅហ្វាយខេត្តឈីជីវ ព្រមទាំងបញ្ជូនសារសម្ងាត់ប្រាប់ដល់ឡៅពី ជាឲ្យសម្លាប់លីប៉ូ ចោល បើគ្រប់យ៉ាងនឹងប្រព្រឹត្តទៅតាមផែនការ។ យើងក៏មិនចាំបាច់ខាតបង់អ្វីទាំងអស់ តែបើមិនសម្រេចលីប៉ូ ក៏នឹងសម្លាប់ឡៅពី។ នេះហើយគឺជាឧបាយ«បោកបញ្ឆោតខ្លាពីរក្បាលឲ្យដណ្ដើមចំណីគ្នា»។

ឧបាយកលនេះជាឧបាយកលដែលសង្ឃឹមថាខ្លួននឹងបានផលប្រយោជន៍ដោយធ្វើការញុះញង់ឲ្យគូសត្រូវប្រយុទ្ធគ្នាឯងរហូតទាល់តែមានរបួសគ្រោះថ្នាក់ទាំងសងខាង ឬក៏ដូចជាឧបាយអង្គុយនៅលើភ្នំរង់ចាំមើលខ្លាពីរក្បាលខាំគ្នាអីចឹងដែរ។ រឿងនេះកើតឡើងនៅក្នុងសម័យឈុនឈីវ ឯណោះ ខ្ញុំបាទនឹងនាំមកនិទានដូចតទៅ៖

www.facebook.com/7khmer
Fb page : Entertainment And Knowledge

មានកសិករម្នាក់ឈ្មោះថាពៀនជួង ឃើញខ្លាពីរក្បាលចង់ចាប់គោរបស់ខ្លួនទៅស៊ីក៏ត្រៀមខ្លួននឹងសម្លាប់ខ្លានោះចោលប៉ុន្តែមិត្តភក្តិគេបែរមកនិយាយរារាំងថាខ្លាពីរក្បាលបំរុងនឹងដណ្តើមគ្នាស៊ីគោ។ ចូរឯងនៅឲ្យស្ងៀមមួយស្របក់សិន។ ពួកវានឹងត្រូវខាំគ្នាទាល់តែរបួសធ្ងន់ទាំងសងខាងដល់ពេលនោះចាំឯងចូលទៅសម្លាប់ចោលទាំងពីរក្បាលតែម្តង។ វាប្រៀបដូចជាបាញ់ព្រួញមួយបានសត្វពីរដូច្នោះដែរ។

ពៀនជុងធ្វើតាមឧបាយដូចពោលខាងលើ។ នៅទីបំផុតគាត់ក៏បានសម្លាប់ខ្លាទាំងពីរក្បាលនោះមែន ទើបអ្នកជំនាញផ្នែកខាងយោធានាំយកឧទាហរណ៍ពីរឿងនិទានមកធ្វើជាគោលការណ៍ និងធ្វើជាតម្រាពិជ័យសង្គ្រាមថា «អង្គុយនៅលើភ្នំរង់ចាំមើលខ្លាខាំគ្នាបានទទួលផលប្រយោជន៍ដ៏អស្ចារ្យដោយមិនចាំបាច់ចំណាយកម្លាំងឡើយ»។

សិក្សាពីគណិតវិទ្យាយកទៅប្រៀប ឬដោះស្រាយយុទ្ធសាស្ត្រខាងលើ (១+១=២) (១-១=០) ប្រសិនឡៅពី រួមកម្លាំងជាមួយនឹងលីប៉ូឥទ្ធិពលរបស់ខ្លាពីរក្បាលនេះរមែងមានគ្រោះថ្នាក់ទៅដល់ចូឆូ ទើបចូឆូប្រើឧបាយព្រះរាជឱង្ការ ដែលគ្មានប្រយោជន៍អ្វីសោះ មកធ្វើជានុយសម្រាប់បោកបញ្ឆោតឡៅពី ធ្វើឲ្យឡៅពីសម្លាប់លីប៉ូ ប៉ុន្តែមិននឹកស្មានសោះថាឡៅពី បានដឹងខ្លួនទាន់ដោះស្រាយដោយយកឧបាយក្នុងសារ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

សម្ងាត់មួយច្បាប់នោះទៅឲ្យលីប៉ូ អាន។ លទ្ធផលចុងក្រោយខ្លាទាំងពីរក្បាលនោះរួចផុតពីគ្រោះថ្នាក់ មិនបានខាំគ្នាដូចអ្វីដែលចូឆូ គិតទុកជាមុននោះឡើយដោយប្រើរូបមន្តគណិតវិទ្យា(១-១=០)ប្រសិនបើប្រើតាមរូបមន្ត(១+១=២)នឹងមានគ្រោះថ្នាក់មិនខាន។

(១−១=០) ស្មើនឹងអស់បញ្ហា

(១+១=២) ស្មើនឹងបន្ថែមបញ្ហា ។

ការបង្កើតជម្លោះ ហើយដណ្តើមផលប្រយោជន៍ចេញពីជម្លោះនោះមកគ្រប់គ្រង គឺជាចំណុចសំខាន់ក្នុងវេទិការនៃផ្នែកនយោបាយរបស់ចូឆូ ចូឆូខំប្រឹងប្រែងយកឧបាយកលនេះមកប្រើប្រាស់ម្តងហើយម្តងទៀត ប្រសិនបើសម្រេច ខ្លួនគឺជាភាគីដែលទទួលបាន តែបើសិនជាបរាជ័យខ្លួនក៏គ្មានខាតបង់អ្វីទាំងអស់។ ម្យ៉ាងវិញទៀត ព្រះរាជាក៏ទ្រង់ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ចូឆូ ធ្វើឲ្យចូឆូលេងល្បិចកលនេះបានយ៉ាងងាយស្រួលបំផុត។

ចូឆូបានយកឧបាយកលនេះមកប្រើម្តងទៀតក្នុងវគ្គទី៥៨របស់និទានសាមកុក រឿងនេះកើតឡើងក្រោយពីចូឆូ រៀបចំផែនការសម្លាប់ម៉ាថេងរួចរាល់ហើយ ប៉ុន្តែចិត្តនៅតែខ្លាចក្រែងម៉ាឈៀវ ដែលជាកូនរបស់ម៉ាថេង លើកទ័ពមកសងសឹក។ ហេតុដូច្នេះហើយ ទើបសរសេរសំបុត្រផ្ញើទៅហាន់ស៊ុយ ដែលជាចៅហ្វាយខេត្តសេលៀងថា«ប្រសិន

www.facebook.com/7khmer
Fb page : Entertainment And Knowledge

លោកអាចចាប់ខ្លួនម៉ាឈៀវ យកមកកាន់ក្រុងហ៊ូតូបានព្រះចៅអធិរាជនឹងតែងតាំងរូបលោកឲ្យធ្វើជាសេនាប្រមុខ»។

ហាន់ស៊ុយ ដែលជាបងប្អូនរួមសម្បថជាមួយនឹងម៉ាឈៀវ មិនហ៊ានគិតក្បត់ ទើបយកសំបុត្រនោះទៅប្រគល់ឲ្យម៉ាឈៀវ ហើយចាប់ទូតរបស់ចូចូសម្លាប់ចោលភ្លាមៗ។ ចូចូ បានប្រើឧបាយ «បញ្ឆោតខ្លាពីរក្បាលឲ្យដណ្តើមចំណីគ្នា» ពីរដង តែមិនបានសម្រេចថ្វីបើសំបកក្រៅមិនបានសម្រេច ប៉ុន្តែសាច់ក្នុងវិញ ឧបាយកលនេះបានទទួលលទ្ធផលល្អតែម្តង ដោយសារតែពួកមេទ័ពម្នាក់ៗ ដណ្តើមកិត្តិយសកេរ្តិ៍ឈ្មោះគ្នាទាល់តែឈ្លក់វង្វេងអស់ ទើបបានជាគ្មាននរណាម្នាក់ជឿជាក់គ្នាទៅវិញទៅមកពិតប្រាកដ។

បន្ទាប់ពីឡៅពី បាននាំយកសារសម្ងាត់របស់ចូចូ ទៅឲ្យលីប៉ូអានដោយសង្ឃឹមថា ការសម្តែងនូវភាពស្មោះត្រង់បែបនេះ នឹងអាចគ្រប់គ្រងចិត្តរបស់លីប៉ូ បាន តែផ្ទុយទៅវិញវាក្លាយជាជម្ងឺមិនទុកចិត្តគ្នារបស់លីប៉ូ ទៅវិញ។ ចំណែកហាន់ស៊ុយ ក៏ដូចគ្នាដែរសូម្បីតែបានចាប់ទូតរបស់ចូចូ សម្លាប់ចោលនៅចំពោះមុខរបស់ម៉ាឈៀវ ក៏ដោយចុះប៉ុន្តែអ្នកទាំងពីរនៅតែមានជម្ងឺមិនទុកចិត្តគ្នា បើស្ថានការណ៍ប្រែប្រួលកើតឡើងពេលណា ស្លាកស្នាមប្រេះឆានោះក៏នឹងបែកធ្លាយមួយរំពេច

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពេលនោះដែរ។ តាមការពិតរឿងបែបនេះកើតឡើងបានដោយសារតែបុគ្គលម្នាក់ៗគិតតែពីផលប្រយោជន៍របស់ខ្លួនឯងរៀងៗខ្លួន។

ក្រោយមកមិនយូរប៉ុន្មាន លីប៉ូក៏សម្រុកចូលរឹបអូសយកក្រុងកេងជិវ ពីទ្បៅពីបាន ចំណែកឯហាន់ស៊ុយ វិញក៏ឈ្លោះប្រកែកគ្នាជាមួយនឹងម៉ាឈៀវ យ៉ាងខ្លាំងដែរ។ ខណៈពេលដែលហាន់ស៊ុយ ចេញទៅធ្វើសង្គ្រាមជាមួយម៉ាឈៀវ នោះ ក៏រត់ទៅស្ម័គ្រស្មោះជាមួយចូចូ បើទោះបីជារឿងទាំងអស់នេះ កើតឡើងពីមូលហេតុសំខាន់ៗផ្សេងៗក៏ដោយ ប៉ុន្តែក៏មិនអាចបដិសេធបានទេថា វាមិនមានការពាក់ព័ន្ធជាមួយនឹងឧបាយកលខាងលើនេះ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ៨

## ឧបាយកល ដេញខ្លា ឲ្យទៅខាំ ជាមួយ ឆ្កែព្រៃ

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ឧបាយកល «បញ្ឆោតខ្លាពីរក្បាលឲ្យដណ្ដើមចំណីគ្នា» ដែលចូចូ ប្រើនោះមិនអាចឃើញលទ្ធផលទាន់នឹងភ្នែកទេ ពោលគឺមិនអាចបំផ្លាញសម្ពន្ធមិត្តរវាងឡោពី និងលីប៉ូ បានទើបចូចូ ពិភាក្សាជាមួយនឹងស៊ុនហុក សាជាថ្មីម្ដងទៀតតើត្រូវធ្វើដូចម្ដេច? ស៊ុនហុក ជ្រួញចិញ្ចើមសញ្ជឹងគិតហើយ ឆ្លើយតបវិញភ្លាមថា ត្រូវប្រើឧបាយ«ដេញខ្លាឲ្យទៅខាំគ្នាជាមួយឆ្កែព្រៃ»។ ឧបាយកលនេះគឺ បញ្ជូនសារសម្ងាត់ទៅប្រាប់ដល់អួនស៊ុត ថា «ឡោពីផ្ញើលិខិតក្រាបទូលព្រះរាជា សុំលើកទ័ពទៅវាយលុកក្រុងឡាំគុន របស់អួនស៊ុត»។ នៅពេលដែលអួនស៊ុតបានដឹងព័ត៌មានភ្លាមនឹងក្រោធខឹងហើយគេប្រាកដជាត្រៀមកម្លាំងទ័ពសម្រាប់ទប់ទល់យ៉ាងពេញទំហឹងនិងពេញកម្លាំងមិនខាន។

មួយទៀតឲ្យបន្លំព្រះរាជឱង្ការបញ្ជាឲ្យឡោពី លើកទ័ពទៅច្បាំងជាមួយអួនស៊ុត នេះគឺជាការសម្រួចស្នែងក្របីឲ្យជល់គ្នា ហើយវាថែមទាំងធ្វើឲ្យលីប៉ូកាន់តែមានការសង្ស័យខ្លាំងឡើងៗផងដែរ។ ចូចូ ធ្វើតាមផែនការនេះហើយនៅទីបំផុតឡោពី និងអួនស៊ុត ក៏ច្បាំងគ្នាមែន។

ចំណែកឯលីប៉ូ ក៏ឆ្លៀតឱកាសពេលដែលឡោពី លើកទ័ពទៅបង្ក្រាបអួនស៊ុត បានទាំងប្រគល់ក្រុងកេងជិវ ឲ្យទៀវហ៊ុយ ជាអ្នកមើលការខុសត្រូវតែទៀវហ៊ុយ ជាមនុស្សប្រមឹកទើបលីប៉ូ រួមគំនិតគ្នាជាមួយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នឹងចូប៉ា សម្រុកចូលរឹបអូសយកក្រុងកេងជិវ បាន។ គោលដៅនៅក្នុងការ«ដេញខ្លាឲ្យទៅខាំជាមួយខ្លែព្រៃនេះ» ចូឆូ នៅតែសំដៅទៅលើការបំផ្លាញសម្ពន្ធមិត្តរវាងឡៅពី និងលីប៉ូ ប៉ុន្តែទទួលបានលទ្ធផលបន្ថែមមួយទៀតគឺអាចញុះញង់ឲ្យឡៅពី និងអួនស៊ុត កាប់សម្លាប់គ្នា។ កាលដែលកាប់សម្លាប់គ្នាទៅវិញទៅមកបែបនេះ ផលប្រយោជន៍ទាំងអស់ធ្លាក់ទៅលើចូឆូ តែម្នាក់ឯង។

មើលផែនការរបស់ស៊ុនហុកហើយនឹងបានយល់ថា«ខ្លា»ដែលស៊ុនហុក ពោលនោះគឺសំដៅដល់ឡៅពី និងអួនស៊ុត ចំណែកខ្លែព្រៃសំដៅដល់លីប៉ូ។ ចូឆូពឹងផ្អែកទៅលើការបង្កើតនូវពាក្យចចាមអារ៉ាមញុះញង់ឲ្យអួនស៊ុតនិងឡៅពីទាស់ទែងគ្នា។ បន្ទាប់មកប្រើព្រះរាជឱង្ការបញ្ជាឲ្យឡៅពី និងអួនស៊ុត ប្រយុទ្ធគ្នាឯង។ ខ្លែព្រៃដូចលីប៉ូបានឱកាសទើបរឹបអូសយកក្រុងកេងជិវបានយ៉ាងងាយស្រួលបំផុត។

ចូឆូ ប្រើឧបាយកលតែមួយគត់ ក៏ប៉ុន្តែអាចបង្វិលក្បាលឡៅពី អួនស៊ុត និងលីប៉ូ ឲ្យប្រយុទ្ធគ្នាបាននេះចាត់ទុកជាឧបាយកលដ៏ប្រសើរបំផុត។ ប៉ុន្តែរឿងដែលធ្វើឲ្យមិត្តអ្នកអានមិនយល់នោះគឺថាហេតុអ្វីទើបស៊ុនហុក និយាយថាពេលដែលញុះញង់ឲ្យឡៅពី និងអួនស៊ុត ច្បាំងគ្នាហើយលីប៉ូនឹងមានការសង្ស័យកាន់តែខ្លាំងឡើង?

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ការពិតនោះគឺ លីប៉ូមិនចង់នៅក្រោមអំណាចរបស់ឡេវតី នោះទេ។ ក្រោយពីចាញ់សង្គ្រាមជាមួយចូចូ លីប៉ូក៏រត់មកពឹងពាក់ឡេវតី ពេលនោះឡេវតី ក៏ធ្លាប់ប្រគល់ខេត្តកេងជីវឲ្យទៅលីប៉ូ ដែរហើយលីប៉ូ ក៏ព្រមទទួលយកដោយឥតកោតក្រែងអ្វីទាំងអស់ ទាស់តែម្យ៉ាងគត់គឺ ខណៈពេលដែលនឹងទទួលត្រាប្រចាំតំណែង ស្រាប់តែឃើញកួនអ៊ូ និង ទៀវហ៊ុយ ឈរត្អឹងនៅពីខាងក្រោយខ្នងឡេវតី លីប៉ូក៏នឹកខ្លាចទើបមិន ហ៊ានទទួលយកធ្វើពុតជាបដិសេធ ហើយនាំទ័ពទៅបោះទីតាំងនៅឯ ស្រុកសៀវផាយជំនួសវិញ។

រឿងនេះបញ្ជាក់ឲ្យឃើញថាលីប៉ូ មានចិត្តចង់បានខេត្តកេងជីវ មកជាយូរមកហើយ។ លីប៉ូគឺជាមនុស្សដ៏ក្រឡិចក្រឡុចគ្មានគោលដៅ ច្បាស់លាស់នោះទេ។ យើងអាចឃើញសកម្មភាពរបស់គាត់ថាតើគាត់ ជាមនុស្សដែលក្រឡិចក្រឡុចយ៉ាណានោះ។ ខ្ញុំបាទនឹងលើកឡើងជា ឧទាហរណ៍ជូនមិត្តអ្នកអានដូចតទៅ៖

ដំបូងលីប៉ូ ធ្វើជាកូនធម៌របស់តេងង៉ួន ហើយក្រោយមកឃើញ ថាតាំងតុ បានផ្តល់ផលប្រយោជន៍ច្រើនជាងក៏ទៅយកតាំងតុ ធ្វើជាពុក ធម៌ហើយបានសម្លាប់តេងង៉ួន ចោល។ លីប៉ូជាមនុស្សអកតញ្ញូ ទោះបី ជាទៀវហ៊ុយ កាលណោះមិនស្រវឹងស្រាក៏លីប៉ូ នៅតែឆ្លៀតឱកាសរឹប

www.facebook.com/7khmer
Fb page : Entertainment And Knowledge

អូសយកខេត្តកេងជិវ ដែរ។

ឈុតឆាកនៅក្នុងវគ្គនេះ វាបានឆ្លុះបញ្ចាំងឲ្យឃើញពីការតស៊ូផ្នែកកងទ័ពផ្នែកនយោបាយ ផ្នែកការទូត និងបើកបង្ហាញមុខមាត់ពិតប្រាកដរបស់ចូឆូ ឡៅពី លីប៉ូ និង អួនស៊ុតចេញមកយ៉ាងច្បាស់ក្រឡែតតែម្តង។ បុគ្គលអស់ទាំងនេះ បើទោះបីជាបានក្លាយមនុស្សឈ្លាសឆ្លាតនិងជាកំពូលមនុស្សក៏ដោយ ប៉ុន្តែពួកគេសុទ្ធតែជាអ្នកឈ្លក់វង្វេងនឹងកិត្តិយសកេរ្តិ៍ឈ្មោះនិងអំណាច ជាមនុស្សមានពុតត្បុតបោកប្រាស់គ្នាទៅវិញទៅមកនិងមិនបានគិតអ្វីក្រៅតែពីផលប្រយោជន៍នោះឡើយ។

ការតម្កល់ខ្លួនក្នុងសភាពបែបនេះ តើនៅមានគុណធម៌សេសសល់ដែរឬទេ? ម្យ៉ាងវិញទៀត វាក៏បានឆ្លុះបញ្ចាំងឲ្យឃើញផងដែរ ថាការតស៊ូផ្នែកកងទ័ពមិនមែនកើតឡើងដោយឯងនោះទេ តែជាលទ្ធផលបន្ទាប់ពីការតស៊ូផ្នែកនយោបាយ ផ្នែកដែនការ និងផ្នែកការទូត។

ក្នុងគោលការណ៍ពិជ័យសង្គ្រាមបានពោលទុកថា«ការរក្សានូវផលប្រយោជន៍របស់ខ្លួនទុកឲ្យបានគ្រប់គ្រាន់ហើយមិនចាំបាច់ប្រយុទ្ធគ្នាដោយសារកម្លាំងទ័ពនោះ គឺចាត់ទុកជានយោបាយដ៏ប្រសើរបំផុត» ហេតុដូច្នេះ ទើបការប្រើឧបាយកល «បញ្ឆោតខ្លាពីរក្បាលឲ្យដណ្តើមចំណីគ្នាស៊ី» ឬឧបាយកល «ដេញខ្លាឲ្យទៅខាំនឹងផ្តៃព្រៃ»អាចចាត់ទុក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បានថាជាអ្នកស្ទាត់ជំនាញផ្នែកខាងយោធាថ្នាក់ខ្ពស់ អាចថ្លឹងថ្លែងផល ប្រយោជន៍ដល់ខ្លួនបានច្រើនបំផុត ពីការបង្កើតភាពទាស់ទែងគ្នាឡើង ហើយក៏ទាញយកផលប្រយោជន៍ពីភាពទាស់ទែងនោះ។

ចូចូ បានធ្វើឲ្យឡៅពី លីប៉ូ និងអួនស៊ុតប្រយុទ្ធគ្នាឯង ហើយខ្លួន មិនចាំបាច់ចំណាយកម្លាំងកងទ័ពសូម្បីតែម្នាក់។ ឧបាយនេះគឺវាត្រូវគ្នា នឹងគោលការណ៍នយោបាយពិជ័យសង្គ្រាមថ្នាក់ខ្ពស់ចំម៉ាច់តែម្តង។

«នៅពីក្រោយ
សកម្មភាព
របស់មនុស្ស
គឺផលប្រយោជន៍...»

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ៩

## ទស្សន ផ្នែកយោធា របស់ ស៊ុន សេក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅក្នុងរឿងនិទានសាមកុក ឡូក្វានចុងសរសេរពីស៊ុនសេក មិនសូវច្រើនប៉ុន្មានទេ ក៏ប៉ុន្តែស៊ុនសេក បែរជាផ្តល់នូវទស្សនយ៉ាងសែនជ្រាលជ្រៅហើយវាមានសារសំខាន់ណាស់ដល់មិត្តអ្នកអាន។ អ្នកអាចយកគំនិតនេះទៅប្រើក្នុងជីវិតប្រចាំថ្ងៃបានផងដែរ។

ស៊ុនសេក គឺជាមនុស្សពូកែមានអានុភាពលើសមនុស្សទូទៅ។ គាត់ចេះក្បាច់គុនច្រើន និងជានាយទាហានដែលមានអំណាចខ្លាំងក្លាវ័យក្មេងម្នាក់។ ក្នុងវគ្គទី១៩របស់រឿងនិទានអាណាចក្រទាំងបីសរសេរទុកថានៅពេលដែលស៊ុនសេក ប្រយុទ្ធជាមួយឡៅអ៊ីវ ឯស្រុកអៀងជិវមិនទាន់បានដល់៣ទឹកផង ក៏អាចចាប់អ៊ិប៊ី ដែលជានាយទាហានរបស់ឡៅអ៊ីវ បានយ៉ាងស្រួល។ នៅពេលនោះមានទាហានម្នាក់ទៀតឈ្មោះវូឡេង ប្រញាប់ចូលមកដើម្បីជួយអ៊ិប៊ី ស៊ុនសេកងាកមកក្រោយស្រែកគំហកដាក់ខ្លាំងៗ។ វូឡេងភ័យ ក៏ភ្លាត់ធ្លាក់ពីលើខ្នងសេះស្លាប់នៅនឹងកន្លែងតែមួយប៉ប្រិចភ្នែកទៅ។

ហេតុការណ៍នេះ បានបង្កើតនូវការចាប់អារម្មណ៍ដល់មនុស្សដែលបានឃើញផ្ទាល់នឹងភ្នែកយ៉ាងខ្លាំង។ ចាប់តាំងពីពេលនោះមកនរណាៗក៏ហៅស៊ុនសេក ថា«វីរបុរសវ័យក្មេង»ឬ«សេនាប្រមុខវ័យក្មេង»។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឡូក្អួនចុង បានអត្ថាធិប្បាយអំពីភាពឈ្លាសវៃរបស់ស៊ុនសេក ទុកត្រឹមតែពីរចំណុចធំៗតែប៉ុណ្ណោះគឺៈ

១/ ពេលដែលស៊ុនសេក វាយសម្រុកចូលទៅបង្ក្រាបសត្រូវ នៅឯក្នុងស្រុកកាំងតាំង ស៊ុនសេកត្រូវគ្រាប់ធ្នូបាញ់ចំជើង ទើបបន្លំធ្វើពុតជាស្លាប់ផ្សព្វផ្សាយព័ត៌មានបោកបញ្ឆោតពួកស៊ីឡេង ឲ្យបានចិត្ត ដើម្បីឲ្យពួកគេលើកទ័ពចូលបន្ទាយរបស់ខ្លួនតែដុយទៅវិញស៊ុនសេក បានបង្កប់កងទ័ពរង់ចាំជាស្រេច ពេលដែលពួកស៊ីឡេង សម្រុកចូល មកដល់ក៏ត្រូវកងទ័ពរបស់ស៊ុនសេក រឹបអូសយកបន្ទាយរបស់ស៊ីឡេង បានយ៉ាងស្រួល។

២/ ក្រោយពីការវាយយកបន្ទាយរបស់ស៊ីឡេង បានមកហើយនោះ ស៊ុនសេកបានរៀបចំផែនការបោកបញ្ឆោតអងឡង ថានឹងលើកកងទ័ពទៅរឹបអូសយកស្រុកចែតក។ ពេលនោះអងឡង បានបញ្ជាឲ្យជិវចៀត និងងៀមពែកហ លើកកងទ័ពចេញទៅទប់ទល់។ ពេលដែលចេញពីស្រុកហួយខេ បានមិនឆ្ងាយប៉ុន្មានផងក៏ត្រូវទ័ពរបស់ស៊ុនសេក ដែលពួនស្ទាក់ចាំនៅមាត់ព្រៃវាយសង្គ្រុបរត់យកតែប្រាសអាយុ។

ទិន្នន័យទាំងអស់នេះបង្ហាញឲ្យឃើញថា ស៊ុនសេកគឺជាមេទ័ពដែលមានផែនការទូលំទូលាយ សមគួរទទួលបានការលើកតំណែងឲ្យ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ធ្វើជាមនុស្សអច្ឆរិយផ្នែកយោធា។ នៅក្នុងប្រវត្តិសាស្ត្រចិនបានកត់ត្រាទុកមកថាស៊ុនកៀន បានស្លាប់នៅក្នុំសៀងសាន កាលនោះស៊ុនសេកទើបតែអាយុត្រឹម១៧ឆ្នាំប៉ុណ្ណោះ។ គេគិតចង់សងសឹកជូនលោកឪពុកទើបបានសម្រេចចិត្តបោះបង់ចោលផ្ទះសម្បែង និងស្រុកកំណើតមកចុះឈ្មោះចូលធ្វើទ័ពជាមួយអួនស៊ុត។

ស៊ុនសេកគឺជាមនុស្សមានសតិបញ្ញាឈ្លាសឆ្លាតលើសមនុស្សទូទៅ ធ្វើចម្បាំងឈ្នះមកជាច្រើនលើករហូតដល់ថ្នាក់អួនស៊ុតស្រមៃថា «បើយើងមានកូនដូចជាស៊ុនសេក ប្រហែលជាយើងស្លាប់បិទភ្នែកជិតហើយ» ប៉ុន្តែអួនស៊ុត បណ្តោយឲ្យភាពលោភលន់និងអំណាចបិទបាំងចិត្តងងឹតមើលអ្វីមិនឃើញទើបបានជាមិនព្រមប្រើស៊ុនសេក។

ដំបូងឡើយ អួនស៊ុតសន្យាថា ប្រសិនបើស៊ុនសេក ច្បាំងឈ្នះនឹងតែងតាំងឲ្យធ្វើចៅហ្វាយស្រុកជិវចៀង ប៉ុន្តែពេលយកជាការពិតអួនស៊ុត បែរជាលេបសម្តីខ្លួនឯង ផ្លាស់ប្តូរចិត្តពាក់កណ្តាលទី ប្រគល់អំណាចឲ្យតាន់គី ដែលជាអ្នកស្រុកតាន់យ៉ុង ធ្វើជាចៅហ្វាយស្រុកទៅវិញ។

ក្រោយមកទៀតអួនស៊ុតឲ្យស៊ុនសេកទៅវាយយកស្រុកឡូកាំងហើយសន្យាថា បើធ្វើការបានសម្រេចនឹងតែងតាំងឲ្យធ្វើជាចៅហ្វាយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ស្រុកតែនៅពេលដែលស៊ុនសេក វាយដណ្ដើមយកបាន អួនស៊ុតបែរជាហៅស៊ុនសេក ត្រលប់មកវិញ ហើយបានចាត់ឲ្យឡៅស៊ី ដែលជាកូនចៅចាស់របស់ខ្លួនទៅគ្រប់គ្រងស្រុកឡូកាំងជំនួស។ រឿងនេះបានបង្កើតនូវភាពឈឺចាប់ដល់ស៊ុនសេកយ៉ាងខ្លាំង។

ចាប់តាំងពីពេលនោះមក ស៊ុនសេកក៏ចាប់ផ្ដើមនឹកគិតឃើញថារាជវង្សហាន ទន់ខ្សោយរហូតទាល់តែគ្មានមធ្យោបាយនឹងអាចជួយស្រោចស្រង់សាឡើងវិញ ហើយពេលនេះអួនស៊ុត រឹបអូសយកដែនដីភាគខាងជើងចំណែកឯចូចូ ក៏រឹបអូសយកដែនដីភាគខាងត្បូង។ ម្នាក់ៗប្រកួតប្រជែងដណ្ដើមតែអំណាចគ្នា។ កាលដែលខ្លួនមករួមរស់នៅជានឹងមួយអួនស៊ុត តើមានប្រយោជន៍អ្វីទៅ? ហេតុដូច្នេះទើបស៊ុនសេកសម្រេចចិត្តដកខ្លួនចាកចេញពីអួនស៊ុត ធ្វើសង្គ្រាមរឹបអូសយកស្រុកផ្សេងៗ និងពង្រីកឥទ្ធិពលទៅផ្នែកដែនដីកាំងតាំង ដែលកំពុងតែមានសភាពទន់ខ្សោយ។

នៅក្នុង គ.ស.១៩៥ ស៊ុនសេកបានលើកទ័ពជាងមួយពាន់នាក់ រួមទាំងមានទ័ពសេះ៧០ ក្បាល ឆ្លងកាត់នូវទន្លេយ៉ែងស៊ីកៀង សម្រុកធ្វើសង្គ្រាមយ៉ាងលំបាកលំបិនរហូតដល់វាយឡៅអ៊ីវ បណ្ដេញអង់ឡុង និងសម្លាប់ខៅកង ពង្រីកកម្លាំងទ័ពកាន់តែខ្លាំងរឹងមាំឡើងជារឿយៗ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទីបំផុតក៏អាចរឹបអូសយកស្រុកតាំងង៉ ហួយខេ និងស្រុកផ្សេងៗរួមទាំងអស់មាន៦ស្រុក។ ស៊ុនសេកបានបង្កើតរដ្ឋអំណាចរបស់ខ្លួនឡើងនៅម្តុំស្រុកកាំងតាំងចាប់តាំងពីពេលនោះមក។

លទ្ធផលទាំងនេះ ចាត់ទុកថាវាមានភាពអស្ចារ្យជាងស៊ុនកៀន ដែលជាឪពុករបស់សិបដង។ នៅក្នុងសម័យដែលស៊ុនកៀន នៅមានជីវិតនៅឡើយថៅហ្វាយខេត្តស្រុកផ្សេងៗបានរួមគ្នាលើកទ័ពទៅវាយតាំងតុ។ កាលនោះស៊ុនកៀន ធ្លាប់រឹបអូសបានស្រុកឡាំយ៉ុង ហើយក្នុងពេលនោះស៊ុនកៀនមានកងទ័ពរាប់ម៉ឺននាក់ប្រសិនបើស៊ុនកៀនយល់ស្ថានការណ៍ ហ៊ានរឹបអូសយកស្រុកឡាំយ៉ុង មកធ្វើជាទីតាំងរបស់ខ្លួន ហើយបានពង្រីកកម្លាំងទ័ព និងអំណាចដើម្បីវាយយកស្រុកឡុកអៀង ប្រហែលជាមានលទ្ធផលច្រើនជាងនេះរាប់រយដង។

ផ្ទុយទៅវិញ ស៊ុនកៀនបែរជាប្រគល់ស្រុកឡាំយ៉ុង ឲ្យអ្នួនស៊ុតដោយងាយៗធ្វើឲ្យខ្លួនឯងគ្មានទីតាំងច្បាស់លាស់។ ក្រោយមកទៀត ប្រសិនបើស៊ុនកៀនលើកទ័ពទៅវាយយកស្រុកឡុកអៀងក៏បាន ប៉ុន្តែដោយសារស៊ុនកៀន មិនស្តាប់បង្គាប់ទីប្រឹក្សាទើបធ្លាក់ទៅក្នុងដៃរបស់អ្នកដទៃបាត់អស់។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចំណែកស៊ុនសេក វិញ ថ្វីបើនៅក្មេងជាងក៏ដោយតែជាមនុស្ស មានចក្ខុវិស័យខ្ពស់ប្រកបដោយបញ្ញាវៃឆ្លាតអាចយល់នូវហេតុការណ៍ បានគ្រប់ជ្រុងជ្រោយ បានឆ្លៀតឱកាសនៅពេលដែលចូចូ អួនសៀវ អួនស៊ុត និងឡៅពី។ល។ ដណ្តើមអំណាចគ្នាឲ្យទាល់តែវឹកវរ ស៊ុនសេក ក៏បោះពួយសំដៅទៅស្រុកកាំងតាំង ដែលមានទន្លេយ៉ាងស៊ីកៀង ជា កំពែងការពារតាមបែបធម្មជាតិ និងបរិបូរណ៍ទៅដោយទ្រព្យសម្បត្តិ ហូរហៀរតែខ្សោយអំណាច។ នៅទីបំផុតស៊ុនសេករឹបអូសយកស្រុក កាំងតាំងបានសម្រេចជាស្ថាពរ ហើយបានបង្កើតឲ្យជាស្ថានការណ៍ថ្មី ដែលមហាអំណាចទាំងបីប្រឆាំងគ្នានិងដណ្តើមយកទឹកដីគ្នាទៅវិញទៅ មកយ៉ាងសាហាវដែលគេហៅថា«សង្គ្រាមសាមកុក»។

រឿងនេះសបញ្ជាក់ឲ្យឃើញថាប្រសិនបើស៊ុនសេក មិនមែនជា អ្នកដែលជំនាញផ្នែកខាងយោធាទេនោះប្រហែលជាគ្មានចក្ខុវិស័យល្អ បែបនេះទេ។

នៅក្នុងសង្គ្រាមបង្ក្រាបឥទ្ធិពលផ្សេងៗក្នុងដែនដីកាំងតាំងដើម្បី បង្កើតសុខសន្តិភាពនោះ។ ស៊ុនសេកបានបង្ហាញនូវភាពអស្ចារ្យរបស់ ខ្លួនក្នុងការដឹកនាំកងទ័ព ប្រើយុទ្ធសាស្ត្រយ៉ាងស្ទាត់ជំនាញ និងសម្លឹង មើលហេតុការណ៍បានគ្រប់ជ្រុងជ្រោយល្អ ដូចយ៉ាងក្រោយពីវាយលុក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឡៀអ៊ិវ បែកខ្ចាត់ខ្ចាយហើយ ពួកចោរតូចធំនៅក្នុងតំបន់នៅតែចេញមកបង្ករឿងជាញឹកញាប់ទើបប្រជាពលរដ្ឋស្នើសុំឲ្យស៊ុនសេក បោសសម្អាតពួកចោរទាំងនោះដើម្បីឲ្យមានសុខសន្តិភាព។ ស៊ុនសេកវិភាគស្ថានការណ៍របស់សត្រូវយ៉ាងហ្មត់ចត់ ហើយក៏ឃើញថាពួកចោរគ្មានឧត្តមគតិអ្វីអស្ចារ្យទេ ចង់ចាប់ពួកគេទាំងនោះពេលណាក៏បាន រង់ចាំបង្ក្រាបស្រុកហួយខេ បានជាមុនសិន ពេលត្រលប់មកវិញទើបបោសសម្អាតពួកចោរសម្រែទាំងអស់នោះឲ្យអស់តែម្តង។

ដូច្នេះហើយទើបស៊ុនសេក លើកទ័ពសម្រុកចូលទៅភាគខាងត្បូងហើយធ្វើការរឹបអូសយកស្រុកកាំងតាំង និងស្រុកហួយខេ ហើយទើបវិលត្រលប់មកបង្ក្រាបពួកចោរដោយចាប់ងៀមប៉ែកហ ដែលជាស្តេចត្រាញ់នោះមកកាត់ក្បាលចោល។ ពួកចោរក្រុមដទៃទៀតក៏នាំគ្នារំលាយក្រុមបាត់អស់ទៅបានធ្វើឲ្យស៊ុនសេក ទទួលជ័យជម្នះយ៉ាងស្រួលបំផុត។

ស៊ុនសេក ជាអ្នកជំនាញខាងផ្នែកយោធា នៅត្រង់ចំណុចដែលចេះវិភាគ និងដៅស្ថានការណ៍ឲ្យបានគ្រប់ផ្នែកទាំងអស់ និងអាចមើលទៅហេតុការណ៍គ្រប់ជ្រុងជ្រោយ។ បន្ទាប់មកទើបរៀបចំផែនការចាត់ការរាល់បញ្ហា។ ទិន្នន័យទាំងនេះរឿងនិទានសាមកុកមិនបានពិពណ៌នា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទុកទេ ឡូក្កួនចុងបានអធិប្បាយត្រឹមតែឈុតឆាករបស់ស៊ុនសេក ទុកថា ស៊ុនសេកជាអ្នកជំនាញផ្នែកយោធាដែលមានចក្ខុវិស័យវែងឆ្ងាយ ដូចយ៉ាងនៅក្នុងឆាកដែលស៊ុនសេក សម្រេចចិត្តលើកទ័ពទៅបោះទីតាំងនៅស្រុកកាំងតាំងនោះ។ ស៊ុនសេកគ្មានកងទ័ពទាល់តែសោះ ទើបយកត្រាប្រចាំផែនដីរបស់ស៊ុនកៀន ដែលបានបន្សល់ទុកឲ្យនោះ យកទៅបញ្ចាំជាមួយនឹងអួនស៊ុត សុំខ្ចីកងទ័ពបីពាន់នាក់ និងសេះប្រាំរយក្បាលមកកវែកកឆ្នាំង។ នៅក្នុងខ្សែរភ្នែករបស់ស៊ុនសេក ត្រាប្រចាំផែនដីគ្រាន់តែជាវត្ថុមួយដែលគ្មានតម្លៃគ្មានឥទ្ធិពលនិងមិនមែនជាវត្ថុវិសេសពិតប្រាកដស្អីនោះទេ។ ផ្ទុយគ្នាពីស៊ុនកៀនដែលជាឪពុករើសបានត្រាប្រចាំផែនដីមកដោយចៃដន្យ តែស្រមើស្រមៃថាត្រានេះនឹងធ្វើឲ្យខ្លួនក្លាយទៅជាព្រះរាជា។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ១០

# យុទ្ធសាស្ត្រ
# ស្រែកខាងឆ្វេង
# តែទៅវាយ
# ខាងស្តាំ
# ឬ
# វាយពីលិច
# បញ្ឆោតពីកេត

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ក្នុងរឿងនិទានសាមកុក  កាសៀងត្រូវបានចាត់ទុកជាទីប្រឹក្សា ដ៏អស្ចារ្យមួយរូបក្នុងសម័យដែលកាសៀង មិនទាន់បានមករស់នៅជាមួយចូចូ នៅឡើយ។  កាសៀងធ្លាប់រៀបចំផែនការល្អៗដណ្ដើមយកជ័យជម្នះក្នុងការធ្វើសង្គ្រាមជាច្រើនលើកច្រើនសា។

នៅក្នុងវគ្គទី១៧របស់រឿងនិទានសាមកុក  បាននិយាយពីគំនិតដ៏ឈ្លាសវៃរបស់កាសៀង ដែលអាចយល់ឧបាយកលរបស់ចូចូ បានទើបរៀបចំផែនការធ្វើឲ្យទ័ពរបស់ចូចូ ចាញ់យ៉ាងដំណំ។  ខ្លឹមសារនៅក្នុងវគ្គនេះផ្ដល់ភាពជក់ចិត្តដល់មិត្តអ្នកអានយ៉ាងច្រើនដូចតទៅនេះ៖

នៅក្នុងរដូវប្រាំងឆ្នាំ១៩៨គ.ស. ចូចូបានអាងព្រះរាជឱង្ការរបស់ព្រះចៅអធិរាជ  បានលើកទ័ពទៅបង្ក្រាបស្រុកឡាំយ៉ុង  របស់ទៀវស៊ិវជាលើកទីពីរ។  ទៀវស៊ិវ  ប្រយុទ្ធមិនឈ្នះចូចូ  ទើបរត់គេចចូលទៅក្នុងស្រុកឡាំយ៉ុងវិញហើយការពារស្រុកឡាំយ៉ុង យ៉ាងរឹងមាំបំផុត។

ចូចូ វាយស្រុកឡាំយ៉ុង មិនបែកទើបជិះសេះក្រវែលស្រុកជុំវិញ ៣ថ្ងៃពេញហើយក៏សង្កេតឃើញថា ឥដ្ឋដែលប្រើប្រាស់កសាងកំពែងនៅទិសអាគ្នេយ៍មានពណ៌ថ្មីចាស់ខុសប្លែកពីគ្នា និងបាក់បែកអស់មួយចំនួនធំ។  ចូចូក៏នឹកឃើញឧបាយកលមួយហើយបញ្ជាទាហានប្រមូលស្បៀងអាហារនិងកម្លាំងទ័ពទៅបោះទីតាំងនៅទិសពាយ័ព្យធ្វើហាក់បី

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ដូចជាចង់សម្រុកចូលវាយយកស្រុកពីផ្នែកនោះ តែការពិតលួចបញ្ជាទ័ពឲ្យត្រៀមញញួររួចជាស្រេចដើម្បីនឹងទៅវាយបំបែកកំពែង។

ចូចូឃើញថា កំពែងនៅឯទិសអាគ្នេយ៍មានចំណុចខ្វះខាត និងជាចំណុចដែលកងទ័ពរបស់ខ្លួន អាចបុករុកចូលក្រុងបានយ៉ាងស្រួល ប៉ុន្តែមិនដឹងថា ខណៈពេលដែលចូចូ ដើរមើលជុំវិញស្រុកពាថ្ងៃពេញនោះ កាសៀងក៏សង្កេតមើលសកម្មភាពចូចូពាថ្ងៃពេញៗដូចគ្នា។

កាសៀងមើលឧបាយកលរបស់ចូចូ ដឹងបានហេតុដូច្នេះហើយទើបប្រាប់ឧបាយកលទៅដល់ទៀវស៊ិវ ថាសូមឲ្យប្រើឧបាយ«កលត្រួតលើកល» ដោយការប្រមូលកងទ័ពខ្លាំងៗឲ្យទៅបង្កប់ខ្លួននៅតាមផ្ទះនៅទិសអាគ្នេយ៍។ បន្ទាប់មកឲ្យអ្នកភូមិមកបន្លំខ្លួនធ្វើជាកងទ័ព ហើយឲ្យឡើងទៅដើរទៅដើរមកនៅលើកំពែងនៅឯទិសពាយ័ព្យនោះព្រមទាំងលើកទង់ស្រែកហ៊ោធ្វើដូចជាត្រៀមខ្លួនប្រយុទ្ធ។

ចូចូឃើញដូច្នេះសើចហើយនិយាយថា «ឯងចាញ់ឧបាយកលយើងហើយ!!!»នៅពេលថ្ងៃចូចូ បញ្ជាឲ្យកងទ័ពទៅជួបជុំគ្នាស្រែកហ៊ោនៅទិសពាយ័ព្យ ដល់ពេលយប់បែរជាលួចនាំទាហានខ្លាំងៗ ឡើងទៅកំពែងចូលទៅក្នុងស្រុកនៅទិសអាគ្នេយ៍។ នៅទីបំផុតទាហានរបស់ចូចូក៏បានធ្លាក់ចូលទៅក្នុងអន្ទាក់របស់កាសៀង ហើយត្រូវបានវាយបែក

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

វត់ខ្វាត់ខ្វាយនិងមានទាហានស្លាប់ជាងប្រាំម៉ឺននាក់។ ឧបាយកលដែលចូចូគិតនឹងប្រើវាយលុកស្រុកឡាំយ៉ុង គឺ «បញ្ឆោតពីខាងឆ្វេងទៅវាយនៅខាងស្តាំ» គឺជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រទាំងឡាយដើម្បីនឹងបង្ក្រាបពួកសត្រូវ។

គោលសំខាន់របស់យុទ្ធសាស្ត្រនេះ គឺត្រូវបង្កើតនូវឈុតឆាកបន្លំភ្នែកសត្រូវធ្វើឲ្យពួកវាវង្វេងវង្វាន់។ ជាទូទៅ អ្នកដែលប្រើប្រាស់ឧបាយកលនេះ ត្រូវមានភាពឈ្លាសវៃរហ័សរហួនពោលគឺ បន្តិចវាយលុកពីខាងស្តាំបន្តិចវាយលុកពីខាងឆ្វេង ធ្វើឥរិយាបថហាក់ដូចជាចង់វាយប៉ុន្តែមិនវាយ បង្ហាញនូវអាកប្បកិរិយាថា មិនចង់វាយប៉ុន្តែបែរជាវាយវិញ។

នៅក្នុងប្រវត្តិសាស្ត្រចិនមានសង្គ្រាមជាច្រើនលើកដែលគេនាំយកយុទ្ធសាស្ត្រនេះយកមកប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព តែចំណុចដែលគួរប្រុងប្រយ័ត្ននោះគឺថាមិនគួរនាំយកទ្រឹស្តីនេះមកប្រើទាំងស្រុងនោះទេព្រោះនឹងធ្វើឲ្យពួកសត្រូវចាប់ចំណុច និងយល់ផែនការរបស់យើង។

គន្លឹះដ៏សំខាន់នៅក្នុងការមើលផែនការនេះឲ្យយល់នោះ គឺត្រូវស្គាល់ខ្លួនយើងនិងពួកសត្រូវ។ អ្នកប្រាជ្ញបុរាណលោកបានពោលថា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

«កើតមកជាមនុស្សត្រូវតែដឹងខ្លួនឯងមានរបួសត្រង់ណាខ្លះ» ចំណែកឯបុគ្គលមានបញ្ញាក៏មាននៅក្នុងវិស័យប្រហាក់ប្រហែលនេះដែរ។ ដូច្នេះក្នុងឋានៈជាមេដឹកនាំ ឬជាមេបញ្ជាការ ត្រូវចេះយកចិត្តរបស់អ្នកដទៃមកដាក់នៅក្នុងចិត្តរបស់យើង។

ពេលដែលយើងចង់វាយលុកសត្រូវ យើងមិនត្រូវសម្រុកចូលវាយលុកត្រង់ចំណុចរឹងមាំរបស់ពួកវាទេ ពួកវាក៏គិតដូចយើងអីចឹង។ ដូច្នេះហើយទើបត្រូវវិភាគផែនការរបស់ពួកសត្រូវ ដោយការចាប់ផ្ដើមពីចំណុចខ្សោយរបស់យើងជាមុនសិន។ នៅពេលដែលសរុបចំណុចខ្សោយរបស់យើងបានហើយ យើងនឹងបានទទួលចម្លើយទាក់ទងជាមួយផែនការរបស់សត្រូវបានយ៉ាងត្រឹមត្រូវ។

ការធ្វើសង្គ្រាមនៅស្រុកឡាំយ៉ុងលើកនេះ កាសៀងដឹងច្បាស់ថាចំណុចខ្សោយរបស់ខ្លួនគឺស្ថិតនៅត្រង់កំពែងទិសអាគ្នេយ៍។ ខណៈពេលដែលចូឆូ ដើរត្រួតពិនិត្យជុំវិញស្រុកចំនួន៣ថ្ងៃពេញៗ ចូឆូក៏មិនមែនជាមនុស្សភ្នែកខ្វាក់ មើលមិនឃើញនូវចំណុចខ្សោយនោះដែរ។ គ្រាន់តែចូឆូធ្វើអាកប្បកិរិយាហាក់បីដូចជាសម្រុកចូលទៅទិសពាយ័ព្យប្រសិនបើសម្រុកចូលមកតាមទិសនេះពិតមែននោះ វាប្រៀបបីដូចជារត់មកបុកកាំបិតប៉ុងតោគឺរត់មករកសេចក្ដីស្លាប់ដូច្នោះដែរ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

មនុស្សដែលឆ្លាតវៃដូចជារូបចូឆូ មិនងាយនឹងនាំទ័ពរបស់ខ្លួនឲ្យមកស្លាប់បែបនេះទេ។ ដូច្នេះហើយទើបបានកាសៀងអាចយល់នូវផែនការរបស់ចូឆូ ថែមទាំងបានដឹងច្បាស់ថា ចូឆូប្រាកដជាប្រើផែនការ «បញ្ឆោតពីឆ្វេងតែទៅវាយខាងស្តាំ»ជាក់ជាពុំខានឡើយ។ នេះជាភាពឈ្លាសវៃរបស់កាសៀង និងជាការធ្វេសប្រហែសរបស់ចូឆូ។

នៅក្នុងប្រវត្តិសាស្ត្រមានមេទ័ពដែលអង់អាចក្លាហានដូចជាចូឆូច្រើនសន្ធឹកសន្ធាប់ ហើយពួកគេតែងតែទទួលបរាជ័យដោយសារការឈ្លក់វង្វេងនឹងខ្លួនឯងគិតថា គំនិតរបស់ខ្លួនប្រសើរជាងអ្នកដទៃ ទើបគិតតែពីដាក់ផែនការតាមតែអំពើចិត្ត ដោយមិនវិភាគលើគូបដិបក្ស។ ទីបំផុតក៏ត្រូវពួកសត្រូវបោកបញ្ឆោតរហូតទាល់តែអស់តម្រិះ ផ្លាស់ប្តូរពីសភាពអ្នកមានប្រៀបលើគេទៅជាអ្នកចាញ់ប្រៀបគេទៅវិញ។

ឧបាយកល «បញ្ឆោតពីខាងឆ្វេងតែទៅវាយខាងស្តាំ»នេះគឺដូចគ្នានឹងឧបាយកលដទៃៗដែរ។ ប្រសិនបើត្រូវពួកសត្រូវចាប់ចំណុចបាន ហើយយើងមានតែផ្លូវមួយគត់គឺធ្លាក់ចូលក្នុងអន្ទាក់របស់ពួកសត្រូវ។ ចំណែកឯការប្រើប្រាស់នូវឧបាយ «កលត្រួតពីលើកល» របស់សត្រូវនោះ អាចនិយាយបានថា ជាគ្រឹះដ៏សំខាន់ក្នុងការឆ្លើយតប ឬការវាយបកទៅលើឧបាយកលរាប់រយជំពូក វាជាចំណុចកំពូលនៃឧបាយកល

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដែលគេប្រើសម្រាប់ទប់ទល់នឹងល្បិចបោកបញ្ឆោតរបស់សត្រូវ គ្រប់បែបយ៉ាងដ៏មានប្រសិទ្ធភាព។

អត្ថប្រយោជន៍នៃ «ផែនការត្រួតពីលើផែនការរបស់សត្រូវ» គឺត្រូវអនុវត្តទៅតាមចេតនារបស់ពួកសត្រូវ។ ការប្រើប្រាស់នូវផែនការនេះគ្មានទម្រង់ទ្រាយច្បាស់លាស់ទេតែត្រូវដាក់ឲ្យស្របទៅតាមផែនការរបស់ពួកសត្រូវនិងផ្លាស់ប្តូរឲ្យទាន់ស្ថានការណ៍។ ក្នុងពេលអនុវត្តវាត្រូវធ្វើពុតជាចាញ់កលឧបាយរបស់ពួកវាគឺដើម្បីបិទបាំងគោលបំណងពិតប្រាកដរបស់យើង។

ដូចយ៉ាងនៅពេលដែលចូឆូ កំពុងតែបញ្ឆោតកាសៀង ដោយការបង្ហាញឥរិយាបថ បីដូចជាចង់សម្រុកចូលវាយលុកយកស្រុកនៅទិសពាយ័ព្យនោះ កាសៀងទប់ទល់នូវចេតនារបស់ចូឆូ ដោយការបន្លំធ្វើជាត្រៀមកងទ័ពការពារនៅទិសពាយ័ព្យយ៉ាងច្រើន តែផ្ទុយទៅវិញកាសៀងបែរជាត្រៀមកម្លាំងពិតប្រាកដនៅទិសអាគ្នេយ៍។ ប្រសិនបើកាសៀងមិនបង្កើតឈុតឆាកបំភាន់ភ្នែកនៅទិសពាយ័ព្យ ដើម្បីបោកបញ្ឆោតចូឆូទេ ចូឆូក៏នឹងផ្លាស់ប្តូរនូវផែនការថ្មី។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ការប្រើ «ផែនការត្រួតពីលើផែនការ» របស់សត្រូវជាដំបូងគឺត្រូវសម្លឹងមើលគោលបំណងរបស់សត្រូវ និងត្រូវយល់ផែនការរបស់ពួកវាឲ្យបានត្រឹមត្រូវ។ បើពុំដូច្នោះទេ នឹងប្រើប្រាស់ផែនការនេះមិនបាន។ នេះឆ្លុះបញ្ចាំងឲ្យឃើញច្បាស់ថាការយល់ផែនការ និងការដាក់ផែនការទប់ទល់ទៅលើពួកសត្រូវជាគូនឹងគ្នា។

ប្រសិនបើអ្នកដឹកនាំ ឬមេបញ្ជាការគិតតែពីវិភាគពិចារណាថាតើត្រូវប្រើនូវផែនការអ្វីល្អទៅហ្ន៎! និងមិនបានគិតចាប់អារម្មណ៍លើគូបដិបក្សថា ពួកគេប្រើផែនការបែបណានោះ រឿងបែបនេះបើទោះជាមានទីប្រឹក្សាល្អៗចាំផ្ដល់មតិនៅក្បែរខ្លួនយ៉ាងណាក៏ដោយចុះ ក៏នៅតែបរាជ័យដែរ។

«ដឹងគេ

ដឹងយើង

ច្បាំង១០០ដង

នឹងបានឈ្នះ១០០ដង...»

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ១១

# សិល្បៈ

# ក្នុងការ

# ដេញប្រយុទ្ធ

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ស៊ុនជឺបានពោលថា«កុំរារាំងឬដេញតាមប្រយុទ្ធកងទ័ព
ដែលដកថយត្រលប់ទៅវិញ» ។

ពាក្យសម្ដីខាងលើនេះមានអ្នកប្រាជ្ញខ្លះវិភាគថា វាមានលក្ខណៈផ្ទុយគ្នាយ៉ាងស្រឡះពីយុទ្ធសាស្ត្រនៃគម្រាពិជ័យសង្គ្រាមដទៃៗ ដែលមានចែងទុកថា «ពេលដែល សត្រូវបែកទ័ពត្រូវតែដេញតាមកម្ទេចឲ្យផុតពូជ»។ ប៉ុន្តែបើតាមការពិតវិញនោះ យើងគួរតែដឹងថាយុទ្ធសាស្ត្រពិជ័យសង្គ្រាម គឺជាយុទ្ធសាស្ត្រដែលកើតមកពីលក្ខខណ្ឌពិតប្រាកដមួយនៅក្នុងផ្នែកប្រវត្តិសាស្ត្រ។ បើចេះតែវិភាគថា ទ្រឹស្ដីនេះត្រឹមត្រូវទ្រឹស្ដីនោះមិនត្រឹមត្រូវក៏នឹងក្លាយជាការសិក្សាបែបសើៗលំៗ ដែលពុំមានភាពស៊ីជម្រៅទាល់តែសោះឡើយ។

មានអ្នកជំនាញផ្នែកយោធាម្នាក់និយាយថា ប្រសិនសត្រូវដកទ័ពថយដោយគ្មានរបៀបវិន័យត្រូវតែដេញតាមប្រយុទ្ធភ្លាមៗ។ សួរថាតើយើងអាចដឹងវាបានដោយវិធីណាថា សត្រូវដែលថយយ៉ាងមានរបៀបឬគ្មានរបៀបនោះ?

នៅក្នុងសម័យបុរាណបានចែងទុកថាប្រសិនបើឃើញរថ(យានជំនិះ) ចម្បាំងបើកបរច្របូកច្របល់និងឃើញដងទង់មានភាពរញ៉េរញ៉ៃចូរប្រញាប់រត់ដេញតាមប្រយុទ្ធ។ ប៉ុន្តែប្រសិនបើកងទ័ពថ្មើរជើងគ្មានរទេះចម្បាំង គ្មានសេះវិញនោះ តើយើងអាចសង្កេតបានដោយវិធីណា?

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ករណីនេះអ្នកជំនាញខាងយោធាប្រាប់ថាត្រូវពឹងផ្អែកទៅលើការវិភាគស្ថានការណ៍របស់មេបញ្ជាការជាមុនសិន។

នៅក្នុងវគ្គទី១៨ របស់រឿងនិទានសាមកុក មានការកត់ត្រាទុកពីក្បួនវិភាគបច្ចាមិត្តរបស់កាសៀងដូចតទៅ៖

បន្ទាប់ពី ទៀវស៊ីវបានធ្វើចម្បាំងឈ្នះចូចូ នៅក្នុងស្រុកឡាំយ៉ុង ហើយនោះ ទៀវស៊ីវ ក៏ណាត់ជួបនឹងឡៅពៀវ ដែលជាចៅហ្វាយស្រុកកេងជិវ ឲ្យលើកទ័ពមកជួយវាយកម្ទេចកងទ័ពរបស់ចូចូ តែកាសៀងបានហាមឃាត់ថា «លោកមិនគួរនឹងលើកទ័ពដេញតាមនៅក្នុងពេលនេះទេបើលោកលើកកងទ័ពទៅ លោកនឹងត្រូវកងទ័ពរបស់ចូចូ វាយបែកទ័ពនិងរត់ខ្ចាត់ខ្ចាយត្រលប់មកវិញយ៉ាងពិតប្រាកដ»។

ឡៅពៀវ មិនព្រមស្តាប់បង្គាប់របស់កាសៀងហើយនិយាយថា «ប្រសិនបើមិនដេញតាមវាយនៅក្នុងពេលនេះក៏នឹងបាត់បង់ឱកាសល្អទទេៗ»។

ឡៅពៀវ បបួលទៀវស៊ីវ លើកទ័ពជាងមួយម៉ឺននាក់ដេញតាមកម្ទេចចូចូ ឲ្យក្លាយទៅជាជេះទើបអស់ចិត្តក្តៅ។ ឡៅពៀវ និងទៀវស៊ីវ ដឹកនាំក្បួនទ័ពចេញទៅបានត្រឹមតែ៥គីឡូប៉ុណ្ណោះ ក៏បានប៉ះទង្គិចគ្នាជាមួយកងទ័ពជួរក្រោយរបស់ចូចូ។ កងទ័ពរបស់ចូចូ ចូលប្រយុទ្ធយ៉ាង

www.facebook.com/7khmer
Fb page : Entertainment And Knowledge

អង់អាចក្លាហាន។ ទីបំផុតក៏វាយកងទ័ពរបស់ទៀវស៊ុីវ និងឡេវពៀវ បែកខ្ចាត់ខ្ចាយរត់យកតែប្រាសអាយុ។

នៅពេលត្រលប់មកដល់ក្រុងវិញ ទៀវស៊ីវនិយាយជាមួយនឹងកាសៀង ថាដោយសារខ្ញុំមិនស្ដាប់បង្គាប់លោកទើបត្រូវទទួលបរាជ័យបែបនេះប៉ុន្ដែកាសៀង បែរជានិយាយណែនាំថា «ឥឡូវនេះលោកគួរតែប្រញាប់លើកទ័ពដេញតាមចូចូ ម្ដងទៀត លើកនេះខ្ញុំធានាថាលោកនឹងឈ្នះ»។

ទៀវស៊ីវ និងឡេវពៀវ ម្នាក់ៗនិយាយទាំងភ័យថា «ពេលនេះយើងខាតបង់អស់ទ័ពជាច្រើននាក់ តើនឹងមានកងទ័ពមកពីណាដើម្បីយកទៅប្រយុទ្ធជាមួយនឹងគេ?»។

កាសៀងនិយាយថា«មានប៉ុន្មានទៅប៉ុណ្ណឹង ម្ដងនេះបើសិនជាលោកដេញតាមប្រយុទ្ធ ខ្ញុំហ៊ានធានាថា«លោកនឹងទទួលជ័យជម្នះបើលោកមិនឈ្នះទេ សូមលោកមកកាត់ក្បាលរបស់ខ្ញុំចុះ!»។

ទៀវស៊ីវជឿជាក់កាសៀង ប៉ុន្ដែឡេវពៀវនៅមានការសង្ស័យនៅឡើយទេ ទើបមិនព្រមលើកទ័ពទៅវាយ។ ទៀវស៊ីវបានលើកទ័ពដេញវាយចូចូ តែម្នាក់ឯង តែបែរជាអាចបង្ក្រាបកងទ័ពរបស់ចូចូ បានហើយអាចរឹបអូសយកបានសព្វាវុធយ៉ាងច្រើនសន្ធឹកសន្ធាប់ផងដែរ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បន្ទាប់ពីអានខ្លឹមសារក្នុងវគ្គនេះចប់ហើយមិត្តអ្នកអានប្រហែលជាមានការសង្ស័យថាតើហេតុអ្វីបានជាទៀវស៊ុវ និងឡៅពៀវលើកទ័ពដេញតាមចូឆូ លើកទីមួយ កាសៀងនិយាយជំទាស់ និងទស្សន៍ទាយថាបើចចេសលើកទ័ពដេញតាមនឹងត្រូវទទួលបរាជ័យ តែពេលដែលទៀវស៊ុវនិងឡៅពៀវ បរាជ័យហើយត្រលប់មកវិញ កាសៀងបែរទៅជាប្រាប់ថា ឲ្យប្រញាប់លើកទ័ពដែលបរាជ័យនោះដេញតាមចូឆូ ម្តងទៀត លើកនេះនឹងត្រូវឈ្នះយ៉ាងពិតប្រាកដហើយក្រោយមកក៏ទទួលបានជ័យជម្នះតាមការទស្សន៍ទាយរបស់កាសៀងមែន តើវាកើតឡើងដោយរបៀបណា?

ភាពអស្ចារ្យនៅក្នុងរឿងនេះសូម្បីតែទៀវស៊ុវដែលជាអ្នកលើកទ័ពទៅដោយខ្លួនឯង ក៏នៅប៉ាន់ស្មានមិនត្រូវដែរ។ ម្លោះហើយទើបមិនបាច់និយាយដល់ឡៅពៀវ នោះទេ គេមានការងឿងឆ្ងល់ពេញទំហឹងតែម្តង។ ក្រោយមកពេលមានឱកាសល្អទើបឡៅពៀវ សួរកាសៀងថាតើហេតុអ្វីបានជាលោកដឹងរឿងនេះច្បាស់ដូចថ្ងៃយ៉ាងនេះ?

កាសៀងបានអធិប្បាយថា ថ្វីបើលោកជាមេទ័ពជំនាញក្នុងការធ្វើសង្គ្រាមក៏ដោយ តែលោកមិនមែនជាដៃគូតស៊ូជាមួយចូឆូ ទេ។ បើទោះបីជាកងទ័ពរបស់ចូឆូ បរាជ័យទៅហើយក៏ដោយ ប៉ុន្តែខណៈពេល

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដែលដកថយចូចូ បានរៀបចំកម្លាំងកងទ័ពដែលរឹងមាំល្អៗទុកសម្រាប់ការពារការដេញតាមរបស់ពួកសត្រូវ។ បើទោះបីជាកងទ័ពរបស់យើងមានភាពក្លាហាន តែថ្វីដៃក៏មិនអាចទប់ទល់ជាមួយនឹងកងទ័ពរបស់ចូចូទេ។ ហេតុដូច្នោះហើយទើបខ្ញុំដឹងថាកងទ័ពរបស់លោកត្រូវចាញ់យ៉ាងដំណំពិតប្រាកដ។ រឿងបន្ទាប់មកទៀតគឺចូចូ បានដកកម្លាំងទ័ពយ៉ាងប្រញាប់ប្រញាល់សបញ្ជាក់ឲ្យឃើញថាវាត្រូវតែមានបញ្ហាអ្វីកើតឡើងនៅក្រុងហ៊ូតូហើយ។ ម្យ៉ាងវិញទៀតចូចូបានបង្ក្រាបកងទ័ពរបស់យើងហើយមានការធ្វេសប្រហែសពេលដែលលើកទ័ពត្រលប់ទៅវិញ ទើបខ្ញុំយល់ឃើញថា ការឆ្លៀតឱកាសនៅពេលដែលសត្រូវមានការធ្វេសប្រហែសនេះបើលើកទ័ពដេញតាមនឹងទទួលបានជ័យជម្នះ។

ឡេវពៀវនិងទៀវស៊ីវ ស្តាប់ការអធិប្បាយរបស់កាសៀង ដល់ថ្នាក់ចំហមាត់ឆ្ងល់។ ម្នាក់ៗនាំគ្នាកោតសរសើរបញ្ញាដ៏ឈ្លាសវៃរបស់កាឈៀងយ៉ាងខ្លាំង។ នេះធ្វើឲ្យយើងដឹងថាកាលដែលកាសៀងអាចវិភាគបញ្ហាបានត្រឹមត្រូវហាក់បីដូចជាមានភ្នែកទិព្វនោះ ក៏ព្រោះតែថាកាសៀងក្តាប់នូវចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួនឯង និងរបស់សត្រូវបានយ៉ាងច្បាស់នោះឯង។ មួយវិញទៀតកាសៀងចេះប៉ាន់ស្មានហេតុការណ៍បានគ្រប់ផ្នែកទាំងអស់ ហើយថែមទាំងអាចចេះទាញយក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គោលការណ៍ដើម្បីទទួលយកជោគជ័យបានទៀតផង។

ជាទូទៅ ការដកថយកម្លាំងទ័ពចាត់ទុកថាជាការចាញ់ប្រៀប។ ចំណែកឯការដេញតាមចាត់ទុកជាការមានប្រៀបលើពួកសត្រូវ។ មេបញ្ជាការកងទ័ពដែលគេមានបទពិសោធន៍រមែងដឹងច្បាស់ថាពេលដកថយត្រូវការពារផ្នែកខាងក្រោយឲ្យបានល្អ។ នេះគឺជាលក្ខខណ្ឌដែលមានប្រៀបបង្កប់ក្នុងលក្ខខណ្ឌដែលចាញ់ប្រៀប។

ឯប្រការមួយទៀត ភាគីដែលទទួលបានជ័យជម្នះហើយច្រើនតែមានការធ្វេសប្រហែសបានចិត្តឡើងចាង់នេះគឺលក្ខខណ្ឌដែលចាញ់ប្រៀបបង្កប់ក្នុងលក្ខខណ្ឌដែលមានប្រៀប។ ខណៈពេលដែលចូចូ ដកកងទ័ពថយនោះ កាសៀងដឹងច្បាស់ថា មេទ័ពស្ទាត់ជំនាញដូចជាចូចូត្រូវតែការពារផ្នែកខាងក្រោយបានយ៉ាងល្អ។ បើនៅតែចចេសលើកទ័ពដេញតាមមានសង្ឃឹមតែម្យ៉ាងគត់ គឺការបរាជ័យឬប្តូរសភាពពីអ្នកឈ្នះឲ្យបានមកជាអ្នកចាញ់វិញ។

កាសៀងក៏បានដឹងទៀតថា ស្ថានការណ៍នៅក្នុងសមរភូមិមានការប្រែប្រួលគ្រប់ពេលវេលា។ វិធីនេះអាចធ្វើបែបនេះបានតែវិនាទីបន្តមិនអាចធ្វើបែបនេះបានទេ។ រាល់ភាពចម្រូងចម្រាស សុទ្ធតែមានការប្រែប្រួលទៅតាមពេលវេលា និងលក្ខខណ្ឌផ្សេងៗគ្នា។ ដូច្នេះហើយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បន្ទាប់ពីការចាញ់សង្គ្រាមជាមួយចូឆូ នៅក្នុងការដេញតាមលើកទីមួយនោះ កាសៀងបានស្នើឲ្យទៀវស៊ីវ លើកទ័ពដេញតាមទ័ពរបស់ចូឆូដែលមានការធ្វេសប្រហែសជាលើកទីពីរ។ នៅទីបំផុតក៏អាចផ្លាស់ប្តូរស្ថានការណ៍ពីអ្នកចាញ់ក្លាយមកជាអ្នកឈ្នះវិញ។ នេះជាភាពឈ្លាសវៃក្នុងផ្នែកយោធារបស់កាសៀង។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ១២

# ព័ត៌មាន
# ក្លែងក្លាយ
# និងការវិភាគ
# ព័ត៌មានរបស់អ្នកដឹកនាំ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅក្នុងការធ្វើសង្គ្រាម ល្បិចកុហកបោកប្រាស់តែងតែបាននាំយកមកប្រើជានិច្ច។ ល្បិចនៃការកុហកបោកប្រាស់អាចចែកចេញជាពីរប្រភេទគឺៈ

*ប្រភេទទី១* បង្កើតហេតុការណ៍បន្លំធ្វើជាចង់វាយលុកឬបន្លំធ្វើជារំកិលកងទ័ពដែលជារឿយៗ ត្រូវបានចាត់ចូលក្នុងប្រភេទបោកប្រាស់ផ្នែកយុទ្ធវិធី។

*ប្រភេទទី២* ហៅថាកុហកបោកប្រាស់ផ្នែកព័ត៌មានគឺប្រកាសនូវព័ត៌មានដែលមិនពិតដើម្បីបញ្ឆោតសត្រូវឲ្យធ្លាក់ចូលក្នុងអន្ទាក់។

នៅក្នុងរឿងនិទានសាមកុក មានរឿងរ៉ាវនៃការប្រកាសព័ត៌មានដែលមិនពិតជាច្រើន ប៉ុន្តែឈុតឆាកដែលល្អបំផុតនោះ គឺនៅក្នុងវគ្គទី១៩ដែលនិយាយពីគាន់តេង ទៅបោកបញ្ឆោតលីប៉ូពាដងធ្វើឲ្យលីប៉ូបាត់ស្រុកចំនួន៣ក្នុងពេលតែមួយយប់សាច់រឿងមានដូចតទៅនេះគឺ៖

បន្ទាប់ពីចូឆូត្រូវបានទៀវស៊ីវ វាយឈ្នះជាលើកទី២នោះ ចូឆូក៏ប្រញាប់ប្រញាល់លើកកងទ័ពត្រលប់ទៅស្រុកហ៊ូតូ វិញដោយមិនព្រមឈប់សម្រាកសូម្បីបន្តិច។

អួនសៀវដឹងថា ចូឆូលើកទ័ពត្រលប់មកវិញ ហើយការដែលខ្លួនចង់រឹបអូសយកក្រុងហ៊ូតូ វាមិនងាយដូចជាការគិតទេនោះ។ ដូច្នេះហើយទើបដឹកនាំទ័ពឆ្ពោះទៅកាន់ស្រុកកងស៊ុនចាន វិញ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចូវបើចូចូ ក្រោធខឹងជាមួយនឹងអួនសៀវ ខ្លាំងប៉ុនណាក៏ដោយ តែក៏នៅស្តាប់តាមបង្គាប់របស់គុយកៃ និងស៊ុនហុកដែលជាទីប្រឹក្សា។ គុយកៃ និងស៊ុនហុកបានស្នើសុំចូចូ រួមដៃជាមួយឡៅពី ដើម្បីកម្ចាត់លីប៉ូ ប៉ុន្តែព័ត៌មានបានបែកការណ៍ធ្វើឲ្យលីប៉ូ ដឹងខ្លួនទាន់។ ទើបលើកកងទ័ពទៅធ្វើសង្គ្រាមជាមួយឡៅពី ដណ្តើមយកបានក្រុងសៀវផាយ ហើយបញ្ជូនតាន់កុង ឲ្យទៅបញ្ចុះបញ្ចូលស៊ុនគួន និងពួកចោរនៅលើភ្នំថៃសាន់ឲ្យមករួមដៃគ្នាដើម្បីវាយសម្រុកចូលយកស្រុកគុនជិវ។

ពេលដែលចូចូ ដឹងព័ត៌មាននេះភ្លាមហើយ ក៏ប្រញាប់លើកទ័ពទៅកាន់ស្រុកសៀវគួន ដើម្បីធ្វើសង្គ្រាមជាមួយលីប៉ូ។ នៅពេលនោះតាន់តេងដែលស្មោះស្ម័គ្រចំពោះចូចូ ក៏នាំយកល្បិចកុហកបោកប្រាស់ដល់លីប៉ូចំនួនពាល្បិចគឺ៖

តាន់តេងបោកបញ្ឆោតលីប៉ូ លើកទីមួយគឺដោយការបន្លំធ្វើជាមានបំណងល្អជាមួយលីប៉ូ ដើម្បីកម្ចាត់បរិវារ របស់លីប៉ូឲ្យដល់នូវភាពវិនាសសាបសូន្យឥតសល់។ នៅពេលដែលស្រុកសៀវគួនស្នើសុំការជួយសង្គ្រោះជាបន្ទាន់នោះ លីប៉ូគិតចង់នាំតាន់តេង លើកទ័ពទៅជួយដោយទុកតាន់គុយ ដែលជាបិតារបស់តាន់តេង ឲ្យថែរក្សាស្រុកឈីជិវ ហើយមុនពេលនឹងចេញដំណើរ តាន់តេងបានមកពិភាក្សាជាមួយនឹង

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បិតាថាប្រសិនបើលីប៉ូ ចាញ់សង្គ្រាមត្រលប់មកវិញ សូមបិទកុំបើកទ្វារក្រុងទទួលឲ្យសោះហើយឲ្យតាន់គុយ រឹបអូសយកស្រុកដោយខ្លួនឯងវិញប៉ុន្តែមានការរាំងស្ទះត្រង់ថានៅក្នុងស្រុកមានបុត្រភរិយានិងកូនចៅរបស់លីប៉ូ យ៉ាងច្រើនទើប តាន់តេងរិះរកឧបាយកលដើម្បីកម្ចាត់បរិវារទាំងនោះឲ្យអស់ជាមុនសិន។

លុះគិតរួចហើយនិយាយប្រាប់លីប៉ូ ថាស្រុកឈីជិវ ត្រូវសត្រូវឡោមព័ទ្ធជាប់ទាំងបួនទិស ប្រសិនបើ ចូចូលើកកម្លាំងទ័ពចូលមកនោះតើយើងនឹងត្រូវធ្វើដូចម្តេច? ខ្ញុំគិតថា «យើងគួរតែការពារ ប្រសើរជាងព្យាបាល លោកគួរតែដឹកជញ្ជូនទ្រព្យសម្បត្តិព្រមទាំងស្បៀងយកទៅរក្សាទុកនៅស្រុកហែហ្វី បើសិនស្រុកឈីជិវ ត្រូវឡោមព័ទ្ធស្រុកហែហ្វីក៏នៅអាចបញ្ជូនស្បៀងមកជួយយើងបាន»។

លីប៉ូ ចាញ់បោកកលឧបាយប្រញាប់បញ្ជាបរិវារ ឲ្យទៅការពារបុត្រភរិយា ព្រមទាំងបញ្ជូនទ្រព្យសម្បត្តិទៅកាន់ស្រុកហែហ្វី នេះគឺជាការកម្ចាត់ឧបសគ្គដើម្បីរឹបអូសយកស្រុកឈីជិវ ឲ្យតាន់គុយ។

តាន់តេងបោកបញ្ឆោតលីប៉ូ ជាលើកទីពីរគឺដោយការបង្កើតនូវព័ត៌មានមិនពិតរឹបអូសយកស្រុកពីរបានយ៉ាងស្រួលខណៈពេលដែលលីប៉ូ និងតាន់តេង សំដៅមកកាន់ស្រុកសៀវគួន ដើម្បីនឹងជួយតាន់កុង

www.facebook.com/7khmer
Fb page : Entertainment And Knowledge

និងស៊ុនគួន។ នៅក្នុងរវាងការធ្វើដំណើរតាមផ្លូវ គាន់តេងគិតរកឧបាយកលបោកបញ្ឆោតលីប៉ូ ថា ខ្លួនសុំយកអាសាស្ម័គ្រទៅយកព័ត៌មាននៅស្រុកសៀវគួន ជាមុនសិន។ នៅពេលដែលមកដល់ស្រុកសៀវគួន គាន់តេងបាននិយាយជាមួយគាន់កុងត្រឹមតែពីរទៅបីមាត់ប៉ុណ្ណោះ។

លុះនៅពេលយប់ក៏បានឡើងទៅលើប៉មយាមខ្ពស់មួយក្រឡេកមើលទៅឃើញសុទ្ធតែទ័ពរបស់ចូចូ ដែលដាក់ពង្រាយពេញ ទើបចងសំបុត្រនឹងផ្លែព្រួញហើយបាញ់ទៅកាន់បន្ទាយរបស់ចូចូចំនួន៣ច្បាប់ ប្រាប់ព័ត៌មានដល់ចូចូថាខ្លួននឹងទៅធ្វើជាអ្នកស៊ើបការណ៍សម្ងាត់ សុំឲ្យចូចូរង់ចាំមើលសញ្ញាភ្លើងដែលខ្លួនបាញ់ហើយ គប្បីប្រញាប់លើកទ័ពបុកចូលមកភ្លាម។ ពេលបញ្ជូនព័ត៌មានចប់ស្រេចបាច់ហើយនៅពេលព្រឹកស្អែកគាន់តេង ក៏ប្រញាប់ប្រញាល់ជិះសេះមករាយការណ៍ប្រាប់លីប៉ូ។

ចំណែកស៊ុនគួន និងពួកចោរនៅតំបន់ភ្នំថៃសាន់ បានឃើញចូចូលើកទ័ពមកច្រើន ក៏នាំគ្នាភ័យខ្លាចហើយបានលើកទ័ពត្រលប់បកក្រោយវិញ។ លីប៉ូឃើញដូច្នោះភ័យខ្លាំងណាស់ ក៏បញ្ជូនគាន់តេងឲ្យទៅប្រាប់គាន់កុង រង់ចាំបើកទ្វារក្រុងទទួលលីប៉ូ តែពេលដែលគាន់តេងទៅដល់បែរជានិយាយកុហកគាន់កុង ថាពេលនេះកងទ័ពរបស់ចូចូ ធ្វើ

ដំណើរផ្លូវគាត់ទៅវាយយកស្រុកឈីជីវ ហើយលីប៉ូ ស្នើឲ្យលោកលើកទ័ពទៅជួយជាបន្ទាន់យប់នេះ។ កងទ័ពរបស់តាន់កុង និងកងទ័ពរបស់លីប៉ូប៉ះទង្គិចគ្នានៅពាក់កណ្ដាលផ្លូវ ហើយកងទ័ពទាំងពីរបានប្រយុទ្ធគ្នាយ៉ាងពេញទំហឹង។ ឃើញហេតុការណ៍ដូច្នេះ កងទ័ពរបស់ចូចូ ក៏ឆ្លៀតឱកាសសម្រុកបុកចូលដណ្ដើមស្រុកសៀវគួន បានយ៉ាងងាយស្រួល។

លីប៉ូនិងតាន់កុង ប្រយុទ្ធគ្នារហូតដល់ភ្លឺទើបបានដឹងថាខ្លួនបានចាញ់បោកឧបាយកលរបស់តាន់តេង។ លីប៉ូក៏ ប្រញាប់ប្រញាល់លើកទ័ពបកត្រលប់ទៅកាន់ស្រុកឈីជីវវិញ។ នៅក្នុងខណៈពេលនោះឯងតាន់គុយប្រកាសខ្លួនថាខ្លួនស្មោះស្ម័គ្រចំពោះចូចូ និងបានរឹបអូសស្រុកឈីជីវ ស្រេចហើយ។ ដូច្នេះលីប៉ូ ក៏ត្រូវបង្ខំចិត្តលើកទ័ពឆ្ពោះទៅកាន់ស្រុកសៀវផាយ វិញ។

តាន់តេង បោកបញ្ឆោតលីប៉ូ ជាលើកទីបីនោះគឺ ដោយការក្លែងបន្លំបញ្ជាកងទ័ពរឹបអូសយកស្រុកសៀវផាយដោយប្រាជ្ញារឿងរ៉ាវមានដូចតទៅនេះ៖

ខណៈពេលដែលលីប៉ូ និងតាន់កុង កំពុងតែប្រយុទ្ធគ្នាឯងនោះតាន់តេង បានឆ្លៀតឱកាសរត់គេចខ្លួន ដោយបានបំបោលសេះយ៉ាងលឿនពេញមួយយប់សំដៅឆ្ពោះទៅស្រុកសៀវផាយ លុះដល់ស្រុក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

សៀវជាយហើយ ក៏ចូលទៅរាយការណ៍ព័ត៌មានក្លែងក្លាយដល់កូស៊ុន ដែលជាអ្នកការពារស្រុកថា ឥឡូវនេះលីប៉ូ ត្រូវចូឆូ ឡោមព័ទ្ធជាប់ទើប សុំឲ្យកូស៊ុននិងទៀវសៀវ លើកទ័ពទៅជួយជាបន្ទាន់។

មេទ័ពទាំងពីរលុះបានទទួលព័ត៌មានភ្លាមហើយក៏ប្រញាប់លើក ទ័ពចេញពីស្រុកសៀវជាយ ក្លែតដើម្បីជួយលីប៉ូ គាន់គេងបានឱកាស ហើយ ក៏បញ្ជូនព័ត៌មានទៅឲ្យចូឆូ ចូឆូក៏បានសម្រុកចូលរឹបអូសយក សៀវជាយ ដោយពុំមានការខាតបង់កងទ័ពសូម្បីតែម្នាក់។ ពេលដែល លីប៉ូ មកដល់ស្រុកសៀវជាយ ក៏ឃើញតែទង់ជាតិរបស់ចូឆូ បក់រវិចៗ នៅលើកំពែងបន្ទាយជុំវិញទាំងអស់។

ផែនការនៃការបោកបញ្ឆោតលីប៉ូ របស់គាន់គេង ទាំង៣លើក អាចធ្វើឲ្យកងទ័ពរបស់លីប៉ូ ចេញពីក្នុងស្រុក និងកាប់សម្លាប់គ្នាឯង។ មិនតែប៉ុណ្ណោះថែមទាំងធ្វើឲ្យស្រុកទាំង៣ក្លាយទៅជាស្រុកគ្មានមនុស្ស រស់នៅ ដែលជាមូលហេតុធ្វើឲ្យចូឆូ អាចរឹបអូសយកបានយ៉ាងងាយ ស្រួលដោយមិនបាច់ចំណាយកម្លាំងទ័ពអ្វីឡើយ។

អ្នកជំនាញផ្នែកយោធាម្នាក់ពោលថា«ព័ត៌មាននៅក្នុងសមរភូមិ ភាគច្រើន ជាព័ត៌មានទាស់គ្នាឯង និងជាព័ត៌មានក្លែងក្លាយជឿជាក់មិន សូវបាន»។ ការស្ដាប់ព័ត៌មានទាំងនេះ ត្រូវពឹងផ្អែកទៅលើការវិនិច្ឆ័យ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

របស់មេបញ្ជាការដែលជាអ្នកវិភាគព័ត៌មាននោះឲ្យបានត្រឹមត្រូវ។ តាមធម្មតានោះគេត្រូវតែជាមនុស្សដែលចាប់អារម្មណ៍ទៅនឹងរឿងព័ត៌មាននិងស្ថានការណ៍ជានិច្ចទើបជាអ្នកវិភាគព័ត៌មានបាន។

ជាទូទៅ មនុស្សយើងច្រើនតែជឿជាក់ព័ត៌មានដែលមិនពិតម្យ៉ាងទៀតចូលចិត្តពង្រីកព័ត៌មានឲ្យលើសពីការពិត។ ថ្វីបើគ្រោះថ្នាក់ដែលបានមកពីព័ត៌មានក្លែងក្លាយដែលប្រៀបដូចជារលកបោកច្រាំងហើយស្ងប់ស្ងាត់ទៅវិញក៏ដោយ ប៉ុន្តែវាក៏មានកូនរលកតូចៗដែលបក់បោកម្តងហើយម្តងទៀតដោយឥតឈប់ឈរផងដែរ។ ដូច្នេះហើយអ្នកដែលជាមេដឹកនាំត្រូវមានឧត្តមគតិខ្ពស់មានគោលជំហររឹងមាំ ទើបអាចគេចផុតពីគ្រោះថ្នាក់ដែលកើតឡើងពីព័ត៌មានក្លែងក្លាយបាន។

តាន់គេងបានបន្តប់ខ្លួន ធ្វើជាអ្នកស៊ើបការណ៍យ៉ាងសម្ងាត់ក្នុងរឿងផ្ទៃក្នុងរបស់លីប៉ូ ទង្វើបែបនេះមិនមែនជារឿងចម្លែកថ្មីៗអ្វីនោះទេនៅក្នុងអតីតកាលក៏មានគំរូបែបនេះមកជាច្រើនដែរ តែសម្រាប់លីប៉ូដែលជាមេទ័ពចូលចិត្តតែប្រើកម្លាំងច្រើនជាងប្រើបញ្ញាម្នាក់នេះ បែរជាគ្មានភ្ញាក់ខ្លួនសូម្បីតែបន្តិច ទើបលង់ជឿព័ត៌មានក្លែងក្លាយធ្វើឲ្យបាត់-បង់អ្វីៗទាំងស្រុងព្រមទាំងជីវិតយ៉ាងអាណោចអាធ័មជាទីបំផុត។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

«មេដឹកនាំត្រូវតែចេះធ្វើ
នយោបាយ
ដោយភាពឈ្លាសវៃ
និងភាពទន់ភ្លន់
មិនមែនដោយភាពស្មោះត្រង់
ទាំងងងឹតងងល់
និងរឹងត្អឹងនោះទេ»

www.facebook.com/7khmer
Fb page : Entertainment  And Knowledge



លិប៊ូ

呂布

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ១៣

# ផែនការ

# របស់

# តាន់គុង

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

នៅក្នុងវគ្គទី ១៩ របស់រឿងនិទានសាមកុកពោលថា

បន្ទាប់ពីចូច្ចូ បុករុកចូលរឹបអូសយកស្រុកហែហ្វីហើយ បាននាំយកខ្លួនលីប៉ូ តាន់កុង និងឈ្លើយសឹកផ្សេងៗទៀត មកសួរចម្លើយ។ ចូច្ចូឃើញតាន់កុង ជាប់ចំណងក៏ពោលឡើងទាំងការបានចិត្តថា«លោកធ្លាប់និយាយថាខ្លួនឯងគឺជាមនុស្សឈ្លាសឆ្លាតវាងវៃណាស់ ហើយចុះឥឡូវនេះដូចម្ដេចដែរ?»។

តាន់កុងងាកមើលលីប៉ូ ដែលត្រូវចាប់ខ្លួនមកជាមួយគ្នាហើយនិយាយទាំងកំហឹងថា«ដោយសារតែលោកឯងមិនស្ដាប់តាមការណែនាំរបស់ខ្ញុំទើបត្រូវគេចាប់ខ្លួនបានដូច្នេះ បើពុំដូច្នោះទេក៏ប្រហែលជាមិនអាចត្រូវចាប់ខ្លួនបានដែរ»។ ពាក្យសម្ដីនេះនិយាយចេញពីក្នុងចិត្តពិតៗរបស់តាន់កុង។

តាន់កុងគឺជាអ្នកឈ្លាសវៃគ្រប់រឿងរ៉ាវទាំងអស់ តែបែរជាមកភ្លេចសុភាសិតមួយដែលពោលថា «សត្វបក្សីដែលល្អត្រូវចេះជ្រើសរើសដើមឈើធ្វើសំបុក ចំណែកឯមន្ត្រីដែលឈ្លាសវៃត្រូវចេះជ្រើសរើសចៅហ្វាយនាយ»។ ចាប់តាំងពីពេលដែលតាន់កុងបានមករស់នៅជាមួយលីប៉ូ តាន់កុងបានស្នើគោលនយោបាយល្អៗជាច្រើនដល់លីប៉ូ ប៉ុន្តែជាអកុសលលីប៉ូ ជាមនុស្សដ៏ល្ងីល្ងើមិនព្រមស្ដាប់តាមបង្គាប់របស់តាន់កុងសោះទើបត្រូវជួបប្រទះនូវរឿងដ៏គួរឲ្យអាម៉ាស់បែបនេះ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅក្នុងរឿងនិទានរបស់សាមកុកបានសរសេរទុកថា លីប៉ូបានធ្វើសង្គ្រាមជាមួយចូឆូនិងឡៅពីជាច្រើនលើកណាស់ បើលើកណាបានស្តាប់តាមការណែនាំរបស់គាន់កុងក៏ឈ្នះតែបើលើកណាមិនព្រមស្តាប់តាមការណែនាំរបស់គាន់កុង ទេក៏ចាញ់។ នៅពេលដែលលីប៉ូ បាត់បង់ស្រុកចំនួនបីក្នុងពេលតែមួយនោះ លីប៉ូត្រូវដកថយកងទ័ពមករស់នៅស្រុកហែហ្វីដែលស្ថិតក្រោមការឡោមព័ទ្ធរបស់ចូឆូ។ ដូច្នេះហើយទើបគាន់កុងស្នើផែនការល្អៗ ដើម្បីផ្លាស់ប្តូរស្ថានការណ៍ដល់លីប៉ូ ចំនួន៣ប្រការដូចតទៅនេះ៖

ពេលដែលលីប៉ូ ដកថយទ័ពមកឈរជើងក្នុងស្រុកហែហ្វី នោះចូឆូបានលើកទ័ពមកតាមជងដែរ។ គាន់កុងឃើញដូច្នេះស្នើផែនការដល់លីប៉ូថា«ឥឡូវនេះកងទ័ពរបស់ចូឆូ វាទើបតែមកដល់ លោកគួរតែឆ្លៀតឱកាស ពេលដែលកងទ័ពរបស់សត្រូវមិនទាន់នឹងមានការរឹងមាំនេះសម្រុកចូលវាយលុកតែម្តង។ សូមធានាថានឹងត្រូវទទួលបានជ័យជម្នះពិតប្រាកដ»។

ចំណុចសំខាន់របស់ផែនការនេះគឺឆ្លៀតឱកាសនៅពេលសត្រូវឈរជើងមិនទាន់រឹងមាំ ដើម្បីផ្លាស់ប្តូរស្ថានការណ៍ពីភាគីចាំទប់ទល់ទៅជាភាគីវាយសម្រុកចូល គឺចូលវាយលុកសត្រូវឲ្យបានរហ័ស ដូចជា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ផ្ដេកបន្ទោរតែម្ដង។ នេះជាចំណុចល្អបំផុតដែលភាគីចាំទប់ទល់អាចឆក់ឱកាសបាន។ ការវាយលុកបែបនេះនឹងទទួលបានលទ្ធផលគួរជាទីគាប់ចិត្ត។

ក្នុងតម្រាពិជ័យសង្គ្រាមបានចែងទុកថា «សម្រុកចូលរឹបអូសយកទីតាំងទុកជាមុន ដើម្បីរង់ចាំឱកាសសម្រុកចូលវាយលុកលើពួកសត្រូវដែលទើបតែលើកទ័ពមកដល់» ប៉ុន្តែលីប៉ូ បែរជាយល់ឃើញថា «កងទ័ពរបស់ខ្លួនចាញ់សង្គ្រាមអស់ជាច្រើនលើកច្រើនសាមកហើយ យើងមិនគួរនឹងលើកទ័ពចេញច្បាំងយ៉ាងប្រថុយប្រថាននោះទេ គួរតែពង្រីកកងទ័ពឲ្យរឹងមាំនៅក្នុងស្រុករង់ចាំសត្រូវលើកទ័ពមកវាយហើយចាំវាយបកត្រលប់ទៅវិញ»។

នៅទីបំផុត ពេលវេលាបានកន្លងផុតទៅអស់រយៈពេលជាច្រើនថ្ងៃ ពួកកងទ័ពរបស់ចូចូ ក៏បាត់នឿយហត់ហើយលីប៉ូ ក៏បាត់បង់ឱកាសល្អៗទៅទទេៗ។ ក្រោយមកកងទ័ពរបស់ចូចូ មកបោះទីតាំងនៅទល់គ្នានឹងកងទ័ពរបស់លីប៉ូ តាន់កុងបានស្នើផែនការដល់លីប៉ូ ម្ដងទៀតថា «ចូចូលើកទ័ពមកពីចម្ងាយ ប្រហែលជាបោះទីតាំងនៅយូរមិនបានទេ លោកគួរតែដឹកនាំកងទ័ពចេញទៅខាងក្រៅស្រុក ចំណែកឯខ្ញុំនឹងនៅការពារក្នុងស្រុកបើសិនកងទ័ពរបស់ចូចូ ធ្វើសង្គ្រាមជាមួយនឹងលោក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ្ញុំនឹងលើកទ័ពទៅវាយពីខាងក្រោយប៉ុន្តែបើកងទ័ពរបស់ចូចូ សម្រុកចូលក្នុងស្រុកលោកត្រូវនាំទ័ពវាយពីខាងក្រោយវិញ។ សង្ឃឹមថាមិនលើសពី១៥ថ្ងៃ កងទ័ពរបស់ចូចូ នឹងអស់ស្បៀងហើយពួកយើងចូលវាយកម្ទេចឲ្យវិនាសតែម្តង»។

លីប៉ូ យល់ព្រមជាមួយនឹងផែនការរបស់តាន់កុង ក៏ប៉ុន្តែពេលត្រលប់ចូលទៅក្នុងភូមិគ្រឹះត្រូវភរិយារាំងជាប់ទើបស្ទាក់ស្ទើរមិនហ៊ានសម្រេចចិត្ត ហើយមិនព្រមចេញមកប្រជុំមន្ត្រីរាជការរហូតដល់ទៅ៣ថ្ងៃ សូម្បីតែតាន់កុងបានដាស់តឿនម្តងហើយម្តងទៀតថា «ទ័ពរបស់ចូចូឡោមព័ទ្ធទាំងបួនទិស បើមិនប្រញាប់លើកទ័ពទៅទេត្រូវបរាជ័យយ៉ាងពិតប្រាកដ»។ ផ្ទុយទៅវិញលីប៉ូ បែរជាឆ្លើយថា «ខ្ញុំគិតឃើញថាការលើកកងទ័ពចេញទៅក្រៅស្រុកស៊ូនឹងការពង្រឹងកម្លាំងនៅខាងក្នុងស្រុកមិនបានទេ»។

រឿងដែលអ្នកជំនាញផ្នែកយោធាភ័យខ្លាចបំផុត គឺការការពារទីតាំងដោយប្រាសចាកកងទ័ពជំនួយ ព្រោះថានៅក្នុងសមរភូមិការធ្វើឲ្យកងទ័ពរបស់យើងមានភាពស្មើគ្នាជាមួយនឹងសត្រូវ មានតែផ្លូវមួយគត់ គឺត្រូវបង្កើតឱកាសសម្រុកចូលវាយលុកទៅលើពួកសត្រូវខ្លះ មិនត្រូវបណ្តោយឲ្យសត្រូវវាយលុកមកលើយើងតែម្ខាងទេ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ការធ្វើសង្គ្រាមនៅក្នុងអតីតកាលតែងតែកើតមានហេតុការណ៍បែបនេះគឺនៅពេលណាដែលយើងទប់ទល់ជាមួយកម្លាំងរបស់សត្រូវមិនបានហើយ មានតែការបើកឆាកវាយពីក្រោយខ្នងរបស់សត្រូវតែប៉ុណ្ណោះ ដែលអាចដោះស្រាយស្ថានការណ៍ទាំងអស់បាន។ ដូច្នេះនៅក្នុងការការពារក្រុង ការពង្រាយកម្លាំងទ័ព ឬការបង្រួបបង្រួមកម្លាំងទ័ពឲ្យបានត្រឹមត្រូវ ទើបជាកត្តាដ៏សំខាន់ក្នុងការផ្លាស់ប្តូរស្ថានការណ៍ឆ្ពោះទៅកាន់ភាពជោគជ័យនិងការពន្យារពេលក្នុងការការពារក្រុងបាន។

តាន់កុងដែលជាអ្នកជំនាញក្នុងគម្រោងពិជ័យសង្គ្រាម ដឹងច្បាស់នូវសារសំខាន់ក្នុងចំណុចនេះទើបសុំឲ្យលីប៉ូ លើកទ័ពច្បាំងតែម្តងប៉ុន្តែលីប៉ូដែលជាមនុស្សល្ងង់ខ្លៅបែរជាបដិសេធសំណើរបស់តាន់កុង ម្តងហើយម្តងទៀតទៅវិញ។ តាន់កុងទ្រាំមើលនូវការបរាជ័យរបស់លីប៉ូនៅនឹងភ្នែកមិនបាន ទើបធ្វើការវិភាគស្ថានកការណ៍យ៉ាងល្អិតល្អន់ម្តងទៀតហើយ ស្នើដែនការចុងក្រោយដល់លីប៉ូថា«ខ្ញុំបានទទួលព័ត៌មានថាពេលនេះកងទ័ពរបស់ចូចូ ខ្វះខាតស្បៀងអាហារត្រូវបញ្ជូនមនុស្សឲ្យទៅដឹកជញ្ជូនស្បៀងពីក្រុងហ៊ូតូ ស្ទើរតែរាល់ថ្ងៃ គឺចេញដំណើរនៅពេលព្រឹក ពេលល្ងាចទើបវិលត្រលប់មកវិញ។ លោកមេទ័ពគួរតែជ្រើសរើសកងទ័ពដែលក្លាហាន ឲ្យពួនស្ទាក់ចាំប្លន់យកស្បៀង របស់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

វា ផែនការមួយនេះល្អបំផុតលោកមេទ័ព ស៊ុនជឺធ្លាប់បានពោលទុកជារឿយៗថាទ័ពអាចរុលទៅមុខបានដោយស្បៀងអាហារបើគ្មានស្បៀងអាហារទេរមែងស្លាប់យ៉ាងពិតប្រាកដ។ យើងជាម្ចាស់ផ្ទះហើយសត្រូវគឺជាភ្ញៀវបើយើងកាត់ផ្ដាច់ស្បៀងពួកសត្រូវរមែង អត់ឃ្លានហើយការប្រើយុទ្ធសាស្ត្រកាត់ផ្ដាច់បែបនេះ ភាគច្រើនតែងតែនឹងធ្វើឲ្យទ័ពរបស់សត្រូវដកថយទៅវិញដោយឯងៗមិនចាំបាច់ធ្វើសង្គ្រាមឡើយ»។

ប៉ុន្តែលីប៊ូ ទ្រាំនឹងដំណក់ទឹកភ្នែករបស់ភរិយាមិនបានក៏និយាយបដិសេធជាមួយតាន់កុងថា«ចូឆូគឺជាមនុស្សពោរពេញទៅដោយល្បិចខ្ញុំមិនហ៊ានចាត់ការជាមួយពួកគេទេ» ម្លោះហើយតាន់កុង បានត្រឹមតែដកដង្ហើមធំហើយក៏លាត្រលប់ទៅវិញ។

ផែនការទាំង ៣ របស់តាន់កុង វាបានឆ្លុះបញ្ចាំងឲ្យបានឃើញច្បាស់ពីការគិតរិះរកមធ្យោបាយ ដើម្បីការពារក្រុង និងព្យាមយាមឆក់យកឱកាសធ្វើការវាយលុកទៅលើពួកសត្រូវ ដោយជៀសវាងនូវការធ្លាក់ខ្លួនទៅជាអ្នកចាំទប់ទល់ជាមួយនឹងពួកសត្រូវ។ គំនិតបែបនេះនៅតែមានការប្រើប្រាស់រហូតមកដល់បច្ចុប្បន្ន ក៏ប៉ុន្តែលីប៊ូបែរជាគិតពាក់កំដែលថាខ្លួនជាអ្នកចម្បាំងយ៉ាងអង់អាចក្លាហាន មានថ្វីដៃនៅក្នុងការបាញ់ហាក់បីដូចជាចាប់យកទៅដាក់ និងមានសេះដែលមានកម្លាំង

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដើងខ្លាំងគ្មាននរណាហ៊ានក្អកឬលលេងជាមួយខ្លួន។

ដូច្នេះហើយ ទើបគិតតែពីខំប្រើងការពារស្រុកដោយបណ្តោយឲ្យពួកសត្រូវធ្វើការវាយលុកដូចជាល្បែងលេង ធ្វើឲ្យផែនការរបស់តាំងកុង ដែលបានខំព្យាយាមគិតយ៉ាងពិតបាត់បង់ទៅជាមួយនឹងភាពបរាជ័យ។

លីប៉ូបានបណ្តោយឲ្យឱកាសដែលល្អៗ បាត់បង់ទទេៗជាច្រើនលើកច្រើនសា។ នៅទីបំផុតក៏ត្រូវពួកសត្រូវចាប់ខ្លួនបានហើយក៏ត្រូវបញ្ចប់ជីវិតយ៉ាងសោកសៅជាទីបំផុតក្នុងពេលនោះទៅ។

«កុំធ្វើជាដែកគោល
ឲ្យញញួរដំ
តែត្រូវធ្វើជាញញួរដំ
ដែកគោលវិញ»

www.facebook.com/7khmer
Fb page : Entertainment And Knowledge



**ទៀវហ៊ុយ**

**張飛**

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ១៤

# ប្រាជ្ញា របស់ ទៀវហ៊ុយ

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

តំណាក់ទឹកប៉ាកការបស់ឡូក្អនចុង បានសរសេរពិពណ៌នាដល់ភាពគ្រោតគ្រាតរបស់ទៀវហ៊ុយ យ៉ាងរស់រវើកធ្វើឲ្យមិត្តអ្នកអានអស់សំណើចដោយលាយឡំជាមួយក្តីអាណិតអាសូរផងដែរ។ ស្របពេលគ្នានោះដែរ ឡូក្អនចុងក៏បានពិពណ៌នាអំពីភាពហ្មត់ចត់របស់ទៀវហ៊ុយយ៉ាងពីរោះដែរ ប៉ុន្តែនៅក្នុងក្រសែភ្នែករបស់អ្នកអានទៀវហ៊ុយ នៅតែជាមនុស្សព្រូវឡោងខាមគ្រោតគ្រាតតែដដែលហ្នឹង បើសិនបើប្រិយមិត្តអ្នកអានសម្លឹងមើលឃើញតែចំណុចអាក្រក់របស់ទៀវហ៊ុយ ច្រើនជាងចំណុចល្អ នេះបើតាមការវាយស្ទាបរបស់ខ្ញុំ។

តាមពិត ទៀវហ៊ុយពិតជាមនុស្សឆេវឆាវមែន ក៏ប៉ុន្តែបើយើងវិភាគបុគ្គលិកលក្ខណៈរបស់ទៀវហ៊ុយ នៅក្នុងវគ្គទី២២យើងនឹងដឹងថាការយល់ឃើញបែបនេះចំពោះទៀវហ៊ុយ មិនយុត្តិធម៌ទេ។ ទៀវហ៊ុយមិនមែនជាមនុស្សដែលធំតែខ្លួនហើយខ្វះការពិចារណានោះទេ។

នៅពេលខ្លះ គាត់ក៏អាចគិតឃើញឧបាយកលល្អៗដើម្បីយកឈ្នះពួកសត្រូវបានដូចគ្នា ខ្លឹមសារក្នុងវគ្គនៃរឿងនិទានសាមកុកទី២២បានរៀបរាប់ថា បន្ទាប់ពីចូចូ បង្ក្រាបលីប៊ូ បានសម្រេចហើយក៏បាននាំឡៅពីត្រលប់មកកាន់ក្រុងហ៊ូតូដែរ។ ឡៅពីចាំបាច់ត្រូវប្រើផែនការដាំបន្លែបង្ការដើម្បីរស់នៅក្នុងរូងខ្លាមួយរយៈសិន។ ក្រោយមក ឡៅពីក៏

www.facebook.com/7khmer
Fb page : Entertainment And Knowledge

យកលេសថានាំទ័ពចេញទប់ទល់នឹងអួនស៊ុត ហើយក៏គៀសខ្លួនចេញពីក្រុងហ៊ូតូដោយសុវត្ថិភាព។

ឡៅពីវ៉ាយឈ្មះអួនស៊ុត កាត់ក្បាលគីម៉ៅ និងរឹបអូសយកបានស្រុកឈីជិវសាជាថ្មីម្តងទៀត។ កាលជាខាងក្រោយមក បានរៀបចំផែនការណាត់ជួបអួនសៀវ លើកទ័ពទៅវ៉ាយលុកចូឆូ។ ចូឆូបានដឹងព័ត៌មានភ្លាម ភិតភ័យយ៉ាងខ្លាំង ហើយក៏ប្រញាប់លើកទ័ព២០ម៉ឺននាក់ទៅវ៉ាយលុកអួនសៀវ។ មួយផ្នែកទៀតបញ្ជាឲ្យឡៅតាយ និងអង់តុងលើកទ័ពទៅបង្ក្រាបឡៅពី។

ឡៅតាយ និងអង់តុង ទាំងពីរនាក់មិនមែនជាដៃគូជាមួយមេទ័ពមហាអង់អាចក្លាហានទាំង៣រូបរួមមានឡៅពី កួនអ៊ូ និង ទៀវហ៊ុយ ទេ។ អង់តុងទើបគ្រវីលំពែងមិនទាន់នឹងបានប៉ុន្មានជង់ក៏ត្រូវកួនអ៊ូ ចាប់បានទាំងរស់ រីឯទៀវហ៊ុយឃើញកួនអ៊ូសាងគុណសម្បត្តិដូច្នោះក៏ប្រញាប់ប្រញាល់ស្បថស្បែនៅចំពោះមុខឡៅពី ថានឹងចាប់ឡៅតាយ ឲ្យបានទាំងរស់ដូចគ្នា។ ខ្លឹមសារលម្អិតមានដូចតទៅនេះ៖

ពេលដែលឡៅតាយ ដឹងថាអង់តុង ត្រូវកួនអ៊ូ ចាប់បានទាំងរស់ដូច្នោះក៏បានព្យាយាមការពារបន្ទាយយ៉ាងតឹងតែងដោយមិនព្រមចេញមកធ្វើចម្បាំងសោះ ទៀវហ៊ុយបានជិះសេះមកស្រែកជេរនៅខាងមុខ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បន្ទាយរាល់ថ្ងៃ។ ឡៅតាយដឹងថាជាទៀវហ៊ុយ ក៏រឹតតែខ្លាចមិនហ៊ាន ចេញមកទៀត ទៀវហ៊ុយបានឡោមព័ទ្ធបន្ទាយអស់ជាច្រើនថ្ងៃនៅតែ មិនឃើញឡៅតាយ ចេញមកទៀត ទើបគិតរកមធ្យោបាយចាត់ការ ជាមួយឡៅតាយ ដោយបញ្ជាទាហានថា «យប់នេះនៅវេលាម៉ោងពីរ រំលងអាធ្រាត្រនឹងលើកទ័ពទៅប្លន់បន្ទាយរបស់ឡៅតាយ»។

នៅពេលថ្ងៃក្នុងថ្ងៃនោះ ទៀវហ៊ុយបានអង្គុយផឹកស្រានៅក្នុង ខ្ទមហើយបន្លំធ្វើជាស្រវឹងនិងវាយកូនទាហានម្នាក់យ៉ាងដំណំ។ ក្រោយ មកបញ្ជាឲ្យចងទុកនៅក្នុងបន្ទាយព្រមទាំងស្រែកខ្លាំងៗថា«រង់ចាំលើក ទ័ពចេញយប់នេះ អញនឹងកាត់ក្បាលវាយកមកសែនទង់ជ័យ»។

ក្រោយមកទៀត លួចបញ្ជាឲ្យកងទ័ពដោះលែងអ្នកទោសម្នាក់ នោះៗ ក៏ប្រញាប់ចេញពីបន្ទាយហើយទៅរាយការណ៍ប្រាប់ឡៅតាយ ថាយប់នេះទៀវហ៊ុយ នឹងលើកទ័ពមកប្លន់បន្ទាយ។ ឡៅតាយឃើញ ទាហានម្នាក់នោះមានរបួសធ្ងន់ ក៏លង់ជឿពាក្យសម្ដី ហើយបោះបង់ បន្ទាយខ្លួនចោលហើយដឹកនាំទ័ពទៅពួននៅក្រៅបន្ទាយ។

យប់នោះទៀវហ៊ុយ បានបែងចែកកងទ័ពជា៣ក្រុមរួចប្រគល់ ភ្នាទីឲ្យកងទ័ព១ក្រុមជាង៣០នាក់ចូលទៅប្លន់បន្ទាយ និងដុតបន្ទាយ ឡៅតាយចោល។ ចំណែកទ័ពពីរក្រុមទៀតឲ្យធ្វើការវាយលុកអមនៅ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពីក្រោយ និងវាយសម្រុកចូលមកខាងក្នុង ដោយរង់ចាំមើលភ្លើងឆេះជាសញ្ញា។ នៅវេលាម៉ោងពាវលង់អាធ្រាត្រ ទៀវហ៊ុយបាននាំកងទ័ពក្លាហានវាយលុកពីក្រោយខ្នងឡៅតាយជាមុន ពេលនោះកងទ័ពដែលមានគ្នា៣០នាក់ ក៏បានសម្រុកចូល និងដុតបំផ្លាញបន្ទាយពួកកងទ័ពរបស់ឡៅតាយ ដែលពួនស្ទាក់ចាំគិតនឹងវាយសម្រុកចូលមកតែកងទ័ពរបស់ទៀវហ៊ុយ ពីរក្រុមទៀតស្ទុះចូលមក ទើបកងទ័ពរបស់ឡៅតាយមានភាពច្របូកច្របល់យ៉ាងខ្លាំងមិនដឹងថា តើទៀវហ៊ុយមានកងទ័ពប៉ុន្មាននាក់ឲ្យពិតប្រាកដ។ ម្នាក់ៗនាំគ្នារត់គេចខ្លួនយកតែប្រាសអាយុ។

ចំណែកឡៅតាយវិញ ដឹកនាំកងទ័ពមួយក្រុមរត់គេចខ្លួនចេញមកស្រាប់តែជួបគ្នានឹងទៀវហ៊ុយ នៅលើផ្លូវតូចចង្អៀត ទើបមានភាពពិបាកនឹងរត់គេចខ្លួន។ ឡៅតាយក៏បានសម្រេចចិត្តប្រយុទ្ធជាមួយនឹងទៀវហ៊ុយទាំងបង្ខំចិត្តបានត្រឹមមួយស្នៀតគត់ ទៀវហ៊ុយក៏ចាប់បានឡៅតាយទាំងរស់ ហើយកងទ័ពដែលនៅសេសសល់ពីនោះក៏នាំគ្នាចុះចូលជាមួយទៀវហ៊ុយតាមសម្រួល។

មិនគួរឲ្យជឿទាល់តែសោះថា មនុស្សព្រៃហើនកោងកាចដូចជាទៀវហ៊ុយ ក៏ចេះរិះគិតរកផែនការល្អបែបនេះចេញមកបានតាមធម្មតាដែរ។ តាមពិតមនុស្សឲ្យតែគិត មិនចេះខ្វះប្រែកចេញនោះទេសមដូច

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពាក្យខ្មែរយើងថា«មានសង្ឃឹម មានឆន្ទៈ និងមានការគិតពិតជានឹងមានមធ្យោបាយ»។

ការពួនស្ទាក់សត្រូវដែលពួនស្ទាក់យើងនោះ វាអាចធ្វើទៅបានលុះត្រាណាតែបានទទួលព័ត៌មានថា មានសត្រូវពួនស្ទាក់ចាំយើង ទើបយើងអាចប្រើ «ផែនការត្រួតស៊ីគ្នាលើផែនការ»នេះបាន ប៉ុន្តែសម្រាប់ទៀវហ៊ុយវិញ បែរទៅជាបញ្ឆោតឲ្យពួកសត្រូវប្រើផែនការពួនចាំស្ទាក់ពេលដែលសត្រូវចាញ់ក្នុងឧបាយកលហើយ ទើបឡោមព័ទ្ធវាយលុកតែម្តងបានធ្វើឲ្យសត្រូវទាល់ច្រកអស់ផ្លូវតស៊ូ ហើយខ្លួនក៏ទទួលបានជ័យជម្នះយ៉ាងស្រួល។

ទៀវហ៊ុយប្រើផែនការបោកបញ្ឆោតឲ្យសត្រូវចាញ់កលឧបាយបានយ៉ាងល្អឥតខ្ចោះ។ តាមធម្មតា ទៀវហ៊ុយចូលចិត្តផឹកស្រាស្រាប់ហើយពេលដែលស្រវឹងលើកណា ក៏តែងតែវាយដំកូនទាហានដោយគ្មានហេតុផលជានិច្ច។ ប៉ុន្តែពេលនេះគាត់បេះនាំយកចំណុចខ្សោយរបស់ខ្លួនមកបោកបញ្ឆោតសត្រូវ មិនដឹងថា ទៀវហ៊ុយឆ្លាតបែបនេះតាំងតែពេលណាមកទេ។ ទៀវហ៊ុយធ្វើពុតជាស្រវឹងហើយវាយដំកូនទាហានព្រមទាំងព្រលយពាក្យថា «រង់ចាំមើលលើកទ័ពនៅយប់នេះនឹងចាប់វាយកមកកាត់ក្បាលយកទៅសែននៅមុខទង់ជ័យ»។ របៀប

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៃការអនុវត្តន៍ផែនការរបស់ទៀវហ៊ុយ ប្រព្រឹត្តទៅតាមបែបធម្មជាតិពិតៗធ្វើឲ្យពួកសត្រូវធ្លាក់ចូលទៅក្នុងអន្ទាក់បានយ៉ាងល្អ។

ក្រោយពីផ្សព្វផ្សាយព័ត៌មានថា នឹងលើកទ័ពទៅវាយឡៀតាយនៅយប់នេះហើយ ទៀវហ៊ុយក៏បានលួចបញ្ជាកងទ័ពឲ្យដោះលែងអ្នកទោសម្នាក់នោះ។ ផែនការមួយនេះគឺដូចគ្នានឹងផែនការ «សុខចិត្តឈឺខ្លួនឯងដើម្បីធ្វើជាអ្នកស៊ើបការណ៍សម្ងាត់ឬប្រើរបស់ក្លែងក្លាយបញ្ជាក់ថាជារបស់ពិត»គោលដៅគឺដើម្បីបោកបញ្ឆោតសត្រូវឲ្យវង្វេងវង្វាន់។

ទៀវហ៊ុយអនុវត្តផែនការមួយនេះប្រព្រឹត្តទៅតាមបែបធម្មជាតិពិតៗ។ វាជាស្នាដៃដែលមិនអាចនឹកស្មានដល់ ធ្វើឲ្យមិត្តអ្នកអានមានអារម្មណ៍សែនរំភើប មិនត្រឹមតែប៉ុណ្ណោះខណៈពេលដែលទៀវហ៊ុយអនុវត្តផែនការ គាត់បានរៀបចំវគ្គឃ្លាយ៉ាងល្អិតល្អន់ ចាប់តាំងតែពីខ្លួនលើកទ័ពសម្រុកចូលវាយលុកឡៀតាយ រហូតដល់ឡោមព័ទ្ធកងទ័ពរបស់ឡៀតាយ ដែលពួនស្ទាក់គ្រប់វគ្គទាំងអស់។ នេះគឺវាសុទ្ធតែសមហេតុផលនិងពេញលេញបំផុត។

នៅក្នុងសម័យបុរាណ អ្នកជំនាញផ្នែកយោធាច្រើនតែឈ្លោះប្រកែកគ្នា តែរឿងប្រើឧបាយកល«ពួនស្ទាក់ចាំវាយ» ឬ «ឧបាយកលស្ទាក់ត្រួតស៊ីលើគ្នា»នេះហាក់បីដូចមិនសូវចាប់អារម្មណ៍ប៉ុន្មានទេ ប៉ុន្តែ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឡូកួនចុង បែរជានាំយកនូវឧបាយកលចាប់ឡៅតាយ របស់ទៀវហ៊ុយ មកធ្វើការពិពណ៌នាឲ្យឃើញពីភាពអស្ចារ្យរបស់ផែនការ«ពួនចាំស្ទាក់ត្រួតស៊ីលើគ្នា»រហូតធ្វើឲ្យមិត្តអ្នកអានជក់ចិត្តដិតអារម្មណ៍។

ខ្លឹមសារនៅក្នុងវគ្គនេះ មិនត្រឹមតែបានឆ្លុះបញ្ចាំងឲ្យឃើញថា ទៀវហ៊ុយ ជាអ្នកលេងដែលមានសមត្ថភាពល្អិតល្អន់ហ្មត់ចត់ប៉ុណ្ណោះ ទេតែថែមទាំងបានឆ្លុះបញ្ចាំងឲ្យឃើញច្បាស់ថែសពីភាពឈ្លាសវៃនៅក្នុងផ្នែកយោធារបស់អ្នកនិពន្ធផងដែរ។

**«យើងមិនទាន់ដឹងថា**
**អ្នកណាឆ្លាតអ្នកណាល្ងង់បានទេ**
**រង់ចាំមើលគេធ្វើសកម្មភាពសិន**
**ទើបដឹងបាន»**

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ១៥

# ឧបាយកល
# បោកបញ្ឆោត
# សត្រូវ
# ឲ្យឆ្មើងកន្ទ្រើង
# ឬឡើងចាង

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

នៅក្នុងគម្រាពិជ័យសង្គ្រាមរបស់ស៊ុនវូមានឧបាយកលមួយហៅថា
«បោកបញ្ឆោតឲ្យសត្រូវឆ្មើងកន្ទើងឬឡើងចាង»

ឧបាយកលខាងលើ មានន័យថាធ្វើឲ្យសត្រូវមើលងាយយើង និងមានចិត្តធ្វេសប្រហែសចំពោះយើង។ ពេលណាដែលសត្រូវមិនប្រុងប្រយ័ត្នសេចក្ដីស្លាប់នឹងមកដល់។ ការធ្វើឲ្យសត្រូវធ្វេសប្រហែសប្រៀបដូចជាពួកសត្រូវទម្លាក់អាវុធផ្នែកសតិបញ្ញាស្មារតីចុះដែរ។

វិធីនៃការបោកបញ្ឆោតសត្រូវឲ្យឆ្មើងកន្ទើងនោះ វាមានច្រើនសន្ធឹកសន្ធាប់ណាស់ដូចជាបន្លំធ្វើជាមនុស្សមិនបានការ។ ខ្លួនមានការប្រុងជើងការខ្ពស់ តែធ្វើជាមិនមានការប្រុងជើងការ។ ខ្លួនមានកងទ័ពក្លាហានតែបន្លំធ្វើជាមានកងទ័ពទន់ខ្សោយ ឬក៏និយាយលើកសរសើរសត្រូវឲ្យបានចិត្ត។ ទាំងអស់នេះ សុទ្ធតែជាការធ្វើឲ្យសត្រូវមានការធ្វេសប្រហែសនិងខ្វះការប្រុងប្រយ័ត្នបាន។

នៅក្នុងវគ្គទី២៦របស់និទានសាមកុកបាននិយាយអំពីចូវឆូ បោកបញ្ឆោតប៊ុនធិវ ឲ្យឆ្មើងកន្ទើងរួចហើយលើកទ័ពសម្រុកចូលវាយយ៉ាងស្រួលដូចតទៅនេះ៖

ខណៈពេលដែលចូវឆូ លើកទ័ពមកជួយឡៅអៀន នៅក្នុងស្រុកប៉ែកបែ ចូវឆូបម្រុងនឹងលើកទ័ពត្រលប់ទៅវិញស្រាប់បានទទួលដំណឹង

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ថាប៊ុនធិវ ដែលជាមេទ័ពដ៏ល្បីឈ្មោះរបស់ស្រុកហ៊ីប៉ុយ បានលើកទ័ពមកសង់សឹកជាមួយក្លួនអ៊ូ ដែលបានសម្លាប់ផាន់លៀង។

ប៊ុនធិវលើកទ័ពធំឆ្លងទន្លេហ្វាងហូ សម្រុកចូលមក ចូឆូប្រញាប់បញ្ជាថាឲ្យប្តូរកងទ័ពជួរក្រោយឲ្យមកនៅជួរមុខ និងឲ្យកងទ័ពជួរមុខទៅនៅជួរក្រោយ ហើយឲ្យកងទ័ពដឹកជញ្ជូនស្បៀងចេញដំណើរទៅមុនសិន។ ចំណែកឯកងទ័ពទាំងអស់ ត្រូវចេញដំណើរតាមពីក្រោយដើម្បីត្រៀមប្រយុទ្ធនឹងប៊ុនធិវ លិយ៉យសួរចូឆូថា«កងដឹកស្បៀងនៅជួរមុខហើយកងទ័ពនៅជួរក្រោយធ្វើបែបនេះតើមានន័យដូចម្តេច?»។

ចូឆូឆ្លើយថា«កងដឹកស្បៀងនៅខាងក្រោយតែងតែត្រូវស្ទាក់ប្លន់ជានិច្ច។ ដូច្នេះហើយទើបឲ្យកងដឹកជញ្ជូនស្បៀងនៅខាងមុខ»។

លិយ៉យមិនដឹងផែនការរបស់ចូឆូ ទើបសាកសួរទៀតថា«កងទ័ពដឹកជញ្ជូននៅខាងមុខ ប្រសិនបើត្រូវពួកសត្រូវប្លន់យកទៅតើត្រូវធ្វើដូម្តេច?» ចូឆូឆ្លើយថា «រង់ចាំឲ្យពួកសត្រូវមកដល់ លោកនឹងយល់ដោយខ្លួនឯង»។ និយាយចប់ក៏បង្ខំឲ្យកងស្បៀងរុញរទេះទៅនៅជួរមុខ ពេលដែលកងដឹកជញ្ជូនស្បៀង ធ្វើដំណើរមកដល់ស្រុកអៀនជិន ក៏ត្រូវកងទ័ពរបស់ប៊ុនធិវ ប្លន់យកស្បៀងទៅពិតមែន។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

កងដឹកជញ្ជូនស្បៀងក៏ត្រូវបានកងទ័ពរបស់ប៊ុនធិវ វាយបែកខ្ចាត់ខ្ចាយក៏រត់មករាយការណ៍ប្រាប់ដល់ចូចូ តែចូចូបែរជានាំពួកកងទ័ពដែលដឹកជញ្ជូនស្បៀងទាំងអស់នោះឡើងទៅលើភ្នំ ហើយបញ្ជាឲ្យកងទ័ពដោះអាវក្រោះចេញពីខ្លួន និងអង្គុយសម្រាកព្រមទាំងលែងសេះឲ្យស៊ីស្មៅតាមសម្រួល។

មួយសន្ទុះក្រោយមកប៊ុនធិវ លើកទ័ពមកដល់ បណ្ដាពួកមេទ័ពនិងកូនទាហានបាននាំគ្នាមកស្នើឲ្យចូចូ ប្រញាប់ប្រមូលរបស់របរ រត់គេចដើម្បីដកថយ មានតែស៊ុនហ៊ិវ ម្នាក់គត់ដែលនិយាយថា«បែបនេះហើយដែលគេហៅថា បោកបញ្ឆោតសត្រូវឲ្យមកជាប់អន្ទាក់ ចាំបាច់ដកថយទ័ពធ្វើអ្វី?»។

ចូចូប្រញាប់ប្រញាល់ញាក់ត្របកភ្នែក ជាសញ្ញាមិនឲ្យស៊ុនហ៊ិវនិយាយជាបន្ត។ ក្នុងខណៈពេលនោះកងទ័ពរបស់ប៊ុនធិវដែលទើបតែច្បាំងឈ្នះមកក្ដៅៗ រួមទាំងរឹបអូសបានសាស្ត្រាវុធរបស់ចូចូ យ៉ាងច្រើនសន្ធឹកសន្ធាប់បានចិត្តពេញទំហឹងតែម្ដង ហើយនៅពេលដែលក្រឡេកមើលទៅឃើញសេះច្រើនរឹតសប្បាយចិត្តទៀត បាននាំគ្នាស្ទុះចូលទៅវាយដណ្ដើមសេះទើបធ្វើឲ្យទ័ពគ្មានរបៀបនិងកើតភាពវឹកវរឡើង។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចូចូឃើញឱកាសល្អបានមកដល់ហើយ ក៏បញ្ជាទ័ពសម្រុកចុះមកពីលើភ្នំ បានធ្វើឲ្យទ័ពរបស់សត្រូវភិតភ័យយ៉ាងខ្លាំងហើយក៏នាំគ្នារត់ជាន់គ្នាទៅវិញទៅមករវាងមនុស្សនិងសេះយ៉ាងកោលាហល។

ចំណែកឯប៊ុនធិវ ដែលល្បីឈ្មោះថាជាកំពូលមេទ័ពប្រចាំនៅស្រុកហឺប៉ីយ ត្រូវបានក្អួនអ៊ូ សម្លាប់ចោលក្នុងភាពច្របូកច្របល់នោះផងដែរ។ កងទ័ពរបស់ចូចូក៏បានទទួលនូវជ័យជម្នះយ៉ាងដាច់រហ័សជាទីបំផុត។ ស្បៀងអាហារព្រមទាំងសេះដែលបាត់បង់ទាំងអម្បាលមាណបានត្រលប់មកវិញទាំងអស់។ កាលក្រោយមក ចូចូបានអធិប្បាយឲ្យលិយ៉យស្តាប់នៅក្នុងពិធីបុណ្យឆ្លងជ័យជម្នះថា «កាលពីម្សិលមិញ ខ្ញុំបញ្ជាឲ្យកងទ័ពជញ្ជូនស្បៀងដើរនៅជួរមុខ ក៏ព្រោះតែត្រូវការប្រើពួកគេដើម្បីធ្វើជានុយបោកបញ្ឆោតពួកសត្រូវ មានតែស៊ុនហ៊ិវ ប៉ុណ្ណោះដែលយល់ពីផែនការរបស់ខ្ញុំ»។ គ្រប់គ្នាបានស្តាប់ហើយក៏នាំគ្នាកោតស្ញប់ស្ញែងចំពោះចូចូយ៉ាងខ្លាំង។

រឿងនិទាននៅក្នុងវគ្គនេះពីរោះណាស់ ប៉ុន្តែប្រសិនបើសម្លឹងមើលយុទ្ធសាស្ត្រផ្នែកយោធាវិញនោះ ក្នុងពេលដែលចូចូប្រើកងដឹកស្បៀងធ្វើជានុយបោកបញ្ឆោតសត្រូវឲ្យមកជាប់អន្ទាក់ ឬបន្លំធ្វើជាទន់ខ្សោយដើម្បីបញ្ឆោតសត្រូវមិនមែនជាផែនការអ្វីអស្ចារ្យប៉ុន្មានទេ តែ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប៊ុនធិវដែលជាគូតស៊ូរបស់ចូចូនោះ ជាអ្នកចម្បាំងផ្នែកក្បាច់គុន ប៉ុន្តែខ្សោយខាងផ្នែកបញ្ញា ថែមទាំងជាមនុស្សដែលមានចិត្តអន្ទះសា ឈ្លក់វង្វេងតែនឹងរឿងសងសឹកឲ្យមិត្តភក្តិ ទើបមិនអាចវិភាគស្ថានការណ៍ឲ្យបានល្អិតល្អន់។

ប្រសិនបើប៊ុនធិវ ឆ្លាតជាងនេះបន្តិចគេនឹងដឹងភ្លាមថា ចូចូគឺជាអ្នកជំនាញផ្នែកយោធា ហើយចុះហេតុអ្វីបានជាចាត់ក្បួនទ័ពខុសរូបបែបដូច្នេះ? បើគ្រាន់តែយកចិត្តទុកដាក់ជាមួយគូតស៊ូតែបន្តិច ក៏នឹងអាចចាប់កំហុសបានភ្លាម។

អ្នកប្រាជ្ញបុរាណលោកបានពោលថា «រឿងល្ខោន បើសិនបើដាក់អារម្មណ៍ជ្រុលពេកក៏វាមិនសមទំនង ហើយការនិយាយអួតជ្រុលពេកក៏នឹងគ្មាននរណាគេជឿជាក់»។ នៅក្នុងប្រវត្តិសាស្ត្រចិនមានការកត់ត្រាហេតុការណ៍ដែលចូចូ កាត់ក្បាលប៊ុនធិវ ពិតមែនប៉ុន្តែមិនមានរឿងរ៉ាវដែលចូចូប្រើឧបាយកលបោកបញ្ឆោតប៊ុនធិវឲ្យបានចិត្តហើយវាយសម្រុកពីក្រោយនោះទេ។

ដូច្នេះមានន័យថាឡកួនចុង បាននិពន្ធក្នុងវគ្គនេះមកដោយខ្លួនឯង។ បើទោះបីជាមិនសូវសមទំនងក៏ពិតមែនតែដោយការបកស្រាយដ៏រស់រវើករបស់ឡកួនចុង ទើបចូចូ នៅតែជាចូចូ ដែលមានលក្ខណៈ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពិសេសដដែល គឺចូលចិត្តប្រើឧបាយកល ដោយពុំគិតថាគូតស៊ូមានលក្ខណៈបែបណានោះទេ ចំណែកឯប៊ុនធិវ ក៏នៅតែជាប៊ុនធិវដែលគិតតែពីការសងសឹកឲ្យឆាប់លឿន។ អាស្រ័យដោយហេតុនេះ ទើបចូឆូសម្លាប់ប៊ុនធិវបានសម្រេច។

ចូឆូបានបោះនុយមកបោកបញ្ឆោតសត្រូវ និងបានធ្វើឲ្យសត្រូវធ្លាក់ចូលទៅក្នុងអន្ទាក់លង់ខ្លួននៅក្នុងរណ្ដៅមរណៈ បន្ទាប់មកបង្ហាញនូវភាពទន់ខ្សោយឲ្យសត្រូវឃើញ ដើម្បីនឹងបញ្ឆោតសត្រូវឲ្យបានចិត្តធ្មេងកន្ទ្រើងឬឡើងចាងរហូតដល់បាត់បង់ក្បួនទ័ព។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ១៦

## អ្នកនៅក្នុងហេតុការណ៍
## តែងវង្វេង
## អ្នកនៅក្រៅហេតុការណ៍
## តែងមើលឃើញច្បាស់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅពេលប្រកួតកីឡាផ្សេងៗ កីឡាករទាំងសងខាងធ្វើការប្រកួតប្រជែងគ្នាយ៉ាងប្ដូរផ្ដាច់។ ម្នាក់ៗខំប្រឹងដណ្ដើមយកជ័យជម្នះរវាងគ្នាទៅវិញទៅមក រហូតខ្វះការពិចារណាឲ្យបានល្អិតល្អន់ និងសម្លឹងមើលមិនឃើញចំណុចខ្សោយរបស់ដៃគូម្ខាងទៀត ទើបមិនអាចកំណត់ដើម្បីយកឈ្នះបាន ប៉ុន្តែគ្រូបង្វឹកដែលនៅខាងក្រៅការប្រកួតតែងតែមើលឃើញចំណុខ្សោយរបស់ដៃគូបានច្បាស់ហើយរៀបចំផែនការទប់ទល់បានយ៉ាងស័ក្តិសមបំផុត។

ទាំងនេះក៏ដោយសារតែអ្នកដែលនៅក្នុងហេតុការណ៍ តែងតែត្រូវហេតុការណ៍ដែលច្របូកច្របល់នោះគ្របសង្កត់ជិត រហូតងើបមុខមិនរួច និងមិនអាចវែកញែកបែងចែកស្ថានការណ៍ពីចម្ងាយបានច្បាស់ប្រៀបបីដូចជាឈរនៅលើកំពូលភ្នំសម្លឹងទៅកាន់ទីទាបដូច្នោះឯង។

ការធ្វើសង្គ្រាមក៏ដូចគ្នាដែរ មេបញ្ជាការបើទោះបីជានៅជួរមុខយល់ស្ថានការណ៍ទាំងសងខាង និងក្ដោបបានស្ថានការណ៍យ៉ាងធាប់រហ័សក៏ដោយ ប៉ុន្តែពេលកំពុងតែច្បាំងគ្នានោះព័ត៌មានផ្សេងៗពិតជាច្រើនហួសពីការស្មាន។ ដូច្នេះហើយទើបធ្វើឲ្យមេបញ្ជាការវង្វេងវង្វាន់ជាពិសេសគឺស្ថិតនៅក្នុងស្ថានការណ៍ដែលត្រូវសម្រេចចិត្តភ្លាមៗ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

មេបញ្ជាការម្នាក់ពោលថា «សភាពគ្រោះថ្នាក់ និងការឈឺចាប់ផ្សេងៗតែងតែបិទបាំងស្មារតីរបស់យើងជានិច្ច ដូច្នេះហើយកាលដែលមនុស្សយើងនឹងមានគំនិតល្អៗនៅក្នុងស្ថានការណ៍ដ៏ពិបាកនោះ វាពិតជារឿងដ៏មហាពិបាកបំផុត»។ ព្រោះហេតុដូច្នេះមានតែទីប្រឹក្សាដែលជាអ្នកស្ទាត់ជំនាញខាងផ្នែកយុទ្ធសាស្ត្រប៉ុណ្ណោះដែលអាចមើលឃើញស្ថានការណ៍ទាំងអស់នោះ ហើយអាចចង្អុលបង្ហាញនូវយុទ្ធវិធីឆ្ពោះទៅរកភាពជោគជ័យដ៏ខ្ពង់ខ្ពស់បាន។

នៅក្នុងវគ្គទី៣០របស់រឿងនិទានសាមកុកមានឈុតឆាកដែលគួរឲ្យពិចារណាដូចតទៅ៖

ក្នុងរដូវប្រាំងគ.ស.២០០ អួនសៀវនិងចូចូ ម្នាក់ៗនាំគ្នាលើកទ័ពយ៉ាងច្រើនមកប្រយុទ្ធគ្នានៅតំបន់កួរត។ នៅពេលនោះអួនសៀវ មានកម្លាំងទ័ពនិងស្បៀងអាហារច្រើនជាងចូចូ រាប់សិបដងឯណោះ ពោលគឺអួនសៀវ មានកងទ័ពដល់ទៅ៧០ម៉ឺននាក់ ចំណែកឯចូចូ មានកម្លាំងទ័ពត្រឹមតែ៧ម៉ឺននាក់ប៉ុណ្ណោះ។

យើងអាចមើលឃើញបានយ៉ាងច្បាស់ក្រឡែតថា អួនសៀវគឺពិតជាមានប្រៀបជាង។ កាលនោះ ចូចូលើកទ័ពទៅវាយអួនសៀវជាច្រើនលើកតែមិនឈ្នះ ទើបសម្រេចចិត្តដកទ័ពថយមកបោះជំរំ ធ្វើជា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បន្ទាយដើម្បីរក្សាកងទ័ពឲ្យមានលំនឹង។ ចំណែកឯអួនសៀវវិញក៏បាន លើកទ័ពទៅវាយចូចូជាច្រើនលើកច្រើនសាដងដែរ ប៉ុន្តែត្រូវកងទ័ព របស់ចូចូ ទប់ទល់យ៉ាងអង់អាចក្លាហានទើបមិនអាចយកឈ្នះបាន។

កងទ័ពទាំងសងខាង ឈរជើងនៅតំបន់ក្វួរត អស់រយៈពេលជា ច្រើនខែរហូតទ័ពចូចូ អស់ស្បៀងអាហារ បានឲ្យធ្វើពួកកងទ័ពមានការ ស្រេកឃ្លានយ៉ាងខ្លាំង។ នៅចំពោះមុខស្ថានការណ៍ដ៏តឹងតែងដូច្នោះធ្វើ ឲ្យចូចូមានការស្ទាក់ស្ទើរក្នុងចិត្តភ្លាមមួយរំពេច។ ចិត្តមួយគិតចង់បោះ បង់តំបន់ក្វួរត ចិត្តមួយទៀតចង់នៅបន្ត ទើបសរសេរសំបុត្រពិភាក្សា ជាមួយស៊ុនហុក ដែលនៅការពារឯក្រុងហ៊ូតូ។ ពេលដែលស៊ុនហុក បានទទួលសំបុត្រក៏ប្រញាប់ឆ្លើយតបទៅចូចូ វិញដែលមានខ្លឹមសារដូច តទៅនេះ៖

«តាមតែលោកពោលមក ខ្ញុំយល់ថាការធ្វើសង្គ្រាមនៅតំបន់ ក្វួរតនោះមានភាពពិបាកខ្លាំងណាស់សម្រុកចូលក៏មិនបាន ដកថយក៏ មិនកើត។ តាមទស្សនរបស់ខ្ញុំយល់ឃើញថាអួនសៀវ លើកកម្លាំងទ័ព ច្រើនមកឈរជើងនៅតំបន់ក្វួរតគឺដើម្បីច្បាំងជាមួយលោកឲ្យដឹងចាញ់ ឈ្នះប្រសិនបើលោកបង្ហាញភាពទន់ខ្សោយឲ្យអួនសៀវ បានឃើញ អួនសៀវនឹងឆក់ឱកាសគ្រប់គ្រងដែនដីនេះ ការធ្វើសង្គ្រាមមួយលើក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នេះគឺជាជោគវាសនារបស់ប្រទេសជាតិទាំងមូល។ ទោះបីជាអួនសៀវមានកម្លាំងទ័ពច្រើនជាងយើងក៏ដោយ តែកងទ័ពរបស់អួនសៀវ សុទ្ធតែគ្មានបានការ ចំណែកឯលោកគឺជាអ្នកជំនាញផ្នែកយុទ្ធសាស្ត្រ ចុះហេតុអ្វីតស៊ូជាមួយអួនសៀវមិនបាន។ ពេលនេះថ្វីបើភាគីយើងមានកងទ័ពតិចជាងក៏ដោយ ប៉ុន្តែក៏នៅប្រសើរជាងសម័យដែលព្រះបាទហាន់កូចូ ធ្វើសង្គ្រាមជាមួយនឹងស្តេចឆប៉ាអង ទៅទៀត។ ដូច្នេះលោកគួរតែការពារបន្ទាយឲ្យគង់វង្សចាប់ក្របួចកអាវសត្រូវឲ្យណែន សូមកុំបណ្តោយឲ្យពួកវាសម្រុកចូលមកឲ្យសោះ ហើយរង់ចាំស្ថានការណ៍ល្អឲ្យដល់ទីបញ្ចប់។ ខ្ញុំសូមធានាថាស្ថានការណ៍នឹងមានការផ្លាស់ប្តូរពេលនោះលោកគប្បីក្រាញននៀលធ្វើសង្គ្រាមតទៅទៀត»។

បើតាមការកត់ត្រាផ្នែកខាងប្រវត្តិសាស្ត្រចិន ស៊ុនហុកធ្លាប់បានសរសេរសំបុត្របែបនេះទៅឲ្យចូចូក៏ពិតមែន តែសំបុត្ររបស់ស៊ុនហុកមួយច្បាប់នេះ ពិតជាសំបុត្រដែលវិភាគស្ថានការណ៍របស់អួនសៀវនិងចូចូបានច្បាស់លាស់។ ប្រសិនបើលើកមកវែកញែកជាលក្ខណៈទូទៅពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងទ័ពវិញនោះ ការដែលកងទ័ពទាំងពីរឈរជើងប្រឈមមុខដាក់គ្នាបែបនេះ វារមែងជាការឈរជើងដើម្បីដណ្តើមយកឱកាសល្អៗ សម្រាប់ធ្វើការវាយលុក។ បើភាគីណា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដកទ័ពថយភាគីនោះគឺជាអ្នកចាញ់ ចំណុចនេះចូចូ ប្រហែលជាយល់ច្បាស់។ ប៉ុន្តែដោយសារស្ថានការណ៍ពិបាកគាបសង្កត់ ទើបធ្វើឲ្យចូចូ វាស្ទើរវង្វាន់ជួយគ្នាពីស៊ុនហុក ដែលនៅឆ្ងាយពីសមរភូមិតែអាចមើលឃើញស្ថានការណ៍បានយ៉ាងច្បាស់ ហើយកំណត់នូវផែនការទាំងនោះថា«នៅពេលណាដែលស្ថានការណ៍ដល់ទីបញ្ចប់ហើយ វារមែងកើតមាននូវការផ្លាស់ប្តូរ ហើយឱកាសល្អៗក៏នឹងមកដល់ ពេលនោះលោកត្រូវតែនៅក្រាញនទៀលធ្វើសង្គ្រាមបន្តទៅទៀត»។

លិខិតមួយច្បាប់នេះប្រៀបបីដូចជាត្រីវិស័យដែលជួយបង្ហាញផ្លូវឲ្យចូចូ ដើរចេញពីស្បែអន្ធកាលដូច្នេះឯង។ ចូចូបានបញ្ជាឲ្យកងទ័ពតស៊ូស្លាប់រស់ដើម្បីការពារបន្ទាយឲ្យបានរឹងមាំជាទីបំផុត។ ក្រោយមកឱកាសល្អក៏មកដល់ពិតមែនគឺសង្គ្រាមដណ្តើមស្បៀងនៅស្រុកអួរចៅដែលជាសឹកសង្គ្រាមដ៏មហាល្បីរន្ទឺក្នុងប្រវត្តិសាស្ត្រចិន។

មានអ្នកប្រាជ្ញម្នាក់ពោលថា «ការទប់ទល់ផ្នែកកងទ័ព និងផ្នែកយុទ្ធសាស្ត្រ សុទ្ធតែជាឱកាសនៃការត្រួតពិនិត្យការប្រឹងប្រែងព្យាយាម និងភាពជឿជាក់របស់មេទ័ពតែប៉ុណ្ណោះ»។ ចំណែករឿងដែលសំខាន់បំផុតនោះគឺ ភាពហ្មត់ចត់ និងភាពអត់ធ្មត់របស់មេទ័ពក្នុងការពង្រឹងគោលជំហររង់ចាំឱកាសល្អដែលនឹងមកដល់ ហើយអ្នកដែលអាចធ្វើ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដូច្នេះបានត្រូវតែជាអ្នកដែលមិនវង្វេងក្នុងស្ថានការណ៍ ដែលមានភាពច្របូកច្របល់នៅក្នុងសមរភូមិ។

«ឯករាជ
ម្ចាស់ការ
សាងជោគវាសនា
សាងអាណាចក្រ
ឲ្យខ្លួនឯង»

www.facebook.com/7khmer
Fb page : Entertainment And Knowledge



ស៊ុន ហ៊ិរ

荀攸

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ១៧

# សង្គ្រាម ប្លន់យកស្បៀង នៅស្រុក អូចៅ

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ការធ្វើសង្គ្រាមអូសបន្លាយពេលវេលានៅស្រុកក្លួរត នោះភាគីណាមានស្បៀងច្រើនជាង ភាគីនោះត្រូវតែឈ្នះ ចំណែកឯភាគីណាខ្វះស្បៀងភាគីនោះគឺជាអ្នកដែលត្រូវតែចាញ់។

បន្ទាប់ពីចូឆូ បានធ្វើតាមបង្គាប់របស់ស៊ុនហុក ដែលជាទីប្រឹក្សាហើយនោះក៏ប្រើនយោបាយពង្រឹងគោលជំហរ ការពារបន្ទាយដើម្បីរង់ចាំឱកាសល្អៗមកដល់។ ក្នុងចន្លោះពេលនោះចូឆូ ក៏ធ្លាប់ប្លន់ស្បៀងរបស់អួនសៀវម្ដងដែរ ប៉ុន្តែដោយសារស្បៀងមានបរិមាណតិច ទើបមិនមានផលប៉ះពាល់ដល់អួនសៀវ សូម្បីបន្តិចតែអ្វីដែលប៉ះពាល់ធំនោះគឺ ខៅហ៊ុវដែលជាទីប្រឹក្សារបស់អួនសៀវ បានរត់គេចខ្លួនទៅសុំចុះចូលជាមួយចូឆូ ហើយបានផ្ដល់ផែនការដល់ចូឆូថា «ស្បៀងរបស់អួនសៀវទាំងអស់ គឺយកទៅរក្សាទុកនៅស្រុកអួចៅ ហើយប្រគល់ឲ្យអ៊ីខេងជាអ្នកមើលការខុសត្រូវ ប៉ុន្តែអ៊ីខេង ជាមនុស្សប្រមឹកមួយថ្ងៃៗគិតតែរឿងផឹកស្រា មិនយកចិត្តទុកដាក់ការពារស្បៀងសូម្បីបន្តិចតែលោកឧបរាជគួរតែជ្រើសរើសទាហានណា ដែលខ្លាំងពូកែ ឲ្យបន្លំខ្លួនធ្វើជាកងទ័ពរបស់អួនសៀវ សម្រុកចូលទៅឃ្លាំងស្បៀង ហើយដុតបំផ្លាញស្បៀងចោលតែម្ដង ហ៊ានធានាថា មិនដល់រយៈពេល៣ម៉ោងផងទេអួនសៀវនឹងទទួលបរាជ័យ»។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចូចូបានឮដូច្នេះ សែនសប្បាយចិត្តឥតឧបមា ប៉ុន្តែទៀវលៀវរួមទាំងកងទ័ពដទៃៗទៀត នាំគ្នានិយាយជំទាស់នឹងចូចូថា «សូមលោកម្ចាស់កុំទាន់អាលជឿទុកចិត្តខៅហ៊ុវឲ្យសោះ»។

ចូចូដែលជាមនុស្សពោរពេញទៅដោយល្បិចកលបែរជាឆ្លើយតបថា«ពេលនេះកងទ័ពរបស់យើងគ្មានស្បៀងអាហារទេ ហើយក៏មិនអាចឈរជើងបានយូរដែរ បើយើងមិនប្រើផែនការរបស់ខៅហ៊ុវ នោះទេប្រៀបដូចជាយើងអង្គុយរង់ចាំសេចក្តីស្លាប់ដូច្នេះឯង»។

ចូចូក៏សម្រេចចិត្តអនុវត្តតាមផែនការរបស់ខៅហ៊ុវ បញ្ជាឲ្យប្លន់យកស្បៀង និងចាត់វិធានការការពារបន្ទាយយ៉ាងរឹងមាំ។ ចូចូបញ្ជាឲ្យចូហងនិងស៊ុនហ៊ុវ ដឹកនាំទ័ពក្លាហានមួយក្រុមការពារបន្ទាយព្រមទាំងបែងចែកកម្លាំងពីរក្រុមទៀត ឲ្យពួនស្ទាក់ចាំនៅតាមផ្លូវទាំងសងខាង ដើម្បីការពារការវាយឆ្មក់របស់អួនសៀវរួមទាំងអុសនិងចំបើងសម្រុកចូលទៅប្លន់យកស្បៀងរបស់អួនសៀវ នៅស្រុកអួចៅ ក្នុងវេលាពាក់កណ្តាលអាធ្រាត្រ។ ពេលកងទ័ពរបស់ចូចូ មកដល់ស្រុកអួចៅក្នុងវេលាពាក់កណ្តាលអាធ្រាត្រហើយ ក៏ប្រញាប់ឡោមព័ទ្ធឃ្លាំងស្បៀង និងដុតបំផ្លាញភ្លាមមួយរំពេច។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

អួនសៀវលុះបានទទួលព័ត៌មាននោះភ្លាមគិតថា ចូចូប្រហែលជាបោះបង់បន្ទាយចោល។ ទើបដឹកនាំកម្លាំងទ័ពសំខាន់ៗសម្រុកចូលវាយលុកក្ងួរគ និងបញ្ជាឲ្យកងទ័ពសេះមួយចំនួនស្រូតរត់ទៅជួយនៅស្រុកអ្ជួថៅ។ ខណៈពេលដែលកងទ័ពរបស់ចូចូ កំពុងវាយលុកស្រុកអ្ជួថៅនោះ ពួកទ័ពសេះរបស់អួនសៀវ កាន់តែខិតមកជិតមេទ័ពម្នាក់របស់ចូចូ បានស្នើសុំឲ្យបែងចែកកម្លាំងទ័ពដើម្បីទប់ទល់ ប៉ុន្តែចូចូបែរជាបញ្ជាថា«សុំឲ្យពួកលោកសម្រុកចូលវាយលុកទៅមុខទៀតរង់ចាំឲ្យសត្រូវមកដល់ចាំត្រលប់មកទប់ទល់វិញក៏មិនយឺតពេលដែរ»។

ចូចូកាន់អាវុធយ៉ាងណែន ហើយហក់ចូលទៅវាយកម្ទេចឃ្លាំងស្បៀងឥតឈប់ឈរកាប់សម្លាប់កងទ័ពដែលនៅការពារស្រុកអ្ជួថៅស្លាប់ឲ្យពាសពេញតែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ។ ព្រះអគ្គីក៏ចាប់ផ្ដើមឆាបឆេះសន្ធោសន្ធៅឡើងទាំង៤ទិសស្បៀងអាហារទាំងអស់បានក្លាយទៅជាផេះឥតមានសេសសល់ឡើយ។

ព័ត៌មានប្លន់យកស្បៀងនៅស្រុកអ្ជួថៅនេះបានផ្សព្វផ្សាយទៅគ្រប់ទិសសព្វទីកន្លែង ដែលជាហេតុធ្វើឲ្យកងទ័ពរបស់អួនសៀវ មានការជ្រួលច្របល់និងកើតមានការខ្វែងគំនិតគ្នាផ្ទែកផ្ទែក្នុង និងឈានទៅរកការបាត់បង់ខាងផ្នែកសាមគ្គីភាព។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទៀវខាប់ត្រូវបានក្ដួរគៅ ដែលជាទីប្រឹក្សារបស់អួនសៀវ បាន បោទប្រកាន់និងស៊ើបអង្កេតរកកំហុសជាប្រចាំ។ ព្រោះហេតុដូច្នេះទើប ទៀវខាប់សម្រេចចិត្តនាំក្ដួឡាំ រត់គេចខ្លួនទៅចុះចូលជាមួយចូចូ។ ចាប់ តាំងពីពេលនោះមកសឹកសង្គ្រាមនៅស្រុកក្ដួរត កើតមាននូវការផ្លាស់ ប្ដូរស្ថានការណ៍ដោយ ចូចូគឺជាភាគីអ្នកឈ្នះ។

ការធ្វើសង្គ្រាមស្រុកក្ដួរត អាចចាត់ទុកថា ជាសង្គ្រាមដែលល្បី ឈ្មោះបំផុតនៅក្នុងទំព័រប្រវត្តិសាស្ត្រចិន ហើយការប្លន់យកស្បៀង នៅស្រុកអួចៅ គឺជាគន្លឹះនៃការផ្លាស់ប្ដូរស្ថានការណ៍ក្នុងសឹកសង្គ្រាម នាសម័យនោះ។ រឿងរ៉ាវដែលទាក់ទងនឹងការប្លន់យកស្បៀងនៅស្រុក អួចៅក្នុងរឿងនិទានសាមកុក ដូចគ្នាទៅនឹងឯកសារផ្នែកប្រវត្តិសាស្ត្រ ដែរ។ វាមានភាពខុសគ្នាត្រឹមតែបន្តិចបន្តួចតែប៉ុណ្ណោះ។

តើសង្គ្រាមប្លន់យកស្បៀងនៅស្រុកអួចៅបានផ្ដល់នូវគោល គំនិតអ្វីខ្លះដល់យើង? មានអ្នកជំនាញផ្នែកខាងយោធាបានពិពណ៌នា វែកញែកដូចតទៅនេះ៖

១/ ត្រូវបេះក្ដោបលក្ខខណ្ឌនៃការផ្លាស់ប្ដូរស្ថានការណ៍ឲ្យបាន ត្រឹមត្រូវនៅក្នុងខណៈពេលដែលកងទ័ពទាំងពីរភាគីកំពុងតែឈរជើង ប្រឈមមុខដាក់គ្នា។ ការពង្រឹងនូវគោលជំហរនិងការបេះអត់ធ្មត់របស់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

មេបញ្ហាការជាកត្តាដ៏សំខាន់បំផុត ប៉ុន្តែការក្រាញនៀលតស៊ូប្រយុទ្ធ មិនមែនជាគោលដៅនោះទេ វាគ្រាន់តែជាយុទ្ធវិធីមួយដែលនាំយើងទៅជួបនិងអាចក្តោបឱកាសដើម្បីផ្លាស់ប្តូរស្ថានការណ៍ប៉ុណ្ណោះឯង។

ម្យ៉ាងវិញទៀតការធ្វើសង្គ្រាមនៅក្នុងសមរភូមិយើងត្រូវប្រយុទ្ធគ្នាច្រើនចំណុចណាស់។ ដូច្នោះគួរដឹងថាតើចំណុចណាខ្លះដែលជាគន្លឹះអាចដឹកនាំទៅកាន់ការផ្លាស់ប្តូរស្ថានការណ៍ទាំងអស់បាន? ប្រសិនបើគ្មានចក្ខុវិស័យទេក៏គ្មានដំណោះស្រាយអ្វីដែរ។

ខៅហ៊ិវជាអ្នកជំនាញខាងផ្នែករៀបចំផែនការ និងទើបតែបានរត់ចេញពីបន្ទាយរបស់អួនសៀវថ្មីៗ ជាធម្មតាទេតែងតែដឹងនូវចំណុចខ្សោយនិងចំណុចខ្លាំងរបស់អួនសៀវ បានច្បាស់លាស់។ ឯចូចូជាអ្នកជំនាញផ្នែកខាងយោធា ដែលប្រកបទៅដោយចក្ខុវិស័យខ្ពស់ម្នាក់ផងដែរ។ ដូច្នេះនៅពេលដែលខៅហ៊ិវ ស្នើផែនការប្លន់យកស្បៀងនៅស្រុកអួថៅ ភ្លាមនោះ ចូចូក៏ធ្វើភ្លែត ហើយថែមទាំងផ្តល់ភាពសំខាន់រហូតដល់ថ្នាក់លើកកងទ័ពចេញទៅប្រតិបត្តិការធ្វើដោយខ្លួនឯងផ្ទាល់ទៀតផង។

២/ ខណៈពេលដែលកងទ័ពទាំងពីរភាគី បានបោះជំរំឈរជើងប្រឈមមុខដាក់គ្នានោះ ការកាត់ស្បៀងរបស់គូបដិបក្សចាត់ទុកថាជា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ផែនការដែលអាចផ្លាស់ប្តូរស្ថានការណ៍ និងទទួលបានផលទាន់ចិត្តនឹងភ្នែកតែម្តង។

សម័យបុរាណស្បៀងអាហារ គេចាត់ទុកថាជាចំណុចសំខាន់ក្នុងការធ្វើសង្គ្រាម។ ក្នុងតម្រាពិជ័យសង្គ្រាមនានាពោលទុកថា«គ្រប់ពេលដែលកងទ័ពបោះបន្ទាយប្រឈមមុខដាក់គ្នាដោយមិនដឹងចាញ់ឈ្នះនៅឡើយ បើភាគីណាដែលមានស្បៀងភាគីនោះជាអ្នកឈ្នះ»។

ដូច្នេះទើបត្រូវបន្ថែមកម្លាំងការពារកងដឹកជញ្ជូនស្បៀងឲ្យបានរឹងមាំមិនត្រូវបណ្តោយឲ្យសត្រូវបង្កហេតុឡើយ។ ប៉ុន្តែប្រសិនបើយើងដឹងផ្លូវដឹកជញ្ជូនស្បៀងរបស់ពួកសត្រូវ ត្រូវតែបញ្ជូនកងទ័ពក្លាហានទៅស្ទាក់ប្លន់ស្បៀងឲ្យបាន ពេលដែលពួកសត្រូវអស់ស្បៀង ពួកវារមែងលើកទ័ពថយ ហើយយើងគប្បីលើកទ័ពដេញតាមនឹងទទួលនូវភាពជោគជ័យយ៉ាងពិតប្រាកដ។

៣/ យុទ្ធវិធីនៅក្នុងការប្លន់យកស្បៀងនៅស្រុកអួចៅ ផ្តល់នូវគោលគំនិតដែលមានខ្លឹមសារជាច្រើនដូចជា៖

**ប្រតិបត្តិការរហ័សដូចផ្លេកបន្ទោរ**

គឺជាប្រតិបត្តិការដែលសត្រូវមិននឹកស្មានដល់។ ចូឆូបានជ្រើសរើសប្រតិបត្តិការនេះក្នុងពេលពាក់កណ្តាលអាធ្រាត្រថែមទាំងក្លែងបន្លំខ្លួនធ្វើជាកងទ័ពរបស់អួនសៀវ ដូច្នេះពួកសត្រូវមិនអាចចាប់កំហុស

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បាន។ លុះដល់ឱកាសល្អមកដល់ទើបសម្រុកបុកចូលវាយលុករហ័ស ដូចជាផ្លេកបន្ទោរអីចឹង។

## បង្រួមកម្លាំងវាយសង្គ្រុបត្រង់ចំណុចសំខាន់របស់ពួកសត្រូវ

នៅពេលដែលអួនសៀវ នាំទ័ពមកជិតដល់ ចូឆូបែរជាបញ្ជា ឲ្យប្រមូលកងទ័ពទាំងអស់សម្រុកចូលទៅវាយយកស្រុកអួចៅ ឲ្យបាន ដោយខំប្រឹងអនុវត្តទៅតាមផែនការឲ្យបានសម្រេចជាមុនសិន។ ក្នុង ពេលនោះប្រសិនបើចូឆូ បែងចែកកម្លាំងមកទប់ទល់ជាមួយពួកសត្រូវ ស្ថានការណ៍នឹងត្រូវប្រែប្រួលមិនខាន វាមិនត្រឹមតែវាយស្រុកអួចៅមិន បែកប៉ុណ្ណោះទេ វាថែមទាំងអាចត្រូវពួកសត្រូវឡោមព័ទ្ធ និងវាយកម្ទេច ក្លាយទៅជាជេះទៀតផង។

## ចេះប៉ាន់ស្មានឥរិយាបថរបស់សត្រូវ ហើយត្រៀមការទប់ទល់យ៉ាងហ្មត់ចត់

ចូឆូមិនត្រឹមតែជាអ្នកដែលចាប់អារម្មណ៍ទៅលើការធ្វើសង្គ្រាម ប៉ុណ្ណោះទេតែចូឆូក៏ជាអ្នកដែលផ្តល់សារសំខាន់ក្នុងផ្នែកយុទ្ធវិធីការពារ ខ្លួនផងដែរ។ មុនពេលចេញដំណើរ ចូឆូបានសន្និដ្ឋានថាកាលណាបើ ខ្លួនសម្រុកចូលទៅក្នុងស្រុកអួចៅ អួនសៀវប្រាកដជាឆ្លៀតឱកាស នោះសម្រុកចូលស្រុកក្អួរត។ ដូច្នេះហើយទើបដាក់ផែនការការពារ ស្រុកក្អួរតយ៉ាងរឹងមាំ។ ការត្រៀមខ្លួនរួចជាស្រេចបែបនេះគឺជាការធ្លុះ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បញ្ជាំងឲ្យឃើញពីភាពអស្ចារ្យរបស់មេដឹកនាំ។

«ខាំ

ចំណុច

ដ៏សើប

របស់សត្រូវ

ឲ្យជាប់

ស្ថានការណ៍

នឹង

ពិតជា

ផ្លាស់ប្តូរ

មិនខាន»

www.facebook.com/7khmer
Fb page : Entertainment And Knowledge




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ១៨

## ផ្សព្វផ្សាយ
## ពាក្យចចាមអារ៉ាម
## ដើម្បីបំបែក
## កម្លាំងសត្រូវ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បន្ទាប់ពីការប្លន់យកស្បៀងនៅស្រុកអួចៅហើយ ចូចូក៏ឆ្លៀត ឱកាសលើកទ័ពសម្រុកចូលវាយលុកកងទ័ពរបស់អួនសៀវ នៅគ្រប់ទីកន្លែងក្នុងស្រុកអួចៅ។ ក្រោយមកស៊ុនហ៊ិបានស្នើផែនការដល់ចូចូថា«ពេលនេះលោកគួរតែបញ្ជូនកងទ័ពមួយចំនួនធំ ឲ្យទៅផ្សព្វផ្សាយពាក្យចចាមអារ៉ាមថា«យើងនឹងលើកទ័ពទៅវាយស្រុកផៀបគុន ដែលជាផ្លូវដឹកជញ្ជូនស្បៀងរបស់អួនសៀវ និងលើកទ័ពមួយក្រុមធំទៀតទៅវាយស្រុកលិមយ៉ុងដើម្បីស្ទាត់ផ្លូវដកថយរបស់អួនសៀវ នៅពេលអួនសៀវបានដឹងព័ត៌មាននេះនឹងភ័យខ្លាចហើយបែងចែកទ័ពចេញជាពីរក្រុមដើម្បីទប់ទល់ជាមួយពួកយើង ពួកយើងនឹងឆ្លៀតឱកាសនេះវាយលុកអួនសៀវ ឲ្យបែកទ័ពខ្ចាត់ខ្ចាយវិនាសតែម្តង»។

ចូចូយល់ព្រមតាមផែនការ ក៏ប្រញាប់បញ្ជូនកងទ័ពមួយចំនួនធំឲ្យចេញទៅផ្សព្វផ្សាយពាក្យចចាមអារ៉ាមជាក្រុមៗ។ នៅពេលដែលអួនសៀវបានដឹងព័ត៌មានក៏មានការភ័យខ្លាចជាខ្លាំង ហើយក៏ប្រញាប់បញ្ជូនកងទ័ពពីរក្រុម មួយក្រុមឲ្យទៅជួយស្រុកផៀបគុន និងមួយក្រុមទៀតឲ្យទៅជួយស្រុកលិមយ៉ុងដូចការគិតទុកមែន។

ចូចូក៏បានឆ្លៀតឱកាស នៅពេលដែលកងទ័ពរបស់អួនសៀវបែងចែកកម្លាំងនោះ ប្រមូលកងទ័ពទាំង៨ក្រុមសំដៅឆ្ពោះទៅត្រង់វាយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

សង្គ្រាមបន្ទាយរបស់អួនសៅកាប់សម្លាប់កងទ័ពរបស់អួនសៅស្លាប់ពាសពេញលើធរណី។ កងទ័ពដែលនៅសេសសល់បាននាំគ្នារត់គេចខ្ចាត់ខ្ចាយ ចំណែកឯអួនសៅបាននាំបុត្រនិងភរិយារួមទាំងកងទ័ពជាង ៨០០នាក់រត់គេចខ្លួនតាមដងទន្លេហ្វាងហូ យ៉ាងមហាវេទនាជាទីបំផុត។

សុភាសិតចិនមួយបានពោលទុកថា«អ្នកដែលមានអំណាចមានបរិវារច្រើនទោះបីជាស្លាប់ទៅហើយក៏នៅតែមានអំណាច»។ អួនសៅក៏ដូចគ្នា បើទោះបីជាត្រូវបានចូចូ ដុតបំផ្លាញស្បៀងនៅស្រុកអូចៅរហូតធ្វើឲ្យស្ថានការណ៍នៅក្នុងសមរភូមិមានការប្រែប្រួលក៏ដោយតែអួនសៅដែលជាអ្នកមានកម្លាំងទ័ពច្រើននៅតែមានអំណាចឥទ្ធិពល។

ចូចូគិតចង់យកឈ្នះឲ្យបានឆាប់ ទើបបានបង្កើតស្ថានការណ៍ដែលមានប្រៀបគឺប្រមូលកម្លាំងទ័ពរបស់ខ្លួន ហើយបំបែកកម្លាំងទ័ពរបស់សត្រូវ។ ការប្រមូលទ័ពរបស់ខ្លួននឹងធ្វើឲ្យកម្លាំងទ័ពមានភាពរឹងមាំប្រៀបបីដូចជាក្តាប់ដៃឲ្យណែន ពេលវាយចេញទៅវានឹងពេញទៅដោយកម្លាំង ចំណែកការបំបែកកម្លាំងរបស់សត្រូវប្រៀបបីដូចជាធ្វើឲ្យសត្រូវលាតកណ្តាប់ដៃចេញពីគ្នាដូច្នោះដែរ។

ការប្រយុទ្ធគ្នាបែបក្តាប់ដៃនិងលាតដៃនេះ មិត្តអ្នកអានគិតមើលថាតើនរណាមានប្រៀបជាង? យុទ្ធវិធីនេះប្រសិនបើចូចូ មិនអាចធ្វើឲ្យ

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

សត្រូវលាតកណ្ដាប់ដៃចេញបានទេ ស្ថានការណ៍នឹងមិនមានការផ្លាស់ប្ដូរបានទេ គឺកណ្ដាប់ដៃទល់កណ្ដាប់ដៃឬជាការយកកម្លាំងខ្លាំងទល់នឹងកម្លាំងខ្លាំងនោះឯង។ ប៉ុន្តែប្រសិនបើចូចូ អាចធ្វើឲ្យអួនសៀវ អាចលាតកណ្ដាប់ដៃបាននោះកណ្ដាប់ដៃរបស់ចូចូ ក៏នឹងមានកម្លាំងអាចនឹងវាយបំបែកកងទ័ពរបស់អួនសៀវឲ្យបែកយ៉ាងស្រួល។

អ្នកដែលស្ទាត់ជំនាញក្នុងការបំបែកកម្លាំងទ័ព ប្រៀបបីដូចជាការបំបែកលុយដុំឲ្យទៅជាលុយរាយដូច្នោះដែរ។ វាមានតែការបំបែកកម្លាំងរបស់សត្រូវប៉ុណ្ណោះ ទើបអាចធ្វើឲ្យខ្លួនឯងមានកម្លាំងរឹងមាំបាន។ មួយវិញទៀតមានតែការផ្លាស់ប្ដូរការមានប្រៀបរបស់សត្រូវ ឲ្យក្លាយទៅជាការចាញ់ប្រៀបប៉ុណ្ណោះទេ ទើបអាចធ្វើការផ្លាស់ប្ដូរពីការចាញ់ប្រៀបរបស់យើងឲ្យក្លាយមកជាការមានប្រៀបវិញបាន។

ការធ្វើសឹកសង្គ្រាមផ្សេងៗ អ្នកជំនាញខាងផ្នែកយោធាតែងតែនិយាយពីគោលការណ៍ក្នុងការបំបែកកម្លាំងទ័ពរបស់សត្រូវ ដោយការប្រើយុទ្ធវិធីឬបង្កើតស្ថានការណ៍ដើម្បីបោកបញ្ឆោតឲ្យពួកសត្រូវផ្លាស់ប្ដូរកម្លាំងទ័ព។ បើពុំនោះទេក៏បញ្ជាកងទ័ពក្រុមតូចតាចមួយក្រុមឲ្យទៅវាយលុកផ្នែកខាងក្រោយរបស់សត្រូវដើម្បីឲ្យសត្រូវចាប់អារម្មណ៍និងបំបែកកម្លាំងទៅវាយលុកជាមួយក្រុមវាយឆ្មក់ទាំងនោះ។ ប៉ុន្តែសម្រាប់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ផែនការរបស់ស៊ុនហ៊ុវ បែរជាស្នើសុំឲ្យចូចូ ទៅបំបែកកម្លាំងទ័ពរបស់អួនសៀវ ដោយការបង្កើតពាក្យចចាមអារ៉ាមទៅវិញ។

ការប្រើផែនការផ្សព្វផ្សាយនូវពាក្យចចាមអារ៉ាមនេះបានទទួលភាពជោគជ័យ ដោយសារតែស្ថានការណ៍ក្នុងពេលនោះ មានសភាពអាក្រក់ចំពោះអួនសៀវ។ ម្យ៉ាងទៀតស្រុកឌៀបគុន និងស្រុកលិមយ៉ុងចាត់ទុកជាចំណុចយុទ្ធសាស្ត្រសំខាន់បំផុតរបស់អួនសៀវ ក្នុងការដកថយទៅកាន់ក្រុងហឺប៉ឺយ និយាយទៅវាប្រៀបបីដូចជាបំពង់ករបស់អួនសៀវដូច្នេះដែរ។ បើត្រូវច្របាច់ជាប់ហើយមានតែផ្លូវស្លាប់មួយតែប៉ុណ្ណោះដូច្នោះហើយទើបបានជាចូចូ រហ័សរហួនចំពោះបញ្ហានេះខ្លាំងដល់ថ្នាក់មិនគិតរកបាយទឹក។

ប្រសិនបើចូចូចាប់ចំណុចខ្សោយនេះមិនបានទេ ហើយចចេសបែរទៅជាផ្សព្វផ្សាយពាក្យចចាមអារ៉ាមខុសទំនងដូចជាថា នឹងទៅវាយលុកយកស្រុកផ្សេង ដែលមិនមែនជាចំណុចយុទ្ធសាស្ត្រសំខាន់របស់អួនសៀវ ជឿថាអួនសៀវ មុខជាមិនចាប់អារម្មណ៍ និងមិនបែងចែកកម្លាំងទ័ពទៅទប់ទល់យ៉ាងពិតប្រាកដ។

ក្រោពីនេះយុទ្ធសាស្ត្រនៃការវាយលុកអួនសៀវលើកនេះ មានលក្ខណៈខុសប្លែកពីការធ្វើសង្គ្រាមទូទៅផងដែរ។ ជាទូទៅពេលវាយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

លុកពួកសត្រូវ អ្នកជំនាញផ្នែកយោធាមិនវាយលុកចំពីមុខត្រង់ៗនោះទេគឺគេតែងតែធ្វើការវាយបោកបញ្ឆោតផ្នែកកណ្ដាល ហើយទើបវាយលុកសម្រុបផ្នែកឆ្វេងស្ដាំ តែសឹកសង្គ្រាមលើកនេះបន្ទាប់ពីចូចូ បំបែកកម្លាំងទ័ពរបស់សត្រូវបានហើយក៏សម្រុកចូលវាយពីមុខត្រង់ៗតែម្ដងដោយមិនបានធ្វើការវាយសម្រុបផ្នែកខាងៗទេ។

នៅក្នុងគម្រាពិជ័យសង្គ្រាមពោលទុកថា«ក្លែងបន្លំវាយនៅផ្នែកខាងៗ ដើម្បីវាយលុកផ្នែកកណ្ដាល។ ពួកសត្រូវនឹងមិនអាចនឹកស្មានដល់ ពេលដែលសត្រូវនឹកស្មានមិនដល់ ទើបយើងផ្ដើមវាយលុកផ្នែកពីមុខ គឺចំផ្នែកកណ្ដាល។ វាយចំពីមុខត្រង់ដើម្បីធ្វើការវាយលុកផ្នែកខាងៗពួកសត្រូវនឹងច្របូកច្របល់។ ពេលដែលសត្រូវច្របូកច្របល់ទើបយើងវាយលុកផ្នែកខាងៗ»។

វិធីវាយលុកអួនសៀវរបស់ចូចូលើកនេះប្រើផែនការ«ក្លែងបន្លំវាយលុកផ្នែកខាងៗដើម្បីធ្វើការវាយលុកចំពីមុខ» ដែលធ្វើឲ្យមានការចាប់អារម្មណ៍ពីមនុស្សជំនាន់ក្រោយយ៉ាងខ្លាំងមហិមា។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

«មុននឹង
យក
ពងមាន់
ទៅ
ធ្វើម្ហូប
ត្រូវតែ
បំបែក
វា
ជាមុនសិន»



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ១៩

## ទឹកចិត្ត
## អ្នកនយោបាយ

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

«ដឹងបាញ់ ដឹងឈ្នះ និងចេះឲ្យអភ័យទាំងនេះគឺជាទឹកចិត្តរបស់កីឡាករ និងជាទឹកចិត្តអ្នកនយោបាយទាំងឡាយ» ។

គេតែងតែនិយាយតៗគ្នាថា សង្គ្រាមគឺជាយុទ្ធសាស្ត្របន្តពីការតស៊ូផ្នែកនយោបាយ។ ដូច្នេះហើយ ទើបអ្នកជំនាញផ្នែកខាងយោធាត្រូវតែមានចក្ខុវិស័យនិងទឹកចិត្តឲ្យដូចនឹងកីឡាករឬអ្នកនយោបាយ។

ក្នុងវគ្គទី៣០របស់និទានសាមកុក និយាយពីឈុតឆាកបញ្ចប់សង្គ្រាមក្នុងស្រុកក្តួរត និងការធ្វើសឹកដើម្បីបោសសម្អាតកងទ័ពរបស់អួនសៀវឲ្យអស់។ នៅក្នុងខណៈពេលដែកឆេរបន្ទាយរបស់អួនសៀវ ចូចូបានជួបប្រទះសំបុត្រមួយដុំធំ ដែលជាសំបុត្រកូនចៅរបស់ខ្លួនលួចសរសេរផ្ញើទៅសុំការចុះចូលជាមួយអួនសៀវ ពេលនោះមានអ្នកស្នើសុំឲ្យចូចូ ធ្វើការស៊ើបរកអ្នកដែលលួចសរសេរសំបុត្រទាំងនោះឲ្យបានឃើញច្បាស់ហើយប្រហារជីវិតចោល ក៏ប៉ុន្តែ ចូចូមិនយល់ស្របតាមសំណើរនេះទេ។

ចូចូបែរជានិយាយថា «ក្នុងពេលដែលអួនសៀវ កំពុងរុងរឿងនោះសូម្បីតែរូបខ្ញុំផ្ទាល់ស្ទើរតែមិនចង់រួចជីវិតផង ហើយចុះទម្រាំជីវិតអ្នកដទៃនោះ?»។ ដូច្នេះហើយទើបចូចូ បញ្ជាឲ្យដុតសំបុត្រទាំងអស់នោះចោលដោយមិនធ្វើការស៊ើបអង្កេតរកឫសគល់អ្វីទាំងអស់ ព្រោះហេតុនេះទើបធ្វើឲ្យកងទ័ពរបស់ចូចូ មិនមានការបែកបាក់សាមគ្គីគ្នា។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ្លឹមសារក្នុងវគ្គនេះបានឆ្លុះបញ្ចាំងឲ្យឃើញថាចូចូ ជាអ្នកជំនាញខាងផ្នែកយោធានិងជាអ្នកនយោបាយអស្ចារ្យពិតមែន។ បើទោះបីជាក្នុងផ្នែកដទៃ ចូចូគឺហាក់ដូចជាឃោរឃៅខ្លះប៉ុន្តែនៅក្នុងផ្នែកនៃការប្រើមនុស្សវិញ ចូចូសមគួរនឹងទទួលបាននូវការលើកតម្កើងឲ្យក្លាយជាអ្នកនយោបាយដ៏មហាអស្ចារ្យ ព្រោះចូចូគឺជាមនុស្សដែលមិនចេះគិតចងអាឃាតព្យាបាទដល់បច្ចាមិត្តដែលមកសុំចុះចូលជាមួយខ្លួន ដូចយ៉ាងការធ្វើសង្គ្រាមជាមួយនឹងទៀវស៊ិវ ជាដើម។ កាលនោះទៀវស៊ិវ បានលើកទ័ពមកកាប់សម្លាប់ចូអ៉ាន ដែលជាកូនច្បងនិងចូអាន់ ដែលជាចៅរួមទាំងសម្លាប់ទៀនអ៊ុយដែលជាមេទ័ពឯកនិងបានបាញ់ព្រួញត្រូវចំដៃស្ដាំរបស់ខ្លួនផងដែរ។ ក្រោយមកទៀវស៊ិវ បានជឿពាក្យណែនាំរបស់កាសៀងក៏ព្រមចុះចូលជាមួយចូចូ ចូចូមានការត្រេកអរជាខ្លាំង ហើយចេញមកទទួលស្វាគមន៍ទៀវស៊ិវយ៉ាងកក់ក្ដៅបំផុត។

ចូចូមិនត្រឹមតែមិនគិតពីការសងសឹកឲ្យកូនប្រុសប៉ុណ្ណោះនោះទេថែមទាំងភ្ជាប់សាច់ឈាមជាមួយគ្នាដោយការរៀបចំអាពាហ៍ពិពាហ៍ឲ្យកូនប្រុសកូនស្រីរវាងគ្រួសារទាំងពីរ និងតែងតាំងឲ្យទៀវស៊ិវ ធ្វើជាមេទ័ពទៀតផង។ ឥរិយាបថបែបនេះធ្វើឲ្យទៀវស៊ិវមានការរំភើបយ៉ាងខ្លាំង ហើយបានតបស្នងសងគុណចូចូវិញដោយការសាងគុណសម្បត្តិ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក្នុងសង្គ្រាមបង្ក្រាបសត្រូវនៅភាគខាងជើង។ ដូច្នេះអ្នកដែលគិតចង់ធ្វើការធំត្រូវតែធ្វើចិត្តគំនិតរបស់ខ្លួនឲ្យធំទូលាយ។

នៅសម័យឈុនឈិវចានក្វរ ស្តេចជិនវើនកុង បានត្រាច់ចរទៅរស់នៅក្នុងស្រុកផ្សេងៗរហូតដល់១៩ឆ្នាំ។ ក្រោយមកទើបបានឡើងគ្រងរាជ្យដើម្បីបានកសាងប្រទេសឲ្យមានសន្តិភាព។ ព្រះអង្គបានប្រើនយោបាយអូសទាញសត្រូវពីអតីតកាល ឲ្យមកធ្វើការងារជាមួយនឹងព្រះអង្គ។ ទង្វើនេះធ្វើឲ្យបរិវារស្តេចមុនៗជឿជាក់ថាស្តេចជិនវើនកុងពិតជាគ្មានការចងគំនុំគុំកួនជាមួយពួកខ្លួនពិតមែន ទើបធ្វើឲ្យព្រះអង្គបានទទួលការគោរពស្រឡាញ់និងការគាំទ្រពីបណ្តាអាណាប្រជានុរាស្ត្រទាំងមូល។

នៅក្នុងសម័យនៃស្តេចឈួជួង ដែលទើបឡើងមកគ្រងរាជ្យថ្មីៗក្រោយពីព្រះអង្គបានបង្ក្រាបពួកសត្រូវអស់ហើយ ព្រះអង្គអនុញ្ញាតឲ្យនាងស៊ីជី ដែលជាស្នំឯក និងជាស្ត្រីដែលព្រះអង្គទ្រង់សព្វព្រះទ័យជាងគេបំផុតនោះដើរចាក់ស្រាដល់មន្ត្រីគ្រប់គ្នា។ ស្រាប់តែមានខ្យល់បក់មកបណ្តាលឲ្យភ្លើងក្នុងពិធីជប់លៀងរលត់អស់។

មានមន្ត្រីខ្លះ លួចលូកលាន់ខ្លួនប្រាណនាងស៊ីជី នាងស៊ីជីបានឆ្លៀតឱកាសចាប់យករំយោលមួករបស់មន្ត្រីខិលខូចទាំងអស់នោះមក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ហើយក្រាបទូលដល់ស្តេចឈូជួង ដើម្បីឲ្យព្រះអង្គចាប់មន្ត្រីណាដែលគ្មានរំយោលមួកយកមកកាត់ទោស ប៉ុន្តែព្រះអង្គបែរជាសើចឲ្យលាន់រំពង ហើយខ្សឹបប្រាប់មន្ត្រីទាំងអស់ដោះបន្ទោងមួកចេញគ្រប់គ្នាព្រមទាំងបញ្ជាឲ្យមន្ត្រីទាំងអស់ផឹកស្រាឆ្លងពិធីជប់លៀងបន្តយ៉ាងសប្បាយរីករាយ។

នៅពេលដែលមន្ត្រីទាំងអស់ ដោះរំយោលមួកអស់ហើយទើបព្រះអង្គទ្រង់បញ្ជាឲ្យដុតភ្លើងប្រទីបសាជាថ្មីឡើងវិញ។ ពេលនេះមើលមិនដឹងថា«នរណាជាមន្ត្រីខិលខូចទេ» ធ្វើឲ្យនាងស៊ីជី គ្រោធខឹងជាខ្លាំងទើបព្រះអង្គនិយាយលួងលោមថាមនុស្សយើងគឺវាអីចឹងឯង តែកាលណាស្រាចូលមាត់ហើយតែងតែមានភាពពិបាកក្នុងការទប់អារម្មណ៍ខ្លួនឯងណាស់។

ប្រសិនបើព្រះអង្គដាក់ទោសមន្ត្រីទាំងអស់នោះ ពួកគេងទំពនឹងអស់កម្លាំងចិត្ត ហើយបើពេលណានគរអ៊ូ លើកទ័ពមកឈ្លានពានលើនគរឈូនោះ តើនរណានឹងលះបង់ជីវិតដើម្បីជាតិហ៊ានប្តូរជីវិតទប់ទល់ជាមួយសត្រូវសាងគុណសម្បត្តិដល់នគរឈូនោះ?

ដូច្នេះមេដឹកនាំគប្បីធ្វើចិត្តឲ្យទូលាយទើបអាចនឹងបង្កើតសាមគ្គីភាពផ្ទៃក្នុងបាននិងអាចប្រើប្រាស់មនុស្សបានយ៉ាងស្រួល។ ម្យ៉ាងទៀត

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នោះជ័យជម្នះដែលទទួលបាននៅក្នុង សមរភូមិទាំងនោះគឺជាលទ្ធផល ដែលពាក់ព័ន្ធគ្នាជាមួយសាមគ្គីផ្ទៃក្នុងយ៉ាងពិតប្រាកដ។

នៅក្នុងសម័យនោះសូម្បីតែចូចូ បានទទួលជ័យជម្នះពីសង្គ្រាម នៅស្រុកក្លួតេ ហើយក៏ដោយ ប៉ុន្តែអួនសៀវ នៅតែមានអំណាចអាច គ្រប់គ្រងដែនដីភាគខាងជើងចំនួន៤ស្រុកយ៉ាងរឹងមាំនៅឡើយ ទើបចូចូ ឆ្លៀតឱកាសក្នុងពេលដែលជោគជ័យនោះសម្រុកទៅមុខទៀត ដោយ ការប្រមូលបានកម្លាំងដែលមានសភាពរឹងមាំស្រាប់ ដើម្បីវាយកម្ទេច អួនសៀវរហូតដល់អាចរឹបអូសយកទឹកដីនៅភាគខាងជើងបាន។

ស្របពេលនេះដែរប្រសិនបើយើងសម្លឹងមើលហេតុការណ៍ឲ្យ បានសព្វជ្រុងជ្រោយ យើងនឹងអាចឃើញច្បាស់ថានៅខាងមុខចូចូមាន អួនសៀវ ហើយនៅពីខាងក្រោយមានឡៅពៀវ ឡៅពី និងស៊ុនគួន ដែលចេះតែរឹងមាំទៅរឿយៗ បើចូចូមិនខំប្រឹងពង្រីកឥទ្ធិពលរបស់ខ្លួន ទេ គិតតែពីធ្វើសឹកសង្គ្រាមក្នុងស្រុករបស់ខ្លួននោះ នឹងគ្មានផ្លូវនឹងគេច ផុតពីភាពលំបាកបានឡើយ។

ដូច្នេះ ស្ថិតនៅក្នុងស្ថានការណ៍បែបនេះ អ្នកដឹកនាំត្រូវតែមាន ចក្ខុវិស័យខ្ពស់ អាចសម្លឹងមើលហេតុការណ៍បានវែងឆ្ងាយ អាចនឹកគិត ដល់ផលប្រយោជន៍រួមបានសព្វជ្រុងជ្រោយ អាចប្តូរពីភាពបរាជ័យឲ្យ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក្លាយជាភាពជោគជ័យបាន និងអាចរីតបន្តឹងចំណងសាមគ្គីភាពផ្ទៃក្នុងឲ្យកាន់តែរឹងមាំឡើងៗទើបអាចទទួលបានជោគជ័យជាបន្តបន្ទាប់។

ចំណុចទាំងអស់នេះចូចូហាក់បីដូចជាច្បាស់លាស់ណាស់។ ជាពិសេស ចូចូសម្លឹងមើលឃើញច្បាស់ក្នុងចំណុចត្រង់ថាអ្នកដែលបានសរសេរសំបុត្រទៅសុំចុះចូលជាមួយអួនសៀវ នោះមិនមែនជាមនុស្សតែម្នាក់ទេ ប្រសិនបើចូចូស៊ើបរកឫសគល់ពិតមែននោះតើស្ថានការណ៍នឹងអូសបន្លាយទៅជាយ៉ាងណា?

ជាការពិត មនុស្សដែលខ្លាំងពូកែមួយចំនួននឹងរត់គេចខ្លួនទៅនៅជាមួយអ្នកដទៃដែលអាចធ្វើឲ្យមានការប៉ះពាល់ដល់ចូចូយ៉ាងខ្លាំង ប៉ុន្តែប្រសិនបើចូចូដុតបំផ្លាញសារសម្ងាត់នោះចោល អ្នកចម្បាំងភាគច្រើន ក៏មានភាពកក់ក្ដៅចង់រស់នៅជាមួយចូចូ យូរអង្វែងតទៀត។

ការធ្វើបែបនេះ ចូចូមានតែផ្លូវចំណេញពុំមានខាតបង់អ្វីសូម្បីតែបន្តិចហើយការផ្ដល់នូវភាពជឿជាក់ដល់កងទ័ពរបស់ខ្លួន វានឹងធ្វើឲ្យកងទ័ពរឹតតែមានកម្លាំងតស៊ូប្រយុទ្ធកាន់តែខ្លាំងឡើងៗ។

កាលដែលចូចូ ដុតបំផ្លាញសារសម្ងាត់ចោលនោះ គឺធ្វើដោយសុទ្ធចិត្តគ្មានចេតនាអ្វីបង្កប់នោះទេ។ យើងអាចមើលឃើញនៅត្រង់ចំណុចដែលចូចូ ឃើញសារសម្ងាត់ហើយក៏បញ្ជាឲ្យដុតបំផ្លាញចោល

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ភ្លាមៗ នេះជាការបង្ហាញឲ្យឃើញពីចិត្តគំនិតដ៏ធំទូលាយរបស់ចូចូ។

ផ្ទុយទៅវិញ បើមេបញ្ជាការជាមនុស្សមានចិត្តចង្អៀតចង្អល់ គ្មានចក្ខុវិស័យ មិនចេះឲ្យអភ័យដល់អ្នកដទៃ រមែងកើតមានសង្គ្រាមផ្ទៃក្នុង បែកបាក់សាមគ្គីគ្នាយ៉ាងពិតប្រាកដ។ មេដឹកនាំណាដែលមានចិត្តចង្អៀតមិនអនុញ្ញាតឲ្យកូនចៅរបស់ខ្លួនមានគំនិតគិតខុសពីខ្លួននិងពេលដែលកូនចៅធ្វើអ្វីខុសបន្តិចក៏ចោទប្រកាន់ទោសភ្លាម ទីបំផុតនឹងភ្លេចនូវគោលដៅផ្នែកយុទ្ធសាស្ត្រ និងគិតតែពីរឿងដែលគ្មានប្រយោជន៍បន្តិចតែរឿងផ្ដេសផ្ដាសដែលជាហេតុនាំឲ្យមានបញ្ហាដល់អ្នកដែលរស់នៅក្បែរខ្លួន។ មនុស្សដែលមានចិត្តចង្អៀតបែបនេះ មិនអាចធ្វើការធំដុំបានសម្រេចឡើយ។

បើនិយាយទៅ ចូចូក៏ជាមនុស្សដែលធ្លាប់កាប់សម្លាប់មនុស្សដើម្បីសងសឹកឲ្យបិតារបស់ខ្លួនយ៉ាងសាហាវឃោរឃៅនៅស្រុកឈីជិវ និងក្រោយមកទៀតក្នុងសង្គ្រាមស្រុកហ៊ូតូដែរ។ ចូចូបានសម្លាប់មនុស្សបរិសុទ្ធអស់ជាច្រើននាក់។ ភាពដ៏សាហាវព្រៃផ្សៃនេះធ្វើឲ្យមនុស្សជំនាន់ក្រោយធ្វើការរិះគន់យ៉ាងខ្លាំង។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ២០

## ឧបាយកល

## ពួនស្ទាក់វាយលុក

## ទាំង១០ទិស

## របស់

## ឆៀយុក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅពេលនិយាយដល់ឧបាយកល «ពួនស្ទាក់វាយលុកទាំង១០ទិស» ធ្វើឲ្យយើងនឹងនឹកឃើញទៅដល់សង្គ្រាមចុងក្រោយរវាងលិវប៉ុង (ឡៅប៉ុង) និងសៀងវ៉ី(ធប៉ាអង)នៅស្រុកកៃសៀ។

បានពួគេនិយាយតគ្នាមកថាក្នុងសង្គ្រាមសម័យនោះហាន់សីនដែលជាមេទ័ពធំបានដឹកនាំកងទ័ព៣សែននាក់ ទៅពួនស្ទាក់គ្រប់ទិសទាំង១០ ហើយបានបញ្ជូនព័ត៌មានតៗគ្នាតែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ។ នៅទីបំផុត អាចយកឈ្នះកងទ័ពរបស់សៀងវ៉ី និងបានធ្វើឲ្យសៀងវ៉ីទាល់ច្រករកផ្លូវចេញលែងបាន។

ឧបាយកល «ពួនស្ទាក់វាយលុកទាំង១០ទិស» របស់ហាន់សីនល្បីល្បាញមកជាយូរហើយរហូតមកដល់សម័យរាជវង្សម៉ិង មានអ្នកប្រាជ្ញម្នាក់បាននាំយកឧបាយកលនេះមកនិពន្ធជារឿងល្ខោន និងតែងជាទំនុកច្រៀងយ៉ាងពីរោះរណ្ដំ។

ក្នុងវគ្គទី៣១ នៃរឿងនិទានសាមកុក ឡកួនចុងក៏បានសរសេរពីឧបាយកលនេះទុកដូចដែរ។ ខ្លឹមសារទាំងនោះមានតទៅនេះ៖

ក្រោយសង្គ្រាមនៅស្រុកក្អួរត ចប់ស្រេចបាច់ហើយ។ ចូឆូបានសម្រួលកងទ័ពសាជាថ្មីឡើងវិញ ហើយបានលើកទ័ពឆ្លងទន្លេហ្វាងហូដើម្បីដេញតាមអួនសៀវ ឯអួនសៀវ ទ្រាំមើលភាពបរាជ័យរបស់ខ្លួន

www.facebook.com/7khmer
Fb page : Entertainment And Knowledge

លែងបាន ទើបប្រមូលកងទ័ពរបស់ខ្លួនពីស្រុកទាំង៤ក្នុងភាគខាងជើង មកឈរជើងនៅតំបន់សងតេង គិតនឹងប្ដូរស្លាប់រស់ជាមួយចូចូម្ដងទៀត។

ចូចូបានកោះហៅទីប្រឹក្សាទាំងអស់មកពិភាក្សាគ្នាដើម្បីនឹងដាក់ផែនការវាយកម្ទេចអួនសៀវ ឲ្យដល់ឫស ។ ពេលនោះធៀយុកក៏បានស្នើផែនការ«ពួនស្ទាក់វាយលុកទាំង១០ទិស»ដល់ចូចូ។

ធៀយុកប្រាប់ចូចូ ឲ្យដកថយទ័ពមកនៅត្រង់មាត់ទន្លេហើយចាំបែងចែកកងទ័ពជា១០កងពលដើម្បីត្រៀមវាយលុក។ បន្ទាប់មកប្រើកងទ័ពមួយក្រុមឲ្យទៅបោកបញ្ឆោតកងទ័ពរបស់អួនសៀវ ឲ្យមកជាប់អន្ទាក់«ពេលដែលកងទ័ពរបស់យើងគ្មានផ្លូវដកថយនឹងតស៊ូស្លាប់ក្នុងសង្គ្រាមលើកនេះធានាថានឹងឈ្នះអួនសៀវយ៉ាងពិតប្រាកដ»។

ចូចូក៏អនុវត្តតាមផែនការនោះភ្លាម ដោយបញ្ជាឲ្យកងទ័ពបែងចែកចេញជាពីរក្រុម មួយក្រុមមាន៥កងពល។ នៅក្រុមខាងឆ្វេងដឹកនាំដោយហែហួទុន ទៀវលៀវ លិទៀន ង៉ាក់ជិន និងហែហួអៀន ចំណែកមេទ័ពផ្នែកនៅខាងស្ដាំមាន ចូហង ទៀវខាប់ ស៊ិឡុង អ៊ិគិម និង កូឡាំកងទ័ពទាំង១០ក្រុមបាននាំគ្នាទៅពួនស្ទាក់ផ្លូវទាំងសងខាង។ បន្ទាប់មកបញ្ជាឲ្យខៅធូដឹកនាំទ័ពមួយក្រុមផ្សេងទៀតទៅបោកបញ្ឆោតអួនសៀវ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅពេលដែលអួនសៀវ បានលើកទ័ពមកដល់ ខៅធូនាំកងទ័ពរត់គេច រហូតមកដល់មាត់ច្រាំងទន្លេ។

ចូចូឃើញឱកាសល្អមកដល់ ក៏ស្រែកប្រាប់កងទ័ពថា «កងទ័ពទាំងឡាយនៅមុខគ្មានច្រកចេញទេ ហើយនៅខាងក្រោយក៏គ្មានច្រកចេញដែរ បើមិនតស៊ូស្លាប់រស់ទេនឹងត្រូវស្លាប់»។ ពួកកងទ័ពក៏ស្រែកស្រុះគ្នាថា«ស៊ូស្លាប់ៗៗៗ»ហើយបានសម្រុកចូលទៅវាយកម្ទេចកងទ័ពរបស់អួនសៀវពេញទំហឹង កងទ័ពរបស់អួនសៀវក៏កើតជាចលាចលប្រញាប់ដកទ័ពថយ ប៉ុន្តែមិនទាន់ដកទ័ពថយបានស្រួលបួលផង ក៏ឮសម្លេងស្គរជ័យលាន់កងរំពងពីផ្នែកខាងឆ្វេង។ ពេលនោះកងទ័ពរបស់ហែហួអៀននិងកូឡាំ ដែលពួនចាំនៅផ្នែកខាងឆ្វេងក៏បានស្ទុះព្រូចេញមករត់កាប់សម្លាប់កងទ័ពរបស់អួនសៀវយ៉ាងចាស់ដៃ។

អួនសៀវ នាំកងទ័ពមួយក្រុមពុះពារបានចេញពីការឡោមព័ទ្ធនោះរហូតទទួលគ្រោះថ្នាក់ហូរឈាមសស្រាក់ពេញទាំងខ្លួន រត់ទៅមុខមិនទាន់បាន៥គីឡូម៉ែត្រផងកងទ័ពឆាក់ជីននៅផ្នែកខាងឆ្វេងនិងកងទ័ពអ៊ិគិមដែលនៅផ្នែកខាងស្តាំបានស្ទុះចេញមកទៀត បន្ទាប់មកកងទ័ពដែលពួនស្ទាក់ចាំនាំគ្នាចេញមកជាបន្តបន្ទាប់កាប់សម្លាប់ទាហានរបស់អួនសៀវ ស្លាប់រាយពាសពេញគរលើដីគ្មានសេសសល់ម្នាក់ឡើយ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ជាទូទៅការពួនស្ទាក់វាយលុកសត្រូវច្រើនតែប្រើកម្លាំងតិចជាង ទៅវាយលុកសត្រូវដែលមានកម្លាំងច្រើនជាង។ គោលបំណងនៅក្នុងយុទ្ធសាស្ត្រនេះគឺវាយកម្ទេចសត្រូវឲ្យខ្ទេចតែម្តង មិនបន្សល់ទុកសូម្បីតែម្នាក់។

ក្នុងសម័យបុរាណ នៅមិនទាន់មានអាវុធទំនើបៗ ដូចបច្ចុប្បន្ននៅឡើយ។ បើចង់កម្ទេចពួកសត្រូវឲ្យផុតពូជ មិនមែនជារឿងងាយទេ ដូច្នេះហើយ ទើបគេប្រើវិធី «ពួនស្ទាក់ចាំវាយលុកគ្រប់ទិសទីដើម្បីឲ្យបានសម្រេចទៅតាមគោលដៅរបស់ខ្លួន»។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# សរុប

## គម្រាពិជ័យសង្គ្រាមសាមកុក

## ទាំងម្ដែចចំណុច

## ឱ្យជាពាក្យកាព្យ

## ទាយចាំ

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

មួយកលយុទ្ធការឡោមព័ទ្ធ ពីរនោះបែនបត់តាមឱកាស
បីរួបរួមគ្នាយ៉ាងល្អល្អះ ឃើញចំណុចឈ្នះចងសម្ព័ន្ធ។
បួនខ្ទីបង្គន់បន្ទោបង់ រួចហើយវែកបួងដោយរួសរាន់
ដីងហេតុមិនទាន់អាសន្នដល់។
ប្លន់យកផ្ទះសោះតែបំភាន់
ប្រាំឧបាយកលនៃស្រីស្រស់ ឯប្រាំមួយនោះញោះជាកល
ប្រាំពីរបញ្ឆោតឲ្យខ្វាយខ្វល់ ខ្លាពីរទប់ទល់ប្រខាំគ្នា។
ប្រាំបីឧបាយប្រដេញខ្លា ខាំសុនខាយ៉ាងពុះពារ
ប្រាំបួនទស្សនផ្ទែកឃោជា កបកលមាយានៃស៊ុនសេក។
ដប់ស្រែកខាងឆ្វេងលេងខាងស្តាំ ដប់មួយមិនចាំឲ្យយូរពេក
សិល្បៈការដេញល្អអនេក មិនចាំថ្ងៃស្អែកដេញប្រហារ។
ដប់ពីរព័តិមានដែលក្លែងក្លាយ ជាគ្រោះអន្តរាយយ៉ាងអស្ចារ្យ
តែអ្នកដឹកនាំដ៏ហានក្លា ប្រើប្រាស់ប្រាជ្ញាវិភាគត្រូវ។
ដប់បីដែនការលោកតាន់កុង អាចឈ្នះទាំងស្រុងលើសត្រូវ
ដេញវាយចូងចូនៅតាមផ្លូវ លិប៉ូមិនទៅត្រូវមរណា។
ដប់បួនទៀវហ៊ុយចិត្តឆេវឆាវ ធ្លាប់តែសាហាវអ័ព្ទប្រាជ្ញា
វាយដំកូនចៅសេពសុរា ចេះប្រើប្រាជ្ញាត្រូតស៊ីគ្នា។
ដប់ប្រាំបញ្ឆោតបច្ចាមិត្ត ឲ្យគេបានចិត្តភ្លេចអង្គា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

លបលួចប្រហារកុំរួញរា សត្រូវច្បាស់ជាបរាជ័យ។
ដប់ប្រាំមួយហេតុការណ៍ចលាចល អ្នកជិតវិលវល់មិនដឹងអ្វី
តែអ្នកនៅឆ្ងាយភ្លឺដូចថ្ងៃ អ្នកជិតនោះនៅតែងវង្វេង។
ដប់ប្រាំពីរប្ដូនស្បៀងនៅអូរថៅ កម្ចាត់សត្រូវឲ្យចម្បែង
បានស្បៀងមានល្បិចលេចស្ញប់សែង សត្រូវវង្វេងក្នុងអន្ធការ។
ដប់ប្រាំពីរផ្សព្វផ្សាយជាដំណឹង ប្រកាសឲ្យដឹងដល់បច្ចា
ព័ត៌មានមិនពិតឥតខ្លឹមសារ ធ្វើឲ្យបច្ចាបែកសាមគ្គី។
ដប់ប្រាំបួននយោបាយដ៏ស័ក្ដិសិទ្ធិ អាចទិញទឹកចិត្តឲ្យពលី
ព្រោះមេដឹកនាំមិនវក់វី គ្រប់គ្រងគិតពីចិត្តខ្លួនឯង។
ម្ដេឧបាយកលស្នាក់វាយលុក ប្រាជ្ញាធៀយុកយ៉ាងចិញ្ចែង
ស្នាក់គ្រប់ដប់ទិសគួរស្ញប់ស្ញែង ខ្លាំងទាល់ចម្បែងគេចមិនរួច។

**ឱុយ ខាសនា**

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# វគ្គបណ្តុះបណ្តាលជំរុញទឹកចិត្ត

យើងទាំងអស់គ្នាជាគណៈកម្មការដាំដើមជីវិត សូមជម្រាបជូនមិត្តអ្នកអានបានជ្រាបជាដំណឹងថា យើងខ្ញុំបានបង្កើតវគ្គបណ្តុះបណ្តាលពិសេសយ៉ាងច្រើនទាំងក្នុងប្រទេសនិងក្រៅប្រទេសដែលមានឈ្មោះថា...

**SLES** Successful life Education System [illegible]

វគ្គបណ្តុះបណ្តាលនេះដឹកនាំដោយថ្នាក់ដឹកនាំរបស់យើងគឺលោក

**ប្រាជ្ញ វិជ័យ** អ្នកបង្កើតយុទ្ធសាស្ត្រជីវិតនិងអ្នកនិយាយជំរុញចិត្តមនុស្សដ៏មានឥទ្ធិពល...

ដូច្នេះមិត្តអ្នកអានទាំងឡាយរូបណាចង់ចូលរួមវគ្គបណ្តុះបណ្តាលនេះជាមួយយើងខ្ញុំក៏អាចចូលរួមបានព្រោះយើងខ្ញុំកំពុងតែដឹកនាំបណ្តុះបណ្តាលជារៀងរាល់ខែ។

## លោកអ្នកនឹងទទួលបាន...

១-លោកអ្នកនឹងទទួលបាននូវបច្ចេកទេសនៃការអភិវឌ្ឍន៍កម្លាំងតាមបែបលោតផ្លោះ

២-លោកអ្នកនឹងបានរៀននូវបច្ចេកទេសក្នុងការអភិវឌ្ឍន៍ខ្លួនក្នុងលក្ខណៈទាន់សម័យដើម្បីជោគជ័យ

៣-លោកអ្នកនឹងបានរៀនបច្ចេកទេសរបស់អ្នកជោគជ័យមកអភិវឌ្ឍខ្លួនឯង

៤-អ្នកនឹងអាចសាងនូវអ្វីដែលជារបស់លោកអ្នកហើយវានឹងនៅជាមួយលោកអ្នកជារៀងរហូត

៥-លោកអ្នកនឹងបានរៀបចំប្រព័ន្ធនៃការគិតនៅក្នុងអ្វីដែលអ្នកត្រូវការ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

៦-លោកអ្នកអាចហ្វឹកហាត់កាយ ពាក្យសម្តី គំនិតក្នុងបែបថ្មីមួយទៀតធ្វើឲ្យជីវិតអ្នករឹតតែមានតម្លៃ

៧-លោកអ្នកនឹងជួបនូវក្តីស្រមៃហើយប្រើក្តីស្រមៃនោះឲ្យក្លាយជាការពិត

៨-លោកអ្នកនឹងអាចបំបែកកំដែងដែលបិទបាំងនូវក្តីស្រមៃរបស់លោកអ្នក

៩-លោកអ្នកនឹងបានរៀនពីវិធីសាងនិងប្រើអារម្មណ៍ដើម្បីសេចក្តីសុខនិងភាពជោគជ័យ

១០-លោកអ្នកនឹងដឹងពីវិធីទំនាក់ទំនងជាមួយខ្លួនឯងដែលនឹងអាចធ្វើឲ្យអ្នកជាមនុស្សថ្មីម្នាក់ទៀតដែលអ្នកចង់បាន

១១-លោកអ្នកនឹងអាចរស់នៅក្នុងចំណោមនៃមនុស្សដែលកំពុងតែចង់អភិវឌ្ឍខ្លួនហើយវានឹងអាចបន្ថែមកម្លាំងក្នុងខ្លួនរបស់លោកអ្នក

១២-លោកអ្នកនឹងបានជួបនូវកម្លាំងជំរុញថ្មីមួយទៀត

១៣-លោកអ្នកនឹងបានជួបនូវកម្លាំងជីវិតក្នុងខ្លួនរបស់អ្នក១០០ភាគរយ

១៤-អ្នកនឹងបានជួបនូវបទពិសោធន៍ ឬមិត្តភាពដែលនឹងធ្វើឲ្យអ្នកជក់ចិត្តជិតអារម្មណ៍ក្នុងការដើរទៅមុខគ្មានថ្ងៃនឹងធុញទ្រាន់

១៥-លោកអ្នកនឹងបានរៀននូវបច្ចេកទេសនៃការប្រើកម្លាំងរបស់លោកអ្នកឲ្យបានពេញទំហឹងដើម្បីឈានទៅរកភាពជោគជ័យដូចក្តីប្រាថ្នា។

**ចូលរួមសិក្ខាសាលា SLES**

...គឺជាការបណ្តាក់ទុនដ៏មានតម្លៃបំផុតក្នុងជីវិតរបស់លោកអ្នក!

សូមទាក់ទងមកកាន់លេខ: ០៧៧ ៨៥ ០៣ ០៥

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# Smart tutor

មានទទួលសេវាកម្មបង្រៀនដល់ផ្ទះ

**ចំណេះដឹងទូទៅគ្រប់កម្រិត**

គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ភាសាខ្មែរ

**ភាសាបរទេសគ្រប់កម្រិត**

ភាសាចិន ភាសាអង់គ្លេស ភាសាថៃ ភាសាបារាំង ភាសាវៀតណាម

និងកុំព្យូទ័រគ្រប់កម្មវិធី

**បញ្ជាក់:** គ្រូសុទ្ធតែមានបទពិសោធន៍និងឆ្លងកាត់គរុកោសល្យយ៉ាងត្រឹមត្រូវ

ជាពិសេសគ្រូមួយចំនួនធំបញ្ចប់ការសិក្សាពីបរទេស

និងគ្រូមកពីបរទេសតែម្តង។

ទំនាក់ទំនងតាមទូរស័ព្ទលេខ ០៧៧ ៨៤ ០៣ ០៤

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# តម្រាពិជ័យសង្គ្រាម សាមកុក


១ . យុទ្ធវិធីនៃការឡោមព័ទ្ធ

២ . ប្រែប្រួលតាមឱកាស

៣ . ចំណុចខ្សោយនៃការចូលរួមពីសម្ពន្ធមិត្ត

៤ . យុទ្ធសាស្ត្រខ្ទីប្រើបង្កន់រួចប្លន់យកផ្ទះ

៥ . ឧបាយកលស្រីស្រស់

៦ . សង្គ្រាមញោះឲ្យខឹង

៧ . ឧបាយកលបញ្ឆោតខ្លាពីរក្បាលឲ្យដណ្តើមចំណីអាហារគ្នា

៨ . ឧបាយកលដេញខ្លាឲ្យទៅខាំជាមួយឆ្កែព្រៃ

៩ . ទស្សនវិជ្ជាកយោធារបស់ស៊ុនសេក

១០ . យុទ្ធសាស្ត្រស្រែកខាងឆ្វេងតែទៅវាយខាងស្តាំឬវាយពីលិចបញ្ឆោតពីកើត

១១ . សិល្បៈក្នុងការដេញប្រយុទ្ធ

១២ . ព័ត៌មានក្លែងក្លាយនិងការវិភាគព័ត៌មានរបស់អ្នកដឹកនាំ

១៣ . ផែនការរបស់តាន់កុង

១៤ . ប្រាជ្ញារបស់ទៀវហ៊ុយ

១៥ . ឧបាយកលបោកបញ្ឆោតសត្រូវឲ្យឆ្មើងកន្ទ្រើងឬឡើងចាង

១៦ . អ្នកដែលនៅក្នុងហេតុការណ៍តែងវង្វេងអ្នកដែលនៅក្រៅ
ហេតុការណ៍តែងមើលឃើញច្បាស់

១៧ . សង្គ្រាមប្លន់យកស្បៀងនៅស្រុកអ្វូចៅ

១៨ . ផ្សព្វផ្សាយពាក្យចចាមអារ៉ាមដើម្បីបំបែកកម្លាំងសត្រូវ

១៩ . ទឹកចិត្តអ្នកនយោបាយ

២០ . ឧបាយកលពួនស្ទាក់វាយលុកទាំង១០ទិលរបស់ផៀយុក



បោះពុម្ពលើកទី០៣

ISBN 978-999-63-60-57-2

9 789996 360572

៥០០០៛



www.facebook.com/7khmer
Fb page : Entertainment And Knowledge